# រាជរដ្ឋាភិបាលកម្ពុជា

## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ


# ចក្ខុវិស័យ និង យុទ្ធសាស្ត្រ
# កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## ដំណាក់កាលទី៣
## “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ”


រៀបចំដោយ

អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# បុព្វកថា

រាជរដ្ឋាភិបាលកម្ពុជា តែងតែយកចិត្តទុកដាក់និងកំណត់ទុកការងារកែទម្រង់ ជាឧបករណ៍គោលនយោបាយគន្លឹះសម្រាប់ដោះស្រាយបញ្ហាប្រឈមនានា និងបង្កើតកាលានុវត្តភាពថ្មីៗ ឆ្ពោះទៅរកអភិវឌ្ឍនភាពនិងវិបុលភាព។ ការងារកែទម្រង់ មិនគ្រាន់តែជាកិច្ចការដែលអាចជួយបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការងារប្រចាំថ្ងៃប៉ុណ្ណោះទេ ប៉ុន្តែថែមទាំងជួយបង្កើតគំនិតផ្តួចផ្តើមនិងនវានុវត្តន៍ជាច្រើនទៀត ក្នុងកាលៈទេសៈដែលកម្ពុជា កំពុងអភិវឌ្ឍខ្លួនពីប្រទេសដែលមានចំណូលមធ្យមកម្រិតទាប ទៅកាន់ប្រទេសដែលមានចំណូលមធ្យមកម្រិតខ្ពស់។ ក្នុងស្មារតីនេះ រាជរដ្ឋាភិបាលកម្ពុជា បានផ្តួចផ្តើមរៀបចំ និងដាក់ឱ្យអនុវត្តការងារកែទម្រង់ជាច្រើន ក្នុងវិស័យសាធារណៈ ជាពិសេសកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកែទម្រង់សម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។

ជាលទ្ធផលក្នុងរយៈពេល ១០ ឆ្នាំ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាលបានកសាងនិងសម្រេចបានជាសារវន្តនូវមូលដ្ឋាននៃ "**ភាពជឿទុកចិត្តនៃថវិកា**" និងបានបង្កើន "**គណនេយ្យភាពហិរញ្ញវត្ថុ**" របស់ក្រសួង-ស្ថាប័ន និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ក្នុងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យវាយតម្លៃលើការអនុវត្តថវិកា។ សមិទ្ធផលទាំងនេះនឹងធ្វើជាមូលដ្ឋានគ្រឹះសម្រាប់ធានាលទ្ធភាពផ្សារភ្ជាប់ថវិកាទៅនឹងគោល-នយោបាយ កម្មវិធីការងារ និងសកម្មភាពរបស់ក្រសួង ស្ថាប័ន និងអង្គភាពសាធារណៈនីមួយៗ ដែលនេះគឺជាជំហានកែទម្រង់មួយថ្មីទៀត ដែលត្រូវឈានចូលទៅក្នុងដំណាក់កាលទី៣ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" គិតចាប់ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០។

បច្ចុប្បន្ន គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពច្បាស់លាស់ ត្រូវបានកំណត់នៅក្នុង **យុទ្ធសាស្ត្រចតុកោណ** របស់រាជរដ្ឋាភិបាល និងនៅក្នុង **ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ** ក៏ប៉ុន្តែ នៅក្នុងកម្រិតវិស័យ និងកម្រិតក្រសួង-ស្ថាប័ន មានសេចក្តីត្រូវការកែលម្អនិងពង្រឹងបន្ថែមទៀត នូវការកំណត់គោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាព ដើម្បីធានាសង្គតិភាពទៅនឹងគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពរួមរបស់រាជ-រដ្ឋាភិបាលផង ក៏ដូចជាដើម្បីធានាភាពត្រឹមត្រូវ ភាពច្បាស់លាស់ និងភាពអាចវាស់វែងបាននូវលទ្ធផល ឬសមិទ្ធកម្មបានផង។ នៅក្នុងដំណាក់កាលទី៣នេះ **ក្របខ័ណ្ឌថវិការយៈពេលមធ្យម** ដែលរួមមានក្របខ័ណ្ឌចំណូលរយៈពេលមធ្យម ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងក្របខ័ណ្ឌគោលនយោបាយសាធារណៈរយៈពេលមធ្យម នឹងត្រូវបានរៀបចំដាក់ឱ្យអនុម័តដោយគណៈរដ្ឋមន្ត្រី ទន្ទឹមនឹងការរៀបចំនិងការអនុវត្តផែនការយុទ្ធសាស្ត្រថវិការបស់ក្រសួង ស្ថាប័ននីមួយៗ ប្រកបដោយប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងគណនេយ្យភាព។

ក្នុងបរិការណ៍នេះ ខ្ញុំសូមផ្តល់អនុសាសន៍ដល់គ្រប់ក្រសួង-ស្ថាប័នទាំងអស់ ត្រូវបំពេញការងារប្រទាក់ក្រឡាគ្នាប្រកបដោយស្មារតីនៃភាពជាម្ចាស់និងការទទួលខុសត្រូវខ្ពស់ តាមអភិក្រមត្រីមុខ គឺ បុរេសកម្ម, សកម្ម និងអន្តរសកម្មរវាងតួអង្គសំខាន់ៗ ទាំងអស់នៃប្រព័ន្ធថវិកាថ្មីរបស់ជាតិ ពិសេស គឺ÷

ទី១. **និម្មាបនករនៃប្រព័ន្ធថវិកាថ្មី** ÷ ពោលគឺ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងនាមជាសេនាធិការរបស់រាជរដ្ឋាភិបាល មានភារកិច្ចរៀបចំយុទ្ធសាស្ត្រនិងក្របខ័ណ្ឌគតិយុត្ត ឱ្យបាន

គ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយ សម្រាប់ធានាការដាក់ឱ្យអនុវត្តប្រព័ន្ធថវិកាថ្មី គឺថវិកាកម្មវិធី ប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។ ក្នុងមុខងារនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវដើរតួនាទីជាអ្នកនាំមុខ ក្នុងការរៀបចំក្របខ័ណ្ឌទាំងនេះ ឱ្យបានគ្រប់គ្រាន់ និងគ្រប់ជ្រុងជ្រោយ ព្រមទាំងត្រូវរៀបចំនិងដាក់ឱ្យអនុវត្តនូវប្រព័ន្ធតាមដាននិងត្រួតពិនិត្យវាយតម្លៃលើប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃកិច្ចដំណើរការអនុវត្ត។

ទី២. **ប្រតិបត្តិករនៃប្រព័ន្ធថវិកាថ្មី** ÷ ពោលគឺ ក្រសួង-ស្ថាប័នទាំងអស់ ដែលចូលរួមអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងត្រូវរៀបចំប្រែក្លាយក្របខ័ណ្ឌយុទ្ធសាស្ត្រ និងក្របខ័ណ្ឌគតិយុត្តខាងលើនេះ ឱ្យទៅជាផែនការយុទ្ធសាស្ត្រនិងបទដ្ឋានគតិយុត្តផ្ទៃក្នុង ដោយត្រូវកែតម្រូវ កែសម្រប និងកែសម្រួល ឱ្យមានសង្គតិភាព សមានគតិភាព និងសុខដុមភាព ជាមួយវិសេសភាពនៃរចនាសម្ព័ន្ធគ្រប់គ្រងនិងរចនាសម្ព័ន្ធគោលនយោបាយរបស់សាមីក្រសួង-ស្ថាប័ននីមួយៗ ទៅតាមជំហានគ្រូបដណ្តប់នៃថវិកាកម្មវិធីដែលបានកំណត់ដាក់ឱ្យអនុវត្ត ចំពោះក្រសួង-ស្ថាប័នជាបន្តបន្ទាប់រហូតដល់ពេញលេញ។

ទន្ទឹមនឹងជោគជ័យដែលរំលេចឡើងតាមរយៈសមិទ្ធផលដែលសម្រេចបានក្នុងរយៈពេល ១០ ឆ្នាំនេះ យើងបានកត់សម្គាល់និងទទួលស្គាល់ថា ប្រព័ន្ធរបស់យើងនៅមិនទាន់សុក្រឹតនៅឡើយ ព្រោះក្របខ័ណ្ឌគតិយុត្តនៅមានកង្វះចន្លោះ, យន្តការអនុវត្តប្រព័ន្ធនិងក្របខ័ណ្ឌគតិយុត្តនៅមិនទាន់ត្រូវបានរៀបចំពេញលេញ ឬ ត្រូវបានរៀបចំរួចហើយ តែមិនទាន់ត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពនៅឡើយ។ ឆន្ទៈកែទម្រង់ ភាពជាម្ចាស់ និងភាពជាអ្នកដឹកនាំក្នុងការងារកែទម្រង់ ស្ថិតក្នុងកម្រិតដែលត្រូវបំពេញបន្ថែមជាច្រើនទៀត ដើម្បីឆ្លើយតបទៅនឹងសេចក្តីត្រូវការចាំបាច់នៃការកែទម្រង់ ទន្ទឹមនឹងរចនាសម្ព័ន្ធស្ថាប័ន និងសមត្ថភាពនៃការគ្រប់គ្រងរបស់ក្រសួង-ស្ថាប័នមួយចំនួន នៅមិនទាន់ត្រូវបានរៀបចំ ឬ/និង មិនទាន់ត្រូវបានអនុវត្តប្រកបដោយសង្គតិភាពនិងសមានគតិភាពជាមួយប្រព័ន្ធថវិកាថ្មីតាមទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ជាពិសេស ធនធានមនុស្សមួយចំនួន ពុំទាន់មានសមត្ថភាពគ្រប់គ្រាន់ សម្រាប់បំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ឱ្យបានប្រកបដោយផលិតភាពនិងប្រសិទ្ធភាព រីឯធនធានមនុស្សមួយចំនួនទៀត ដែលមានសមត្ថភាព និងសក្តានុពល ពុំទាន់បានចូលកាន់មុខងារនិងភារកិច្ច ដែលសមស្របតាមជំនាញវិជ្ជាជីវៈនិងអស់សក្តានុពលរបស់ខ្លួននៅឡើយ។

ដើម្បីជាប្រទីបបំភ្លឺផ្លូវក្នុងពេលកំពុងចាប់ផ្តើមដំណើរការអនុវត្តដំណាក់កាលទី៣ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" នេះ រាជរដ្ឋាភិបាល សម្រេចផ្តល់អនុសាសន៍គន្លឹះ ដូចតទៅ÷

១. គ្រប់ក្រសួង-ស្ថាប័ន ត្រូវកសាងនិងលើកកម្ពស់ភាពជាអ្នកដឹកនាំ ដែលជាទេសធមិគន្លឹះនៃការបំពេញមុខងារនិងភារកិច្ច ជាពិសេសលើការងារកែទម្រង់ ចាប់តាំងពីកម្រិតរដ្ឋមន្ត្រីក្រសួង ប្រធានស្ថាប័ន កម្រិតថ្នាក់ដឹកនាំក្រសួងរហូតដល់កម្រិតគ្រប់គ្រង និងថ្នាក់ដឹកនាំបច្ចេកទេស។ ទន្ទឹមនេះ គ្រប់ក្រសួង-ស្ថាប័ន ត្រូវបង្កើនឆន្ទៈនិងស្មារតីនៃភាពជាម្ចាស់លើការងារកែទម្រង់ ដែលត្រូវបានសម្រេចដោយរាជរដ្ឋាភិបាល ក្នុងក្របខ័ណ្ឌគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

២. គ្រប់ក្រសួង-ស្ថាប័ន ត្រូវយកចិត្តទុកដាក់ជាពិសេស នៅក្នុងដំណាក់កាលទី៣នេះ លើការពង្រឹងសមត្ថភាពធនធានមនុស្ស ដែលជាកត្តាកំណត់ជោគជ័យ នៃការងារកែទម្រង់។ ក្នុងស្មារតីនេះ ខ្ញុំសូមគាំទ្រនិងជំរុញការផ្តួចផ្តើមនិងនវានុវត្តន៍ទាំងឡាយ ដែលធ្វើឡើង ក្នុងគោលបំណង÷

- **ពង្រឹងគណនេយ្យភាព** របស់មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ តាមរយៈការរៀបចំនិងការអនុវត្តយន្តការត្រួតពិនិត្យតាមដាននិងវាយតម្លៃលើការបំពេញមុខងារនិងភារកិច្ចរបស់មន្ត្រីរាជការ ក្នុងគោលដៅបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការអនុវត្តថវិកាកម្មវិធីនិងអង្គភាពថវិកា
- **ផ្តល់ឱកាសដល់បេក្ខជនដែលមានសមត្ថភាព** ដើម្បីក្លាយជាមន្ត្រីរាជការ ដោយអនុវត្តគោលការណ៍សមភាពនិងតម្លាភាព ព្រមទាំង**ផ្តល់ការលើកទឹកចិត្ត** ដល់មន្ត្រីរាជការដែលមានគុណបំណាច់ ដោយអនុវត្តគោលការណ៍គុណាធិបតេយ្យ អនុលោមតាមប្រព័ន្ធនិងយន្តការវាយតម្លៃជាក់លាក់និងយុត្តិធម៌
- **អភិវឌ្ឍសមត្ថភាព** មន្ត្រីរាជការដែលពុំទាន់មានសមត្ថភាពជំនាញគ្រប់គ្រាន់ ក្នុងការបំពេញមុខងារនិងភារកិច្ចរបស់ខ្លួន ព្រមទាំងផ្តល់មុខងារនិងភារកិច្ច ដល់មន្ត្រីរាជការដែលមានសមត្ថភាព ឱ្យបានសមស្របតាមជំនាញវិជ្ជាជីវៈ និងសក្តានុពលភាព ជាអតិបរមា។

៣. គ្រប់ក្រសួង-ស្ថាប័ន ត្រូវលើកកម្ពស់ស្មារតីរបស់ថ្នាក់ដឹកនាំនិងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ក្នុងភាពជាម្ចាស់និងការទទួលខុសត្រូវខ្ពស់លើការងារកែទម្រង់ តាមរយៈស្មារតីការងារជាក្រុម ៣ យ៉ាង គឺ សាសង សម្របសម្រួល និងសហការ ទាំងនៅក្នុងក្របខ័ណ្ឌផ្ទៃក្នុងក្រសួង-ស្ថាប័ននីមួយៗ ទាំងនៅក្នុងក្របខ័ណ្ឌអន្តរក្រសួង-ស្ថាប័ន និងជាពិសេសក្នុងក្របខ័ណ្ឌអន្តរកម្មវិធីកែទម្រង់ ដើម្បីបង្កើនកាលានុវត្តភាពនៃការសម្រេចជោគជ័យលើការងារកែទម្រង់ជាឧត្តមប្រយោជន៍ដល់ការអភិវឌ្ឍស្ថាប័នជាតិនិងការបង្កើនគុណភាពសេវាសាធារណៈជូនដល់ប្រជាពលរដ្ឋ។

ជាក់ស្តែង យន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដែលត្រូវបានបង្កើតឡើងកន្លងមក ត្រូវបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃកិច្ចដំណើរការ ដើម្បីផ្តល់វិធានការដោះស្រាយជាក់ស្តែង ប្រកបដោយសមានគតិភាព ជាមួយនឹងបញ្ហាប្រឈមដែលកើតមានឡើងជាលក្ខណៈអន្តរកំណែទម្រង់ សំដៅធានាឱ្យបាននូវសង្គតិភាព ភាពប្រទាក់ក្រឡាគ្នា និងសុខដុមភាពនៃដំណើរការកែទម្រង់ទាំងបីរបស់រាជរដ្ឋាភិបាលស្របតាមយុទ្ធសាស្ត្រចតុកោណ ដំណាក់កាលទី៣ និងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។

៤. គ្រប់ក្រសួង-ស្ថាប័ន ត្រូវអនុវត្តប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនូវ **សារាចរស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ** ដែលត្រូវបានដាក់ចេញដោយរាជរដ្ឋាភិបាល កាលពីពេលថ្មីៗនេះ ដើម្បីធានាសង្គតិភាពនិងសមានគតិភាពនៃការរៀបចំ ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការអនុវត្ត ព្រមទាំងសុក្រឹតភាពនិងភាពទាន់ពេលនៃការត្រួតពិនិត្យតាមដាននិងវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ខ្ញុំរំពឹងថា ការរៀបចំប្រព័ន្ធនិងយន្តការត្រួតពិនិត្យតាមដាននិងវាយតម្លៃសមិទ្ធកម្មនៃការងារកែទម្រង់របស់ក្រសួងស្ថាប័ន ដោយភ្ជាប់មកជាមួយនូវវិធានការលើកទឹកចិត្តនិងវិធានការរឹតត្បិត ឆ្លុះបង្ហាញកាន់តែច្បាស់អំពីស្មារតីនៃភាពជាម្ចាស់និងការទទួលខុសត្រូវខ្ពស់របស់រាជរដ្ឋាភិបាល លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅចំពោះមុខប្រជាពលរដ្ឋ ទូទាំងប្រទេស ក៏ដូចជាភាពជាម្ចាស់និងការទទួលខុសត្រូវខ្ពស់របស់ក្រសួង-ស្ថាប័នទាំងអស់ នៅចំពោះមុខរាជរដ្ឋាភិបាលផងដែរ ព្រមទាំងការទទួលខុសត្រូវរបស់ប្រធានស្ថាប័ន នៅចំពោះមុខប្រមុខរាជរដ្ឋាភិបាល។

ជាបទពិសោធន៍នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ***"គ្មានសមិទ្ធផលណាដែលបានមកដោយពុំមានការបង់ថ្លៃនោះទេ ហើយក៏គ្មានការកែទម្រង់ណា ដែលសម្រេចបានដោយពុំមានការលះបង់នោះដែរ"*** ។ នេះគឺជាច្បាប់សត្យានុម័ត ដែលរាជរដ្ឋាភិបាល ពិតជាគ្មានជម្រើសអ្វីផ្សេង ក្រៅពីត្រូវធ្វើការកែទម្រង់ តាមទិសស្លោក ដែលខ្ញុំតែងតែរំលឹកថា ***"កែទម្រង់ គឺ រស់, បើមិនកែទម្រង់ គឺស្លាប់"***។

ជាលទ្ធផល ជាមួយនឹងចក្ខុវិស័យនិងយុទ្ធសាស្រ្តច្បាស់លាស់ សុទិដ្ឋិនិយម មហិច្ឆតា និងប្រាកដនិយម កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានសម្រេចជោគជ័យក្នុងដំណាក់កាលទី២ និងបានបោះជំហានប្រកបដោយជវភាពនិងសក្តានុពលភាព ឆ្ពោះទៅកាន់ដំណាក់កាលទី៣ នាឆ្នាំ២០១៦ តាមការគ្រោងទុក។

ក្នុងនាមរាជរដ្ឋាភិបាល ខ្ញុំសូមសម្តែងនូវការវាយតម្លៃខ្ពស់ និងសូមថ្លែងអំណរគុណ ជូនចំពោះឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ក្នុងនាមជាប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងឯកឧត្តមបណ្ឌិត **អូន ព័ន្ធមុនីរ័ត្ន** ក្នុងនាមជាប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងឯកឧត្តម លោកជំទាវ ជារដ្ឋមន្រ្តីនិងប្រធានស្ថាប័ន និងមន្រ្តីរាជការគ្រប់លំដាប់ថ្នាក់ទាំងអស់ ដែលបានខិតខំប្រឹងប្រែងយ៉ាងប្អូរផ្តាច់ ក្នុងការដឹកនាំនិងសហការអនុវត្ត **"កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ"** ប្រកបដោយឆន្ទៈក្លៀវក្លា និងស្មារតីនៃភាពជាម្ចាស់និងការទទួលខុសត្រូវខ្ពស់ រហូតសម្រេចបានជោគជ័យ គួរជាទីមោទនៈ។

ទន្ទឹមនេះ រាជរដ្ឋាភិបាល សូមសម្តែងអំណរគុណយ៉ាងជ្រាលជ្រៅជូនចំពោះដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលតែងតែផ្តល់ការគាំទ្រ ទាំងផ្នែកហិរញ្ញវត្ថុ និងបច្ចេកទេស តាមរយៈកិច្ចសម្របសម្រួលនិងកិច្ចសហការជាប្រចាំជាមួយរាជរដ្ឋាភិបាល ព្រមទាំងជាមួយក្រសួង-ស្ថាប័នទាំងអស់ ក្នុងអភិក្រមគ្របដណ្តប់ទូទាំងវិស័យ និងការគោរពភាពជាម្ចាស់របស់រាជរដ្ឋាភិបាលកម្ពុជា ក្នុងកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃព្រះរាជាណាចក្រកម្ពុជា។

ជាមួយនឹងសតិសម្បជញ្ញៈនៃភាពជាម្ចាស់និងការទទួលខុសត្រូវខ្ពស់ ចំពោះការងារកែទម្រង់ ខ្ញុំមានក្តីរំពឹងយ៉ាងមុតមាំថាដំណាក់កាលទី៣ **"ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ"** នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រាកដជាដំណើរការទៅប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ដើម្បីបុព្វហេតុ នៃការបម្រើឧត្តមប្រយោជន៍របស់ប្រជាពលរដ្ឋកម្ពុជា។

រាជធានីភ្នំពេញ ថ្ងៃទី ០៥ ខែកុម្ភៈ ឆ្នាំ២០១៦

**នាយករដ្ឋមន្រ្តី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# អារម្ភកថា

ដំណាក់កាលទី១ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាលនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤។ ពេលនោះ គោលដៅចម្បងរបស់យើង គឺ "**ការបង្កើនភាពជឿទុកចិត្តនៃថវិកា**" ដែលផ្តោតលើការពង្រឹងការប្រមូលនិងការគ្រប់គ្រងចំណូល ការពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និងការកែលម្អនីតិវិធីនៃការអនុវត្តថវិកា។ ស្របតាមគោលដៅនេះ នៅក្នុងដំណាក់កាលទី១ យើងបានដាក់ចេញនិងជំរុញការអនុវត្តវិធានការជាច្រើន ដែលសំដៅជាសំខាន់លើការដោះស្រាយបញ្ហាបំណុលសាច់ប្រាក់ និងកង្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ។ បន្ទាប់ពីបានអនុវត្តអស់រយៈពេល ៤ ឆ្នាំ និងដោយពិនិត្យឃើញថា ភាពជឿទុកចិត្តនៃថវិកា ត្រូវបានសម្រេចជាមូលដ្ឋាន យើងក៏បានដាក់ចេញនូវ "**ដំណាក់កាលទី២ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" នៅចុងឆ្នាំ២០០៨ ជាមួយនឹងគោលដៅចម្បងនៃ "**ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ**" ដោយផ្តោតជាសំខាន់លើការរៀបចំ ការកែលម្អ ព្រមទាំងការពង្រឹងការកត់ត្រា និងការធ្វើរបាយការណ៍គណនេយ្យនិងហិរញ្ញវត្ថុ ឱ្យបានកាន់តែត្រឹមត្រូវ ច្បាស់លាស់ សុក្រឹត និងទាន់ពេលវេលា ស្របតាមស្តង់ដារអន្តរជាតិ។ យើងបានចាយពេលជាង ៦ ឆ្នាំ ក្នុងការត្រៀមរៀបចំសមាសភាគជាច្រើនសម្រាប់កសាង "**មូលដ្ឋានគ្រឹះនៃប្រព័ន្ធថវិកាថ្មី**" ដែលជា "**ស្នូលនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល**"។

ការចាប់ផ្តើមដំណាក់កាលទី៣ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" បានបង្ហាញថាការកែទម្រង់របស់យើង បានឈានមកដល់ចំណុចមួយដ៏សំខាន់ នោះគឺដំណាក់កាលនៃការចាប់ផ្តើមធ្វើការផ្លាស់ប្តូរមួយចំណែកម្តងៗ នៃប្រព័ន្ធថវិកាបច្ចុប្បន្ន ដោយបានចាប់ផ្តើមពីចុងឆ្នាំ២០១៥ នេះ តាមរយៈការដាក់ឱ្យអនុវត្តមាតិកាថវិកាថ្មី ស្តង់ដារគណនេយ្យ និងប្លង់គណនេយ្យថ្មី អង្គភាពថវិកា និងនីតិវិធីអនុវត្តថវិកាថ្មី រួមជាមួយនឹងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជំហានទី១ ព្រមទាំងការចាប់ផ្តើមពង្រឹង និងពង្រីកការអនុវត្តថវិកាកម្មវិធីពេញលេញ ជាជំហានៗ ទៅក្នុងចំណោមក្រសួង-ស្ថាប័នរដ្ឋ គ្រប់ថ្នាក់ ទាំងថ្នាក់ជាតិនិងថ្នាក់ក្រោមជាតិ ដោយចាប់ផ្តើមពីឆ្នាំ២០១៥ ទៅរហូតដល់ឆ្នាំ២០១៨ ស្របតាម "**ទស្សនាទានស្តីពីទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកា ២០១៣-២០២០**" ក្នុងគោលដៅបោះជំហាន ឆ្ពោះទៅកាន់ការកែប្រែប្រព័ន្ធថវិកាទាំងស្រុងពី "**ប្រព័ន្ធថវិកាផ្តោតលើធាតុចូល និងមជ្ឈការ ទៅជាប្រព័ន្ធថវិកាផ្តោតលើលទ្ធផល ឬធាតុចេញ និងវិមជ្ឈការ**" ឱ្យបាននៅឆ្នាំ២០២០។ ការរៀបចំការផ្លាស់ប្តូរនេះ គឺជាការងារស្នូល នៃដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់យើង ដែលកំណត់យក ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ជាគោលដៅចម្បង។ បន្ទាប់មកទៀត តាមការគ្រោងទុក ចាប់ពីឆ្នាំ២០២០ យើងនឹងបន្តពង្រឹងនិងពង្រីក ការអនុវត្តប្រព័ន្ធថវិកាកម្មវិធី ដែលផ្តោតលើលទ្ធផល ឬធាតុចេញនេះ ជាបណ្តើរៗ ឆ្ពោះទៅរក "**ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម**" នៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទាំងមូល ឱ្យបានសម្រេចនៅឆ្នាំ២០២៥ ដែលនេះគឺជាគោលដៅចម្បងនៃដំណាក់កាលចុងក្រោយ គឺ ដំណាក់កាលទី៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

បរិការណ៍កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់យើង បានចង្អុលប្រាប់យ៉ាងជាក់ប្រាកដថា ការងារកែទម្រង់នេះ គឺជាមាគ៌ាដ៏ត្រឹមត្រូវតែមួយគត់ ដែល **អគ្គមហាវិជ្ជបុរស** នៃយើង គឺ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា បានសម្រេចជ្រើសរើសយកមកប្រតិបត្តិយ៉ាងតក់មត់និងម៉ឺងម៉ាត់ក្លៀវក្លា តាមទស្សនវិស័យដ៏ប្រាកដនិយម គឺ "**កែទម្រង់គឺរស់, មិនកែទម្រង់ គឺស្លាប់**"។ ហេតុនេះ យើងពិតជាគ្មានជម្រើសអ្វីផ្សេងឡើយ ក្រៅពីការខិតខំពុះពារជំនះការលំបាក និងឧបសគ្គសព្វសារពើ ដើម្បីអភិវឌ្ឍសមត្ថភាពដឹកនាំ គ្រប់គ្រង និងប្រតិបត្តិការ លើការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយបំពាក់ជាប់ជានិច្ចនូវស្មារតីនៃភាពជាម្ចាស់ និងការទទួលខុសត្រូវខ្ពស់ ចំពោះគោលដៅកែទម្រង់ដែលបានកំណត់ ប្រកបដោយសតិសម្បជញ្ញៈនៃលក្ខណៈបន្ទាន់ មហិច្ឆតា និងប្រាកដនិយម នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជាយើង។

ប្រាកដណាស់ ថវិកាកម្មវិធី គឺជាស្នូលនៃការកែទម្រង់ប្រព័ន្ធថវិកា នៅក្នុងដំណាក់កាលទី៣. "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" ដែលនឹងឈានមកដល់នៅឆ្នាំ២០១៦ ប៉ុន្តែការអនុវត្ត "**យុទ្ធសាស្ត្រកែទម្រង់បោះជំហានជាដំណាក់កាល**" បានបង្ហាញប្រាប់យើងថា កិច្ចការនេះ គឺជាជំហានទី៣ នៃការកែទម្រង់ ដែលយើងបានរៀបចំត្រៀមខ្លួនបានជាច្រើនរួចមកហើយ នៅក្នុងដំណាក់កាលទី២ ហើយទាមទារជាចាំបាច់ឱ្យយើងត្រូវពង្រឹង និងបំពេញបន្ថែមទៀត ទាំងក្នុងកម្រិតប្រព័ន្ធ យន្តការ ក្របខ័ណ្ឌគតិយុត្ត និងធនធានមនុស្ស។

ដើម្បីធានាបានសុក្រឹតភាពនៃការផ្សារភ្ជាប់ទៅនឹងគោលនយោបាយ ថវិកានិងរចនាសម្ព័ន្ធស្ថាប័នគ្រប់គ្រងចាំបាច់ត្រូវពិនិត្យនិងកែលម្អបន្ថែម សំដៅបន្ស៊ីគ្នានិងភ្ជាប់គ្នា ជាមួយគោលបំណងគោលនយោបាយ ពោលគឺគម្លាតរវាងរចនាសម្ព័ន្ធស្ថាប័ននិងផែនការថវិកា ជាមួយនឹងគោលនយោបាយ ត្រូវបានកាត់បន្ថយជាអតិបរមា។ ក្នុងទស្សនៈនេះ រចនាសម្ព័ន្ធគោលនយោបាយ នឹងត្រូវកំណត់ឱ្យបានជាក់ប្រាកដបន្ថែម ទាំងផ្នែកទំនាក់ទំនងអន្តរវិស័យ និងជាឋានានុក្រមគោលនយោបាយ រវាងយុទ្ធសាស្ត្រចតុកោណ ផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិរយៈពេល៥ឆ្នាំ កម្មវិធីវិនិយោគសាធារណៈ៣ឆ្នាំរំកិល ក្របខ័ណ្ឌថវិការយៈពេលមធ្យម ក្របខណ្ឌចំណូលនិងចំណាយរយៈពេលមធ្យម និងគោលការណ៍ណែនាំរបស់រាជរដ្ឋាភិបាលស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងគម្រោងថវិកាប្រចាំឆ្នាំ។ សុខដុមនីយកម្មជាប្រព័ន្ធ លើទំនាក់ទំនងនិងលំដាប់ឋានានុក្រមនៃបទដ្ឋានគោលនយោបាយទាំងនេះ គឺជាលក្ខខណ្ឌចាំបាច់និងជាមូលដ្ឋានសម្រាប់ធ្វើការផ្សារភ្ជាប់គោលបំណងគោលនយោបាយ របស់ក្រសួង-ស្ថាប័ននីមួយៗ ទៅនឹងគោលនយោបាយរបស់រាជរដ្ឋាភិបាលផង និងផ្សារភ្ជាប់ទៅនឹងគម្រោងថវិកាប្រចាំឆ្នាំរបស់ក្រសួង-ស្ថាប័នផង។ យន្តការសម្រាប់ធានាសុខដុមនីយកម្មនៃក្របខណ្ឌគោលនយោបាយនេះ ចាំបាច់ត្រូវពិនិត្យ រៀបចំ និងកែលម្អបន្ថែម ដើម្បីធានាបាននូវសង្គតិភាព ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព នៃការអនុវត្តគោលបំណងគោលនយោបាយរបស់ក្រសួង-ស្ថាប័ននីមួយៗ ប្រកបដោយលក្ខណៈភ្ជាប់គ្នាជាមួយនឹងការសម្រេចសមិទ្ធកម្មលើគោលនយោបាយរបស់រាជរដ្ឋាភិបាល។

ម្យ៉ាងទៀត ជាមួយនឹងរចនាសម្ព័ន្ធគោលនយោបាយ ដែលត្រូវមានទំនាក់ទំនងភ្ជាប់គ្នានិងលំដាប់ឋានានុក្រមរវាងគ្នាកំណត់ជាក់លាក់ហើយនោះ រចនាសម្ព័ន្ធគ្រប់គ្រងស្ថាប័ន ក៏ត្រូវកំណត់ឱ្យបានជាក់លាក់ផងដែរអំពីមុខងារ ភារកិច្ច សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់ថ្នាក់ដឹកនាំក្រសួង អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន នាយកដ្ឋាន ការិយាល័យ ដែលនឹងត្រូវពិនិត្យលក្ខណៈសម្បត្តិនិងសមត្ថភាព ក្នុងការផ្តល់ជូននូវមុខងារជាអង្គភាពហិរញ្ញវត្ថុ និងអង្គភាពថវិកា ជាមួយនឹងសិទ្ធិអំណាចសមស្របក្នុងការអនុវត្តកិច្ចប្រតិបត្តិការហិរញ្ញវត្ថុរបស់ខ្លួន ទៅតាមកម្រិតកំណត់

ដោយប្រធានស្ថាប័ន ដែលជាអាណាប័ក។ ក្នុងន័យនេះ ក្របខ័ណ្ឌនៃមុខងារ ភារកិច្ច សិទ្ធិអំណាច និងការទទួលខុសត្រូវទាំងឡាយ គប្បីត្រូវបានកំណត់បន្ថែមឱ្យបានច្បាស់លាស់ ហើយក៏ត្រូវយកទៅសម្របទៅតាមរចនាសម្ព័ន្ធគ្រប់គ្រងរបស់ក្រសួង-ស្ថាប័ន នីមួយៗ សំដៅធានាឱ្យគម្រោងថវិកាប្រចាំឆ្នាំ ត្រូវបានរៀបចំឡើង ដោយរំលេចឃើញកាន់តែច្បាស់នូវការចូលរួមប្រកបដោយភាពគ្រប់ជ្រុងជ្រោយ ក្នុងការអនុវត្តមុខងារនិងភារកិច្ច ពីគ្រប់តួអង្គប្រតិបត្តិពាក់ព័ន្ធអនុលោមតាមរចនាសម្ព័ន្ធគ្រប់គ្រង និងឆ្លុះបង្ហាញជាក់លាក់អំពីសមិទ្ធកម្មដែលត្រូវសម្រេចបានធៀបទៅនឹងគោលបំណងគោលនយោបាយ និងកម្មវិធីដែលត្រូវបានកំណត់ដោយសាមីក្រសួង-ស្ថាប័ននីមួយៗ។

ជារួម ក្នុងគោលដៅសម្រេចឱ្យបាននូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ថវិកាអាចបំពេញមុខងារជាឧបករណ៍ដ៏ស័ក្តិសិទ្ធិរបស់គោលនយោបាយបាន លុះត្រាតែលក្ខណៈសម្បត្តិទាំង៤ប្រការ ដូចខាងក្រោម ត្រូវបានបំពេញ គឺ÷

ទី១. ប្រព័ន្ធ ត្រូវបានរៀបចំត្រឹមត្រូវ÷ បានន័យថា រចនាសម្ព័ន្ធគោលនយោបាយ និងរចនាសម្ព័ន្ធគ្រប់គ្រងត្រូវបានកំណត់ជាក់លាក់ ទាំងកត្តាទំនាក់ទំនងផ្សារភ្ជាប់ ទាំងកត្តាលំដាប់ថានានុក្រម។

ទី២. យន្តការ ត្រូវបានកំណត់ច្បាស់លាស់÷ មានន័យថា រចនាសម្ព័ន្ធគោលនយោបាយនិងរចនាសម្ព័ន្ធគ្រប់គ្រងអាចដំណើរការទៅដោយប្រទាក់ក្រឡាគ្នាបាន លុះត្រាតែវិធាន នីតិវិធី មុខងារ ភារកិច្ច សិទ្ធិអំណាច និងការទទួលខុសត្រូវរបស់គ្រប់តួអង្គពាក់ព័ន្ធ ជាអាទិ៍អង្គភាពហិរញ្ញវត្ថុ អង្គភាពថវិកា ត្រូវបានកំណត់ឱ្យមានជាខ្សែបន្ទាត់គណនេយ្យភាពជាក់លាក់។

ទី៣. ក្របខណ្ឌគតិយុត្ត ត្រូវបានបង្កើតនិងដាក់ឱ្យអនុវត្ត÷ ក្នុងន័យនេះ ប្រព័ន្ធ និងយន្តការ ដែលបានកំណត់ខាងលើ ត្រូវរៀបចំឡើង នៅក្នុងក្របខ័ណ្ឌគតិយុត្តមួយ ប្រកបដោយនីត្យានុកូលភាព *(ស្របច្បាប់)* និងគតិយុត្តភាព *(ត្រឹមត្រូវតាមវិធីសាស្ត្រច្បាប់ មានការគោរពឋានានុក្រមគតិយុត្ត អានុភាពគតិយុត្ត សមស្របតាមកម្លាំងគតិយុត្តនៃលិខិតបទដ្ឋានដែលបានដាក់ចេញជាដើម)*។

ទី៤. ធនធានមនុស្ស គឺជាកត្តាកំណត់ជោគជ័យ÷ បានសេចក្តីថា ធនធានមនុស្សត្រូវមានគុណវុឌ្ឍិគ្រប់គ្រាន់ដើម្បីធានាកិច្ចដំណើរការប្រកបដោយប្រសិទ្ធភាព និងស័ក្តិសិទ្ធភាព។

មុននឹងបញ្ចប់ ក្នុងនាមគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ខ្ញុំសូមសម្តែងកតញ្ញូកតវេទិតាធម៌ ដោយគារវកិច្ចយ៉ាងវិសុទ្ធ ជូនចំពោះ អគ្គមហាបុរសនៃយើង គឺ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន នាយករដ្ឋមន្ត្រី នៃព្រះរាជាណាចក្រកម្ពុជា** ដែលតែងតែផ្តល់ចក្ខុវិស័យដឹកនាំដ៏ប្រាកដនិយម និងស្ថាបនាមាគ៌ានយោបាយដ៏ត្រឹមត្រូវ ដើម្បីសម្រេចជោគជ័យលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទន្ទឹមនេះ ខ្ញុំសូមសម្តែងនូវការដឹងគុណដ៏ជ្រាលជ្រៅ ជូនចំពោះឯកឧត្តមកិត្តិសេដ្ឋាបណ្ឌិត **គាត ឈន់** ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលតែងតែបានផ្តល់ឱវាទដឹកនាំដល់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងនាមជាសសរស្តម្ភមួយ នៃគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

ខ្ញុំសូមសម្តែងមូលវិចារដ៍ថ្លៃវិសេសជូនដល់សម្តេច ឯកឧត្តម លោកជំទាវ ជារដ្ឋមន្ត្រី និងប្រធានស្ថាប័ន ដែលតែងតែដឹកនាំនិងគាំទ្រដល់ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង-ស្ថាប័ន ព្រមទាំង

មន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ ដែលបាននិងកំពុងចូលរួមចំណែកអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយស្មារតីនិងសតិសម្បជញ្ញៈ នៃភាពជាម្ចាស់ ការទទួលខុសត្រូវខ្ពស់ និងភាពជាអ្នកដឹកនាំគម្រូលើការងារកែទម្រង់ រហូតសម្រេចបានសមិទ្ធផលដ៏វិសេសនាពេលនេះ។

ជាចុងក្រោយ ខ្ញុំសូមសម្តែងនូវអំណរគុណយ៉ាងជ្រាលជ្រៅ ជូនចំពោះគ្រប់ដៃគូអភិវឌ្ឍន៍ទាំងអស់ ដែលតែងតែគាំទ្រ ទាំងផ្នែកហិរញ្ញវត្ថុ និង បច្ចេកទេស តាមរយៈកិច្ចសហការនិងកិច្ចសម្របសម្រួលជាប្រចាំជាមួយគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ខ្ញុំរំពឹងថា ចក្ខុវិស័យនិងយុទ្ធសាស្ត្រនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ "**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**" នេះ នឹងក្លាយជាប្រទីបគោចរបង្ហាញផ្លូវដល់គ្រប់តួអង្គពាក់ព័ន្ធទាំងអស់ អំពីកិច្ចដំណើរការនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាលកម្ពុជា ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។

រាជធានីភ្នំពេញ ថ្ងៃទី១៩ខែមករាឆ្នាំ២០១៦

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន**

**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត អូន ព័ន្ធមុនីរ័ត្ន**

# មាតិកានុក្រម


បុព្វកថា ........................................................................................ I

អារម្ភកថា ........................................................................................ V

មាតិកានុក្រម ........................................................................................ ៩

សេចក្តីផ្តើម ........................................................................................ ១៩

១. ចក្ខុវិស័យ និង យុទ្ធសាស្ត្រ ........................................................ ២២

២. ក្របខ័ណ្ឌស្ថាប័ន ........................................................................ ២៤

២.១. ក្របខ័ណ្ឌដឹកនាំ ........................................................................ ២៤

ក. គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ............................ ២៤

ខ. គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ.......... ២៥

គ. គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ .................................................... ២៦

២.២. ក្របខ័ណ្ឌអនុវត្ត ........................................................................ ២៦

ក. ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈប្រចាំក្រសួង- ស្ថាប័ន ....... ២៦

ខ. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ .................................................... ២៦

២.៣. ក្របខ័ណ្ឌសម្របសម្រួល និង សហប្រតិបត្តិការ.............................. ២៧

ក. ក្របខ័ណ្ឌសម្របសម្រួលរវាងក្រសួង- ស្ថាប័ន : អគ្គលេខាធិការដ្ឋាន
គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ.......... ២៧

ខ. ក្របខ័ណ្ឌសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ : ក្រុមការងារបច្ចេកទេស
គ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM-TWG)........................................ ២៧

គ. ក្របខ័ណ្ឌសម្របសម្រួលរវាងកំណែទម្រង់ទាំងបី : កម្មវិធីកែទម្រង់ការគ្រប់គ្រង
ហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ និង
កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ............ ២៨

៣. សមិទ្ធផល និងបញ្ហាប្រឈម នៃកម្មវិធីកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ នៅក្នុងរយៈពេល ១០ ឆ្នាំ ..................................... ៣០
៣.១. ដំណាក់កាលទី១ (២០០៤-២០០៨) ..................................... ៣០
ក. សមិទ្ធផល ..................................... ៣០
ខ. បញ្ហាប្រឈម..................................... ៣៤
៣.២. ដំណាក់កាលទី២ (២០០៩-២០១៥)..................................... ៣៤
ក. សមិទ្ធផល ..................................... ៣៥
ខ. បញ្ហាប្រឈម..................................... ៣៦
៤. ផែនការសកម្មភាព ដំណាក់កាលទី៣..................................... ៣៧
៥. ការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ..................................... ៤០
៦. ធនធានហិរញ្ញវត្ថុ..................................... ៤១
៦.១. ការចំណាយសម្រាប់គាំទ្រកិច្ចដំណើរការ នៃកម្មវិធីកែទម្រង់ ចាប់ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១៥..................................... ៤១
៦.២. តម្រូវការធនធានហិរញ្ញវត្ថុ សម្រាប់ដំណាក់កាលទី៣..................................... ៤២
៦.៣. ការគ្រប់គ្រងធនធាន ..................................... ៤៥
៧. ការគ្រប់គ្រងហានិភ័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ..... ៤៦
៧.១. និយមន័យនៃហានិភ័យ ..................................... ៤៦
៧.២. កម្រិតនៃហានិភ័យ ..................................... ៤៦
៧.៣. ហានិភ័យ និង សំណើវិធានការដោះស្រាយ..................................... ៤៨
៨. សេចក្តីសន្និដ្ឋាន ..................................... ៥៨
៨.១. បទពិសោធន៍..................................... ៥៨
៨.២. កត្តាកំណត់ជោគជ័យ..................................... ៥៩
បញ្ជីឧបសម្ព័ន្ធ..................................... ៦០

ឧបសម្ព័ន្ធ ១. ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ........ ៦៣
ឧបសម្ព័ន្ធ ២. អនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ.................................................................................. ៦៧
ឧបសម្ព័ន្ធ ៣. អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ.............................. ៧២
ឧបសម្ព័ន្ធ ៤. សារាចររាជរដ្ឋាភិបាល លេខ ០៩ សរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ.................. ៧៨
ឧបសម្ព័ន្ធ ៥. ប្រកាសលេខ ៦៤៩ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ........................................................... ៨៦
ឧបសម្ព័ន្ធ ៦. ប្រកាសលេខ ៣៤៧ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ.......... ៩១
ឧបសម្ព័ន្ធ ៧. សេចក្តីសម្រេចរួមលេខ ០០៦ សហវ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតយន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ........... ១០៧
ឧបសម្ព័ន្ធ ៨. សារាចរលេខ ០០៦ សហវ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ ស្តីពីយន្តការដោះស្រាយបញ្ហាប្រឈម ក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ......................................................... ១១០
ឧបសម្ព័ន្ធ ៩. ផែនការសកម្មភាពរួម ដំណាក់កាលទី៣.................................................. ១១៣

ឧបសម្ព័ន្ធ ១០. គំរូរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស និង គំរូរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ
នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ១៥៨
ឧបសម្ព័ន្ធ ១១. វិធីសាស្ត្រនៃការកំណត់ទម្ងន់ និង ការវាយតម្លៃការអនុវត្ត
ផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ...................... ១៨៥
ឧបសម្ព័ន្ធ ១២. អនុសាសន៍កែលម្អកង្វះចន្លោះនៃប្រព័ន្ធគ្រប់គ្រង
ហិរញ្ញវត្ថុសាធារណៈ (PEFA)............................................................ ២១២

## សេចក្តីផ្តើម

ចាប់ពីពាក់កណ្តាលទសវត្សទី៨០ រហូតមក កម្ពុជាបានសម្រេចយ៉ាងគត់មត់ ជ្រើសរើសយកមាគ៌ាកែទម្រង់ សម្រាប់ដឹកនាំការផ្លាស់ប្តូរពីប្រព័ន្ធសេដ្ឋកិច្ចផែនការ ទៅកាន់ប្រព័ន្ធសេដ្ឋកិច្ចទីផ្សារ ដោយឆ្លងកាត់កំណាត់ផ្លូវដ៏លំបាក ជាច្រើនគន្លាក់និងឧបសគ្គគ្រប់បែបយ៉ាង។ នៅលើវិថីនៃសេរី-ភាវូបនីយកម្មនិងស្ថិរភាវូបនីយកម្មសេដ្ឋកិច្ច កម្ពុជាទទួលស្គាល់អំពីភាពចាំបាច់នៃការស្ថាបនាមូលដ្ឋានរឹងមាំនៃប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដើម្បីធ្វើជាបរិស្ថានអនុគ្រោះដល់ស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ភាពធន់នៃសេដ្ឋកិច្ច និងចីរភាពនៃកំណើនសេដ្ឋកិច្ច។

ក្នុងស្មារតីនេះ វិធានការកែទម្រង់ជាច្រើនក្នុងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានដាក់ចេញជាបន្តបន្ទាប់ដោយរាជរដ្ឋាភិបាលកម្ពុជា នៅមុនការចាប់ផ្តើមជាផ្លូវការនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នាដំណាច់ឆ្នាំ២០០៤ ទៅទៀត។ ជាក់ស្តែង នៅឆ្នាំ១៩៩៣ បន្ទាប់ពីការបោះឆ្នោតជ្រើសតាំងតំណាងរាស្ត្រ អាណត្តិទី១ និង ការប្រកាសឱ្យប្រើរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជារួចមក ច្បាប់ស្តីអំពីប្រព័ន្ធហិរញ្ញវត្ថុដែលត្រូវបានរៀបចំតាក់តែងតាំងពីឆ្នាំ១៩៨៩ ក្នុងសម័យកាលនៃរដ្ឋកម្ពុជា ត្រូវបានអនុម័តនិងប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ ០១ នស ចុះថ្ងៃទី២៨ ខែធ្នូ ឆ្នាំ១៩៩៣ ដែលត្រូវបានបំពេញបន្ថែមដោយបទដ្ឋានគតិយុត្តជាច្រើនទៀត ជាអាទិ៍ ព្រះរាជក្រឹត្យ អនុក្រឹត្យ ប្រកាស និងសារាចរ។

ជាមួយនឹងឆន្ទៈនយោបាយមោះមុត ស្មារតីនៃភាពជាម្ចាស់ ការទទួលខុសត្រូវខ្ពស់ និងដោយមានសមិទ្ធផលលេចធ្លោជាបន្តបន្ទាប់នៃការកែទម្រង់លើផ្នែកចំណូលនិងផ្នែកចំណាយសាធារណៈ ព្រមទាំងការគាំទ្រយ៉ាងក្លៀវក្លាពីដៃគូអភិវឌ្ឍន៍ចំពោះការងារកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេសតាមរយៈកម្មវិធីពង្រឹងការគ្រប់គ្រងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (Technical Cooperation Assistance Program : TCAP) និងរបាយការណ៍វាយតម្លៃនិងត្រួតពិនិត្យចំណាយសាធារណៈ (Integrated Fiduciary Assessment and Public Expenditure Review : IFAPER) ដែលជាកម្មវិធីសហ-ប្រតិបត្តិការជំនួយបច្ចេកទេស និងគាំទ្រដោយដៃគូអភិវឌ្ឍន៍ជាច្រើន, រាជរដ្ឋាភិបាលកម្ពុជាបានផ្តួចផ្តើមរៀបចំបង្កើតកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈមួយ ដែលមានចក្ខុវិស័យនិងយុទ្ធសាស្ត្រប្រកបដោយលក្ខណៈវែងឆ្ងាយ ប្រាកដនិយម ខ្សែចង្វាក់ជាប្រព័ន្ធ និងគ្រប់ជ្រុងជ្រោយចំពោះឧត្តមប្រយោជន៍របស់ប្រទេសជាតិនិងប្រជាពលរដ្ឋកម្ពុជាទាំងមូល, ដែលត្រូវបានប្រកាស

ដាក់ឱ្យអនុវត្តជាផ្លូវការនៅថ្ងៃទី០៥ ខែធ្នូ ឆ្នាំ២០០៤ ក្រោមអធិបតីភាពដ៏ខ្ពង់ខ្ពស់ **សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា។

កម្មវិធីនេះផ្តោតសារៈសំខាន់លើការពង្រឹងនិងលើកកម្ពស់ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការគ្រប់គ្រងចំណូលនិងចំណាយនៃថវិកាជាតិ រួមទាំងការស្វែងរកថវិកា ការវិភាជន៍ថវិកា និងការប្រើប្រាស់ថវិកាដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ដើម្បីជាគុណប្រយោជន៍ដល់ការគាំទ្រដំណើរការអនុវត្តគោលនយោបាយតាមវិស័យ និងគោលបំណងគោលនយោបាយ/ យុទ្ធសាស្ត្ររបស់ក្រសួងស្ថាប័ន ដែលត្រូវបានកំណត់នៅក្នុងយុទ្ធសាស្ត្រចតុកោណនិងផែនការយុទ្ធសាស្ត្រអភិវឌ្ឍន៍ជាតិ។ ក្នុងទស្សនៈវិស័យនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវសម្រេចឱ្យបាននូវគោលដៅនៃថវិកា ៣ យ៉ាង គឺ÷ បូរណភាពនៃការគោរពវិន័យថវិកា ប្រសិទ្ធភាពនៃការវិភាជថវិកា និងស័ក្តិសិទ្ធភាពនៃការផ្តល់សេវាសាធារណៈ។

រាជរដ្ឋាភិបាលកម្ពុជា បានសម្រេចឯកភាពជាមួយដៃគូអភិវឌ្ឍន៍ ជ្រើសរើសយកអភិក្រមគ្របដណ្តប់លើវិស័យទាំងមូល (Sector Wide Approach) ធ្វើជាវិធីសាស្ត្រក្នុងការរៀបចំនិងអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងបានសម្រេចកំណត់យកធ្វើជាគោលដៅចុងក្រោយនៃការកែទម្រង់របស់ខ្លួននូវប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុ ឬ ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ ដែលបណ្តាប្រទេសជឿនលឿនលើសកលលោក ភាគច្រើនកំពុងពេញនិយម និងប្រកាន់យកមកអនុវត្តចាប់តាំងពីដើមទសវត្សទី៩០។

ប្រព័ន្ធគ្រប់គ្រងថវិកាផ្អែកលើលទ្ធផល ឬ សមិទ្ធកម្មនេះ គឺជាប្រព័ន្ធដែលផ្សារភ្ជាប់ការវិភាជថវិកាទៅនឹងសកម្មភាពជាក់ស្តែង និងកម្មវិធីច្បាស់លាស់ទៅនឹងគោលបំណងគោលនយោបាយអាទិភាពរបស់ក្រសួង-ស្ថាប័ន និងជាពិសេស ទៅនឹងគោលបំណងគោលនយោបាយតាមវិស័យ និងរបៀបវារៈគោលនយោបាយថ្នាក់ជាតិរបស់រដ្ឋាភិបាល ដើម្បីធានាថាថវិកាជាតិពិតជាដើរតួនាទីជាឧបករណ៍នៃគោលនយោបាយថ្នាក់ជាតិរបស់រដ្ឋាភិបាល ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពប្រាកដមែន។

នៅក្នុងលំអាននៃសាវតារនិងចក្ខុវិស័យកែទម្រង់ខាងលើ សៀវភៅកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ ត្រូវបានរៀបចំក្នុងគោលដៅ ២ យ៉ាង គឺ÷

ទី១. ធ្វើជាឯកសារទស្សនាទានស្តីពីចក្ខុវិស័យ យុទ្ធសាស្ត្រ និងទិសដៅនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល និង

ទី២. ធ្វើជាមគ្គុទេសក៍ស្តីពីកិច្ចដំណើរការអនុវត្តដំណាក់កាលទី៣ “**ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ**”។

ឯកសារនេះ ចែកចេញជា ៨ ផ្នែក គឺ÷

១. ចក្ខុវិស័យនិងយុទ្ធសាស្ត្រ

២. ក្របខ័ណ្ឌស្ថាប័ន

៣. សមិទ្ធផលនិងបញ្ហាប្រឈមនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងរយៈពេល ១០ ឆ្នាំ

៤. ផែនការសកម្មភាព ដំណាក់កាលទី៣

៥. ការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៦. ធនធានហិរញ្ញវត្ថុ

៧. ការគ្រប់គ្រងហានិភ័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

៨. សេចក្តីសន្និដ្ឋាន។

ជាវិធីសាស្ត្រនៃការរៀបចំ ខ្លឹមសារនៃផ្នែកនីមួយៗមិនត្រូវបានរៀបចំជាលក្ខណៈបរិមាធិប្បាយលើគ្រប់ព័ត៌មាននោះទេ គឺគ្រាន់តែរៀបរាប់អំពីខ្លឹមសារគន្លឹះឱ្យមានលក្ខណៈជាលំហូរតក្កភាពនៃគំនិត រីឯខ្លឹមសារលម្អិតមានកំណត់នៅក្នុងឧបសម្ព័ន្ធដែលជាមូលដ្ឋានគតិយុត្តនិងបច្ចេកទេសគាំទ្រដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល។

## ១. ចក្ខុវិស័យ និង យុទ្ធសាស្ត្រ

រាជរដ្ឋាភិបាល បានកំណត់យកកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាអាទិភាពគោលនយោបាយមួយ ក្នុងចំណោមបណ្តាអាទិភាពទាំង ៤ នៃ **បរិស្ថានគ្របដណ្តប់ទី២ “បរិស្ថានម៉ាក្រូសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលមានលក្ខណៈអនុគ្រោះនិងចីរភាពបរិស្ថាន”** នៃយុទ្ធសាស្ត្រចតុកោណដំណាក់កាលទី៣ ដែលរួមមាន ១) ការធានាស្ថិរភាពម៉ាក្រូសេដ្ឋកិច្ចនិងភាពធន់នៃសេដ្ឋកិច្ច ២) គោលនយោបាយម៉ាក្រូសេដ្ឋកិច្ចបុរេសកម្ម ៣) គោលនយោបាយរូបិយវត្ថុ និង ៤) ការបន្តជំរុញអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានចក្ខុវិស័យច្បាស់លាស់ គឺប្រែក្លាយ *ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ឆ្ពោះទៅកាន់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ផ្តោតលើលទ្ធផល ឬ សមិទ្ធកម្ម និងវិមជ្ឈការ ស្របតាមស្តង់ដារនិងឧត្តមានុវត្តន៍អន្តរជាតិ*។

ដើម្បីសម្រេចចក្ខុវិស័យនេះ រាជរដ្ឋាភិបាលបានកំណត់យកតាំងពីចុងឆ្នាំ២០០៤ រហូតមកនូវយុទ្ធសាស្ត្រកែទម្រង់ ***“បោះជំហានជាដំណាក់កាល”*** (Platform Approach) គឺ បោះជំហានថ្មីទៅក្នុងដំណាក់កាលថ្មី ដោយថែរក្សាជំហាន ដែលសម្រេចបានជោគជ័យកន្លងទៅផង ថែមទាំងរៀបចំត្រៀមខ្លួនតម្រង់ឆ្ពោះទៅកាន់ជំហានខាងមុខបន្ទាប់ទៀតផង។ ក្នុងន័យនេះ កិច្ចការ ៣ យ៉ាង ត្រូវបំពេញក្នុងពេលដំណាលគ្នា គឺ÷ ១) ថែរក្សានិងពង្រឹងបន្ថែមនូវសមិទ្ធផលដែលសម្រេចបានក្នុងដំណាក់កាលមុន ២) ស្ថាបនាសមិទ្ធផលដែលត្រូវសម្រេចឱ្យបានក្នុងដំណាក់កាលបច្ចុប្បន្ន និង ៣) រៀបចំត្រៀមខ្លួនកសាងសមិទ្ធផលថ្មីៗ នៅដំណាក់កាលខាងមុខ។

ផ្អែកលើយុទ្ធសាស្ត្រខាងលើ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានគ្រោងទុកថានឹងបញ្ចប់នៅឆ្នាំ២០១៥។ ប៉ុន្តែ បទពិសោធន៍រយៈពេលជាង១០ ឆ្នាំកន្លងទៅ បានបង្ហាញថាកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពិតជាត្រូវការរយៈពេលបន្ថែមទៀត គឺសរុបប្រមាណ ២១ ឆ្នាំ ដោយគ្រោងជាថ្មីថានឹងសម្រេចបញ្ចប់នៅឆ្នាំ២០២៥ ហើយដែលនៅពេលនោះ ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជានឹងត្រូវបានផ្លាស់ប្តូរទាំងស្រុងទៅជាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលផ្តោតលើធាតុចេញ ឬ លទ្ធផល និងវិមជ្ឈការ ស្របតាមស្តង់ដារ និងឧត្តមានុវត្តន៍អន្តរជាតិ។

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ត្រូវបានរៀបចំឡើងជា ៤ ជំហាន និងចែកចេញជា ៤ ដំណាក់កាល និងត្រូវបានដាក់ឱ្យអនុវត្តប្រកបដោយលក្ខណៈគ្រប់ជ្រុងជ្រោយ ភាពជាម្ចាស់ ស្មារតីទទួលខុសត្រូវខ្ពស់ មហិច្ឆតា និងប្រាកដនិយម សម្រាប់រយៈពេលវែង ដូចតទៅ÷

- **ដំណាក់កាលទី ១÷** ការបង្កើនភាពជឿទុកចិត្តនៃថវិកា មានរយៈពេលជាង ៤ឆ្នាំ (២០០៤ - ២០០៨) ដោយសម្រេចបានជោគជ័យនូវមូលដ្ឋានគ្រឹះនៃការពង្រឹងការគ្រប់គ្រងនិងប្រមូលចំណូល ព្រមទាំងការគ្រប់គ្រងសាច់ប្រាក់និងការកែលម្អយន្តការចំណាយ។
- **ដំណាក់កាលទី ២÷** ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ មានរយៈពេល ៦ឆ្នាំ (២០០៩ - ២០១៥) ដោយសម្រេចបានមូលដ្ឋានជាសារវន្តនៃគណនេយ្យភាពហិរញ្ញវត្ថុ ដែលមានជាអាទិ៍ ការដាក់ឱ្យអនុវត្តប្លង់គណនេយ្យថ្មី, មាតិកាថវិកាថ្មី, ថវិកាកម្មវិធី, ផែនការយុទ្ធសាស្ត្រថវិកា, អង្គភាពថវិកា និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- **ដំណាក់កាលទី ៣÷** ការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ ត្រូវបានរំពឹងថានឹងមានរយៈពេល ៥ឆ្នាំ (២០១៦-២០២០) ដើម្បីសម្រេចគោលដៅគន្លឹះនៃការកែទម្រង់ប្រព័ន្ធថវិកាទាំងមូល គឺផ្លាស់ប្តូរពីប្រព័ន្ធគ្រប់គ្រងដែលផ្អែកលើធាតុចូលនិងមជ្ឈការ ឆ្ពោះទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ តាមរយៈការពង្រឹងនិងពង្រីកការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា, ការអនុវត្តថវិកាកម្មវិធី, និងការអនុវត្តអង្គភាពថវិកា ព្រមទាំងការពង្រឹងការរៀបចំគោលនយោបាយ ការព្យាករណ៍ និងការរៀបចំផែនការហិរញ្ញវត្ថុសាធារណៈ។
- **ដំណាក់កាលទី ៤÷** ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម ត្រូវបានរំពឹងថានឹងមានរយៈពេល ៥ឆ្នាំ (២០២១-២០២៥) ដើម្បីសម្រេចបានជាមូលដ្ឋាន នូវគណនេយ្យភាពសមិទ្ធកម្ម ដែលជាលទ្ធផលចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល។

### ជំហានយុទ្ធសាស្ត្រ តាមដំណាក់កាលទាំង ៤ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ




## ២. ក្របខ័ណ្ឌស្ថាប័ន

ដើម្បីសម្រេចបាននូវគោលដៅប្រកបដោយមហិច្ឆតា និង ប្រាកដនិយម នៃកម្មវិធីកែទម្រង់នេះ រាជរដ្ឋាភិបាលកម្ពុជា បានបង្កើតក្របខ័ណ្ឌច្បាស់លាស់ក្នុងការដឹកនាំ គ្រប់គ្រង សម្របសម្រួល សហប្រតិបត្តិការ និងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### ២.១. ក្របខ័ណ្ឌដឹកនាំ

#### ក. គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**គ.ស.ហ.**) ជាសេនាធិការកំពូលរបស់រាជរដ្ឋាភិបាល ដែលមានភារកិច្ចដឹកនាំ រៀបចំ សម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល មានជាអាទិ៍ ការងារពាក់ព័ន្ធនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងការអភិវឌ្ឍវិស័យឯកជន, ព្រមទាំងសម្របសម្រួលរាល់កិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍ ឬការងារកែទម្រង់ក្នុងវិស័យសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល ជាមួយដៃគូអភិវឌ្ឍន៍។

**គ.ស.ហ.** ដឹកនាំដោយឧបនាយករដ្ឋមន្ត្រីមួយរូប និងមានរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាអនុប្រធានប្រចាំការ ទេសាភិបាលធនាគារជាតិនៃកម្ពុជា និងប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឬតំណាង ជាអនុប្រធាន, រដ្ឋមន្ត្រីនៃក្រសួងនានាក្នុងវិស័យសេដ្ឋកិច្ចនិងវិស័យរដ្ឋបាលទូទៅ ជាសមាជិក។

**គ.ស.ហ.** មានសសរស្តម្ភចំនួន ០៣ គឺ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន ។ ***(ឧបសម្ព័ន្ធ ១)***

## ២. គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ជាសារវតារ គណៈកម្មាធិការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ត្រូវបានបង្កើតឡើងដោយប្រកាសលេខ ២១៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ដើម្បីបំពេញភារកិច្ចរៀបចំចក្ខុវិស័យ កម្មវិធី និងផែនការសកម្មភាពនានាសំដៅកែលម្អនិងធ្វើទំនើបកម្មប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈកម្ពុជាទាំងមូល។

គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (**គ.ស.ហ.**) ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ១៣៥ អនក្រ.បក ចុះថ្ងៃទី២១ ខែកញ្ញា ឆ្នាំ២០០៧ និងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចលេខ ៥៦ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ របស់រាជរដ្ឋាភិបាល ដែលបានកែសម្រួលគណៈកម្មាធិការកែទម្រង់ប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ទៅជា “គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃ កសហវ.”។

នៅដើមនីតិកាលទី៥ នៃរដ្ឋសភា រចនាសម្ព័ន្ធនេះត្រូវបានកែសម្រួលជាថ្មី។ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីបំពេញភារកិច្ចដឹកនាំ រៀបចំ សម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ។ ***(ឧបសម្ព័ន្ធ ២)***

### គ. គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងនាមជាស្ថាប័ននាំមុខ ក្នុងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានបង្កើតគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ក.ហ.**) ក្រោមការដឹកនាំរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងមានការចូលរួមពីថ្នាក់ដឹកនាំក្រសួង និងប្រធាននៃគ្រប់អង្គភាពក្រោមឱវាទក្រសួង ជាអនុប្រធាន និងជាសមាជិក។ **គ.ក.ហ.** មានភារកិច្ចសម្របសម្រួលការរៀបចំ ការអនុវត្ត ការតាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅក្នុងក្របខ័ណ្ឌនៃសមត្ថកិច្ចផ្ទាល់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ***(ឧបសម្ព័ន្ធ ៥)***

### ២.២. ក្របខ័ណ្ឌអនុវត្ត

### ក. ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំក្រសួង-ស្ថាប័ន

នៅតាមក្រសួង-ស្ថាប័ន ដែលចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**) ត្រូវបានបង្កើតឡើងនៅក្រោមការដឹកនាំផ្ទាល់របស់ប្រធានស្ថាប័ន ឬ តំណាងនៃក្រសួង-ស្ថាប័ន ០១ រូប ដែលជាសមាជិក **គ.ហ.ស.** ដែលមានមុខតំណែងជារដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ឬ ថ្នាក់ដឹកនាំមួយរូប ដែលជាអ្នកទទួលបន្ទុកនិងជួយប្រធានស្ថាប័នផ្ទាល់លើការងារហិរញ្ញវត្ថុរបស់ក្រសួង-ស្ថាប័ន។ **ក.ហ.ស.** មានភារកិច្ចដឹកនាំនិងសម្របសម្រួលការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់សាមីក្រសួង-ស្ថាប័ន ដោយទំនាក់ទំនងជាមួយ **អ.គ.ហ.**។ ***(ឧបសម្ព័ន្ធ ៤)***

### ខ. ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ចំពោះផ្ទៃក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**) ត្រូវបានបង្កើតឡើង នៅតាមអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋានរបស់ខ្លួន។ **ក.ហ.ស.** មានភារកិច្ចដឹកនាំនិងសម្របសម្រួលការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់សាមីក្រសួង-ស្ថាប័ន ដោយទំនាក់ទំនងជាមួយ **អ.គ.ហ.**។ ***(ឧបសម្ព័ន្ធ ៤)***

## ២.៣. ក្របខ័ណ្ឌសម្របសម្រួល និងសហប្រតិបត្តិការ

### ក. ក្របខ័ណ្ឌសម្របសម្រួលខាងក្រសួង-ស្ថាប័ន : អគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ជាសេនាធិការរបស់ **គ.ហ.ស.** ក្នុងការអនុវត្តកិច្ចការប្រចាំថ្ងៃរបស់ **គ.ហ.ស.** និងសម្របសម្រួលការងារជាមួយ **ក.ហ.ស.** នៃក្រសួង-ស្ថាប័ន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការរវាងរាជរដ្ឋាភិបាល និងដៃគូអភិវឌ្ឍន៍ និងសម្របសម្រួលការងារជាមួយកំណែទម្រង់ផ្សេងទៀតរបស់រាជរដ្ឋាភិបាល។

ទន្ទឹមនេះ **អ.គ.ហ.** ក៏មានតួនាទីផ្តល់ការគាំទ្រជូនក្រសួង ស្ថាប័ន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ទាំងក្នុងការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**អ.គ.ហ.** ដឹកនាំដោយអគ្គលេខាធិការមួយរូប អមដោយអគ្គលេខាធិការរងមួយចំនួនតាមការចាំបាច់។ **អ.គ.ហ.** មានផ្នែកចំនួន ០៧ គឺ ១.ផ្នែកគោលនយោបាយ, ២.ផ្នែកចំណូល, ៣.ផ្នែករៀបចំថវិកា, ៤.ផ្នែកអនុវត្តថវិកា, ៥.ផ្នែកនវានុវត្តន៍និងផ្សព្វផ្សាយ, ៦.ផ្នែកគាំទ្រទូទៅ និងកសាងសមត្ថភាព និង ៧.ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ ដែលផ្នែកនីមួយៗត្រូវទទួលបន្ទុកសម្រប-សម្រួលជាមួយ **ក.ហ.ស.** នៃអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលពាក់ព័ន្ធ និងជាមួយ **ក.ហ.ស.** នៃក្រសួង-ស្ថាប័ន។ ផ្នែកនីមួយៗ ត្រូវដឹកនាំដោយប្រធានមួយរូប និងអនុប្រធានមួយចំនួនជាជំនួយការ។ ***(ឧបសម្ព័ន្ធ ៣ និង ឧបសម្ព័ន្ធ ៦)***

### ខ. ក្របខ័ណ្ឌសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ : ក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PFM-TWG)

ក្រុមការងារបច្ចេកទេសគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលហៅកាត់ថា “**ក.ប.ហ.**” (PFM TWG) ត្រូវបានបង្កើតឡើង ដើម្បីជាយន្តការសម្របសម្រួលការដឹកនាំ ការអនុវត្ត និងត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ **ក.ប.ហ.** មានសមាសភាព ២ ភាគី គឺ **គ.ហ.ស.** ជាតំណាងឱ្យរាជរដ្ឋាភិបាល និងគណៈកម្មាធិការដៃគូអភិវឌ្ឍន៍ (DPC) ជាតំណាងឱ្យក្រុមដៃគូអភិវឌ្ឍន៍។ **ក.ប.ហ.** មានរបបប្រជុំប្រចាំត្រីមាស ដែលត្រូវដឹកនាំដោយប្រធាន **គ.ហ.ស.** ជាមួយនឹងតំណាងក្រុមដៃគូអភិវឌ្ឍន៍ ដោយមានការចូលរួមពី **ក.ហ.ស.** នៃ

គ្រប់ក្រសួង ស្ថាប័ន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ កិច្ចប្រជុំ **គ.ប.ហ.** គឺជាវេទិកាសម្រាប់ពិភាក្សាលើការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រចាំត្រីមាស និងប្រចាំឆ្នាំ និងការងារពាក់ព័ន្ធផ្សេងទៀតនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទន្ទឹមនេះ គណៈកម្មាធិការដៃគូអភិវឌ្ឍន៍ មានតួនាទីសម្របសម្រួលនិងផ្តល់ការគាំទ្រដល់ **គ.ហ.ស.** ជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ ក្នុងកិច្ចការនានា ជាអាទិ៍ ការចូលរួមផ្តល់អនុសាសន៍លើការរៀបចំផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ និងការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ គណៈកម្មាធិការដៃគូអភិវឌ្ឍន៍ មានលេខាធិការដ្ឋានមួយជាសេនាធិការ ដើម្បីជួយសម្របសម្រួលនិងអនុវត្តការងាររបស់គណៈកម្មាធិការដៃគូអភិវឌ្ឍន៍រវាង **គ.ហ.ស.** និងដៃគូអភិវឌ្ឍន៍ផ្សេងទៀត។

## គ. ក្របខ័ណ្ឌសម្របសម្រួលរវាងកំណែទម្រង់ទាំងបី: កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ផ្តោតសំខាន់លើការកែលម្អប្រព័ន្ធគ្រប់គ្រងថវិការបស់ក្រសួង-ស្ថាប័នទាំងអស់នៃព្រះរាជាណាចក្រកម្ពុជា ព្រមទាំងមានទំនាក់ទំនងយ៉ាងជិតស្និទ្ធជាមួយនឹងការងារកែទម្រង់ផ្សេងទៀតផងដែរ ជាពិសេស កម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ។ ដើម្បីធានាសង្គតិភាព ភាពប្រទាក់ក្រឡា និងសុខដុមនីយកម្មរវាងការកែទម្រង់ទាំងបី, យន្តការសម្របសម្រួលមួយ ត្រូវបានបង្កើតឡើងដោយសេចក្តីសម្រេចរួមលេខ ០០៦ សហវ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ដោយផ្សារភ្ជាប់ទំនាក់ទំនងរវាងលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់ទាំង៣។ លេខាធិការដ្ឋានទាំងបី មានរបបប្រជុំប្រចាំត្រីមាស តាមការដឹកនាំជាលក្ខណៈប្តូរវេន ដើម្បីពិនិត្យ សម្របសម្រួល និងលើកសំណើដំណោះស្រាយបញ្ហាប្រទាក់ក្រឡារវាងកម្មវិធីកែទម្រង់ទាំងបី។ ***(ឧបសម្ព័ន្ធ ៧)***

## ក្របខ័ណ្ឌស្ថាប័ននៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



## ៣. សមិទ្ធផលនិងបញ្ហាប្រឈម នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងរយៈពេល ១០ ឆ្នាំ

ក្នុងរយៈពេល ១០ ឆ្នាំកន្លងមកនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានអនុវត្តដោយសម្រេចបានជោគជ័យ លើជំហានទី១ ក្នុងដំណាក់កាលទី១ "ភាពជឿទុកចិត្តបាននៃថវិកា" នាឆ្នាំ២០០៨ និងបានសម្រេចឈានចូលដល់ជំហានទី២ ក្នុងដំណាក់កាលទី២ "គណនេយ្យភាពហិរញ្ញវត្ថុ" នាឆ្នាំ២០០៩ និងត្រូវបញ្ចប់នាដំណាច់ឆ្នាំ២០១៥។

### ៣.១. ដំណាក់កាលទី១ (២០០៤-២០០៨)

ដំណាក់កាលទី១ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានតួនាទីជាតួអង្គស្នូល ដើម្បីសម្រេចបាននូវគោលដៅគន្លឹះ គឺ ការកសាងថវិកាដែលអាចជឿទុកចិត្តបាន ដែលជាថវិកាគ្រប់គ្រាន់ តាមការគ្រោងទុក មានចីរភាព និងអាចព្យាករណ៍បាន។ នៅក្នុងដំណាក់កាលនេះ ពុំទាន់មានការចូលរួមពីក្រសួង-ស្ថាប័ន នៅឡើយទេ។

ផែនការសកម្មភាព ដំណាក់កាលទី១ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មាន ៣ ផ្នែក ដែលរួមមាន (១) សកម្មភាពការងារចាំបាច់សម្រាប់បំពេញក្នុងជំហានទី១ (២) សកម្មភាពការងារសម្រាប់ជំហានបន្ទាប់ ដែលត្រូវចាប់ផ្តើមនៅក្នុងដំណាក់កាលទី១ និង (៣) សកម្មភាពការងារសម្រាប់អនុវត្តវិធានការកែលម្អរចនាសម្ព័ន្ធ និងពង្រឹងសមត្ថភាពស្ថាប័ន និងមានចង្កោមសកម្មភាពចំនួន៣៣។

ដំណាក់កាលទី១ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រេចបានសមិទ្ធផលទន្ទឹមនឹងត្រូវដោះស្រាយបញ្ហាប្រឈម ដូចខាងក្រោម÷

#### ក. សមិទ្ធផល

ក្នុងជំហានទី១ ដំណាក់កាលទី១ នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ "**ស្ថានភាពខ្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ**" ត្រូវបានផ្លាស់ប្តូរ មកជាសម្រេចបាន "**អតិរេកសាច់ប្រាក់**" ជាបន្តបន្ទាប់។ ការពង្រឹងការគ្រប់គ្រងនិងការប្រមូលចំណូល បានធ្វើឱ្យចំណូលមានកំណើនជាមធ្យម ២៦% ក្នុងមួយឆ្នាំ។ ការលុបបំបាត់បំណុលកកស្ទះនៅរតនាគារជាតិ ការបង្កើតអង្គភាពសវនកម្មផ្ទៃក្នុងនៅតាមក្រសួង-ស្ថាប័ន ការកាត់បន្ថយនីតិវិធីចំណាយ ការពង្រីកការប្រើប្រាស់ប្រព័ន្ធធនាគារ

(រដ្ឋនិងឯកជន) ជាលទ្ធផលដ៏គួរឱ្យកត់សម្គាល់ ដែលរាជរដ្ឋាភិបាលកម្ពុជាសម្រេចបាន។ ការផ្លាស់ប្តូរបាននូវស្ថានភាពខ្វះសាច់ប្រាក់ដ៏រ៉ាំរ៉ៃ មកជា ស្ថានភាពមានអតិរេកសាច់ប្រាក់នេះ បានអនុញ្ញាតឱ្យការបើកបៀវត្សជូនមន្ត្រីរាជការគ្រប់ប្រភេទនិងគ្រប់លំដាប់ថ្នាក់ ត្រូវបានធ្វើឡើងទាន់ពេលវេលា ថែមទាំងអាចបង្កើនបៀវត្សជារៀងរាល់ឆ្នាំជូនគ្រូបង្រៀន មន្ត្រីរាជការ និងកងកម្លាំងប្រដាប់អាវុធគ្រប់ប្រភេទទៀតផង។ លើសពីនេះ រាជរដ្ឋាភិបាលមានលទ្ធភាពបង្កើនទុនវិនិយោគសាធារណៈលើការកសាងហេដ្ឋារចនាសម្ព័ន្ធសង្គមនិងសេដ្ឋកិច្ច ការពង្រឹងនិងពង្រីកសេវាសាធារណៈ និងការដោះស្រាយផលវិបាកដែលកើតចេញពីគ្រោះធម្មជាតិ។

សមិទ្ធផលទាំងនេះបានមកពីការសម្រេចបាននូវវិធានការកែទម្រង់ដែលត្រូវបានដាក់ចេញតាំងពីកម្រិតគោលនយោបាយ កម្រិតគ្រប់គ្រង រហូតដល់កម្រិតប្រតិបត្តិការបច្ចេកទេស ដែលមានកម្មវត្ថុពង្រឹងការប្រមូលចំណូលនិងការអនុវត្តចំណាយសាធារណៈ ប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព។

ខាងផ្នែកចំណូល កិច្ចការដ៏សំខាន់មួយដែលរាជរដ្ឋាភិបាលសម្រេចបាន គឺ ការធ្វើឱ្យ**លទ្ធផលជាក់ស្តែងនៃការប្រមូលចំណូល កាន់តែខិតទៅរកច្បាប់ថវិកាដែលត្រូវបានអនុម័ត**។ ក្នុងរយៈកាលកន្លងមក បញ្ហាស្ថិតត្រង់ ការព្យាករណ៍អំពីចំណូលដែលអាចប្រមូលបាន ត្រូវបានកម្រិតទាបពេកដែលធ្វើឱ្យមានគម្លាតខ្លាំងពីលទ្ធផលជាក់ស្តែង។ ទោះបីជាយ៉ាងណា បញ្ហានៃការព្យាករណ៍ចំណូលនៅតែត្រូវបន្តពង្រឹងបន្ថែម ជាការងាររយៈពេលវែង តាមរយៈការរៀបចំគោលនយោបាយចំណូលរយៈពេលមធ្យម ការកែលម្អវិធីសាស្ត្រព្យាករណ៍ចំណូល និងការបង្កើនកិច្ចសម្របសម្រួល ព្រមទាំងកិច្ចសហការរវាងគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ទាំងលើចំណូលសារពើពន្ធ និងចំណូលមិនមែនសារពើពន្ធ។ ទន្ទឹមនេះ ទោះបីជាលទ្ធផលចុងឆ្នាំនីមួយៗនៃការប្រមូលចំណូលសរុប បានបង្ហាញអំពីគម្លាតលើសពី១០% នៃច្បាប់ថវិកាដែលបានកំណត់ ក៏ប៉ុន្តែ លទ្ធផលនេះក៏បានឆ្លុះបញ្ចាំងជារួមអំពីកំណើននៃទិន្នផលចំណូល ដែលជាលទ្ធផលវិជ្ជមានមួយ។ ជាទិន្នន័យជាក់ស្តែង ពីឆ្នាំ ២០០១-២០០៣ ការប្រមូលពន្ធផ្ទាល់ មានកំណើន ៣ % រីឯការប្រមូលពន្ធប្រយោលមានកំណើនតែ៩% ប៉ុណ្ណោះ ក៏ប៉ុន្តែ ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៧ ការប្រមូលពន្ធផ្ទាល់មានកំណើន ៣៩,៤% ចំណែកឯការប្រមូលពន្ធប្រយោលមានកំណើន រហូតដល់២៨,៣%។ កំណើននៃទិន្នផលចំណូលសារពើពន្ធនេះ កើតចេញពីការកែលម្អលើផ្នែកគោលនយោបាយសារពើពន្ធ, ការពង្រឹងរដ្ឋបាលសារពើពន្ធ, ការពង្រឹងប្រព័ន្ធប្រមូលចំណូល, ការពង្រីកមូលដ្ឋាន

សារពើពន្ធឱ្យកាន់តែទូលាយ និងការពង្រឹងការរៀបចំក្របខ័ណ្ឌគតិយុត្ត ព្រមទាំងការពង្រឹងការអនុវត្តច្បាប់។ ដោយឡែក សម្រាប់ផ្នែកចំណូលមិនមែនសារពើពន្ធវិញ កំណើនពិតប្រចាំឆ្នាំ២០០៤ មានត្រឹម ១២% តែប៉ុណ្ណោះ និងពីឆ្នាំ២០០៥ ដល់ ឆ្នាំ២០០៧ មានកំណើន ជាមធ្យម ១៦,៩%។

ខាងផ្នែកចំណាយ រាជរដ្ឋាភិបាលកម្ពុជា បានដាក់ចេញនូវក្របខ័ណ្ឌគតិយុត្ត វិធាន និងនីតិវិធី ដើម្បីពង្រឹងប្រសិទ្ធភាព ស័ក្តិសិទ្ធភាព និងភាពសន្សំសំចៃនៃថវិការដ្ឋ ទាំងក្នុងចំណាយបន្ទុកបុគ្គលិក និងចំណាយក្រៅពីបន្ទុកបុគ្គលិក។ សម្រាប់ចំណាយក្រៅបន្ទុកបុគ្គលិក ចំណាយតាមនីតិវិធីនៃកិច្ចលទ្ធកម្ម មានទំហំធំ ដែលត្រូវយកចិត្តទុកដាក់។ ដើម្បីពង្រឹងប្រសិទ្ធភាពចំណាយក្នុងកិច្ចលទ្ធកម្ម អនុក្រឹត្យលេខ ១០៥ អនក្រ.បក ចុះថ្ងៃទី១៨ ខែតុលា ឆ្នាំ២០០៦ ស្តីពីលទ្ធកម្មសាធារណៈ និង ប្រកាសលេខ ០៤៥ ស្តីពីវិមជ្ឈការលទ្ធកម្ម ត្រូវបានដាក់ឱ្យអនុវត្ត សំដៅរៀបចំប្រព័ន្ធ វិធាន និងនីតិវិធីនៃកិច្ចលទ្ធកម្ម តាំងពីដំណាក់កាលផ្សព្វផ្សាយ ដំណាក់កាលដេញថ្លៃរហូតដល់ដំណាក់កាលប្រគល់-ទទួល និងដំណាក់កាលត្រួតពិនិត្យតាមដានក្រោយការអនុវត្តកិច្ចលទ្ធកម្ម។ ផែនការលទ្ធកម្មត្រូវបានដាក់ឱ្យដំណើរការ, សៀវភៅណែនាំស្តីពីលទ្ធកម្មត្រូវបានចេញផ្សាយនៅថ្ងៃទី២៣ ខែមករា ឆ្នាំ២០០៧ និងបានបន្តរៀបចំច្បាប់ស្តីពីលទ្ធកម្មសាធារណៈ។ ដោយឡែក ចំណាយលើបុគ្គលិកត្រូវបានធ្វើវិចារណកម្មតាមរយៈការរៀបចំគម្រោងចំណាយដោយផ្អែកលើតារាងបៀវត្សដែលមានសុក្រឹតភាព។ សំណើជ្រើសរើសមន្ត្រីថ្មី, ការផ្លាស់ប្តូរតំណែង ការបង្កើននិងការកាត់បន្ថយចំនួនមន្ត្រីនៃគ្រប់ក្រសួង-ស្ថាប័ន ត្រូវបានរៀបចំនិងបូកសរុបឱ្យមានសង្គតិភាពនិងសុខដុមភាព តាមរយៈយន្តការការងារច្បាស់លាស់រវាងរដ្ឋលេខាធិការដ្ឋានមុខងារសាធារណៈ (បច្ចុប្បន្ន ជាក្រសួងមុខងារសាធារណៈ) ជាមួយក្រុមប្រឹក្សាកែទម្រង់រដ្ឋបាលសាធារណៈ និងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។ ទន្ទឹមនេះ សំណើសុំឥណទានថវិកាបន្ថែមរបស់ក្រសួង-ស្ថាប័ន ត្រូវបានពិចារណាយ៉ាងល្អិតល្អន់ដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្អែកលើគោលការណ៍ផ្សារភ្ជាប់អាទិភាពការងារ ជាមួយនឹងលទ្ធភាពថវិកានិងប្រភពហិរញ្ញប្បទានរបស់រាជរដ្ឋាភិបាល។ ក្នុងន័យនេះ ការផ្តល់នូវឥណទានបន្ថែមជូនក្រសួង-ស្ថាប័ន ត្រូវផ្អែកលើលទ្ធភាពនៃទុនបម្រុងរបស់រាជរដ្ឋាភិបាល និងប្រភពហិរញ្ញប្បទានផ្សេងទៀតដែលមាន។ ការកែលម្អគោលនយោបាយចំណាយនិងការពង្រឹងការអនុវត្តចំណាយទាំងនេះ បានធ្វើឱ្យគម្លាតរវាងចំណាយជាក់ស្តែងសរុបទាំងបៀវត្សនិងមិនមែនបៀវត្ស ជាមួយនឹងគម្រោងចំណាយក្នុងច្បាប់ថវិកាប្រចាំឆ្នាំ កាន់តែរួមតូច។ នៅចុងឆ្នាំ២០០៧ ចំណាយជាក់ស្តែងលើបៀវត្សមាន ៩២%, ចំណាយលើទំនិញនិងសេវា

មាន ១០៤% និងចំណាយមូលធនមាន ៨៦% ធៀបនឹងច្បាប់ថវិកាប្រចាំឆ្នាំ។ លទ្ធផលនេះ សបញ្ជាក់ថាការរៀបចំនិងការអនុវត្តផែនការថវិកាកាន់តែមានតុល្យភាពនឹងគ្នា ហើយលទ្ធផលនឹងកាន់តែប្រសើរជាងនេះ នៅពេលដែលថវិកាកម្មវិធី ត្រូវបានអនុវត្ត។

បើពិនិត្យលើវដ្តនៃថវិកា ដំណាក់កាលទាំងបី គឺការរៀបចំថវិកា ការអនុវត្តថវិកា និងការតាមដានវាយតម្លៃលទ្ធផល ត្រូវបានកែលម្អជាបណ្តើរៗ។

ការរៀបចំថវិកាមានការកែលម្អ គួរឱ្យកត់សម្គាល់ នោះគឺការតម្រូវឱ្យក្រសួង-ស្ថាប័ន រៀបចំ "**ផែនការយុទ្ធសាស្ត្រថវិកា**" ដែលជាផែនការថវិការយៈពេល ៣ ឆ្នាំ រំកិល និងការដាក់ឱ្យអនុវត្តនូវ "**មាតិកាសេដ្ឋកិច្ចថ្មី**"។ ព្រមជាមួយគ្នានេះ ដើម្បីធានាគោលការណ៍តម្លាភាព ថវិកាសង្ខេបត្រូវបានរៀបចំនិងផ្សព្វផ្សាយជាសាធារណៈ នៅឆ្នាំ២០០៧។ កិច្ចការទាំងនេះ ត្រូវបានចាប់ផ្តើមអនុវត្តសាកល្បង ចាប់ពីឆ្នាំ២០០៧ តទៅ ពោលគឺមុនការកំណត់ដោយច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានប្រកាសឱ្យប្រើដោយព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨។

សម្រាប់ការពង្រឹងការអនុវត្តថវិកា ក្នុងដំណាក់កាលទី១នៃការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គណនីទោលរតនាគារជាតិត្រូវបានបង្កើតឡើង ដែលជាការប្រមូលផ្តុំគណនីទាំងអស់របស់រាជរដ្ឋាភិបាល។ ប្រព័ន្ធទិន្នន័យដែលអាចកត់ត្រានិងតាមដានហិរញ្ញប្បទានពីខាងក្រៅ ត្រូវបានបង្កើតនិងកែលម្អជាបន្តបន្ទាប់ ទន្ទឹមនឹងចំណូល-ចំណាយដែលមិនឆ្លងកាត់រតនាគារជាតិ ត្រូវបានត្រួតពិនិត្យជាប្រចាំ។ ដោយឡែក លទ្ធផលសម្រេចបានមួយចំនួន បានធ្វើឱ្យអាណាប័កកាន់តែមានលទ្ធភាពបញ្ជាចំណាយ ស្របទៅតាមការព្យាករណ៍ថវិកា និងលំហូរសាច់ប្រាក់ តាមរយៈការព្យាករណ៍លំហូរសាច់ប្រាក់ប្រចាំឆ្នាំ, ការដាក់ឱ្យអនុវត្តនូវកម្មវិធីចំណូលចំណាយប្រចាំត្រីមាសដែលបានក្លាយជាការងារប្រចាំថ្ងៃ, ការបង្កើតអង្គភាពគ្រប់គ្រងសាច់ប្រាក់, ការកាត់បន្ថយនីតិវិធីចំណាយ និងការកាត់បន្ថយចំនួនបំណុលកកស្ទះជាបណ្តើរៗ ព្រមទាំងការសម្រេចបាននូវការបំបាត់បំណុលកកស្ទះថ្មី។ លទ្ធផលគួរឱ្យកត់សម្គាល់មួយទៀត គឺការកើនឡើងនៃការប្រើប្រាស់ប្រព័ន្ធធនាគារសម្រាប់ប្រតិបត្តិការថវិការដ្ឋ ក្នុងនោះ នៅឆ្នាំ២០០៧ ការទូទាត់ទៅឥណទាយកនិងមន្ត្រីរាជការតាមប្រព័ន្ធធនាគារបានកើនឡើងរហូតដល់ ៧២,៥% បើប្រៀបធៀបនឹងឆ្នាំ២០០៤ ដែលមានតិចជាង ៥% នៃការទូទាត់ ស្របពេលដែលការប្រមូលចំណូលសារពើពន្ធតាមធនាគារបានកើនពី២% នៅឆ្នាំ២០០៤ ទៅដល់ ៩២% នៅឆ្នាំ២០០៧។

ជាចុងក្រោយ សម្រាប់ការតាមដានត្រួតពិនិត្យនិងវាយតម្លៃលទ្ធផលនៃការអនុវត្តថវិកាវិញ លទ្ធផលដ៏លេចធ្លោ គឺការពង្រឹងនិងពង្រីកការងារសវនកម្មផ្ទៃក្នុងនៅតាមក្រសួង-ស្ថាប័ន ដែលលទ្ធផលជាក់ស្តែង មានក្រសួង-ស្ថាប័ន ចំនួន ២៣ បានបង្កើតអង្គភាពសវនកម្មផ្ទៃក្នុង ដែលក្នុងនោះ ១១ ក្រសួងបានដំណើរការ។

## ខ. បញ្ហាប្រឈម

ទន្ទឹមនឹងវឌ្ឍនភាព ដែលបានរៀបរាប់ខាងលើ ជំហានទី១ នៃការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានជួបប្រទះបញ្ហាប្រឈម ដែលមានជាអាទិ៍ ដូចតទៅ÷

- ការយល់ដឹង ការទទួលស្គាល់អំពីភាពចាំបាច់ ការចេះដឹងអំពីទស្សនវិស័យ និងការចូលរួមអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយសាធារណជន គ្រប់ស្រទាប់ជាន់ថ្នាក់ និងមន្ត្រីរាជការ គ្រប់លំដាប់ថ្នាក់ នៅមានកម្រិត។
- ទស្សនាទាននៃការងារកែទម្រង់នៅពុំទាន់មានការឯកភាពគ្នាទាំងស្រុងនៅឡើយ ក្នុងចំណោមតួអង្គពាក់ព័ន្ធ។
- សមាហរណកម្មរវាងថវិកាចរន្តនិងថវិកាមូលធន នៅតែចោទមានបញ្ហា ដែលមិនទាន់មានដំណោះស្រាយជាក់លាក់នៅឡើយ។
- កិច្ចសហការ និងកិច្ចសម្របសម្រួលអន្តរស្ថាប័ន នៅពុំទាន់អាចធានាបានប្រកបដោយប្រសិទ្ធភាពនៅឡើយ។
- សមត្ថភាពធនធានមនុស្សនៃរដ្ឋបាលសាធារណៈ ដែលចាំបាច់សម្រាប់គាំទ្រកិច្ចដំណើរការនៃការងារកែទម្រង់ នៅពុំទាន់សមស្របនៅឡើយ ទាំងបរិមាណ និងគុណភាព។
- មន្ត្រីរាជការ និងស្ថាប័ន ពុំទាន់ទទួលបាននូវការលើកទឹកចិត្តសមស្របនៅឡើយ ក្នុងការធានាកិច្ចដំណើរការនៃការអនុវត្តការងារកែទម្រង់។
- ភាពជាម្ចាស់លើការងារកែទម្រង់ នៅមានកម្រិត។

## ៣.២. ដំណាក់កាលទី២ (២០០៩-២០១៥)

ជំហានទី២ “គណនេយ្យភាពហិរញ្ញវត្ថុ” ត្រូវបានដាក់ឱ្យអនុវត្តនៅដំណាក់កាលទី២ ដែលមានរយៈពេល ៣ ឆ្នាំ (២០០៨-២០១០) ជាមួយនឹងផែនការសកម្មភាពរួម ដំណាក់កាលទី២ ដែលចែកចេញជា ១៤គោលបំណង និង ៧៣ចង្កោមសកម្មភាព។ ដំណាក់កាលទី២នេះ បានប្រព្រឹត្ត

ទៅដោយឆ្លងកាត់បញ្ហាប្រឈមដ៏ស្រួចស្រាល់ជាច្រើន ដែលតម្រូវឱ្យមានការកែសម្រួលលំដាប់អាទិភាពនៃស្ទូចនាករសមិទ្ធកម្មគន្លឹះឡើងវិញ។ ក្នុងដំណើរការនេះ យុទ្ធសាស្ត្រ ៣ + ២ ត្រូវបានដាក់ឱ្យអនុវត្ត ពីឆ្នាំ២០១១ ដល់ ឆ្នាំ២០១៣ ដើម្បីជំរុញប្រសិទ្ធភាពនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមប្រព័ន្ធព័ត៌មានវិទ្យា (Financial Management Information System "FMIS")។ បន្ទាប់មកទៀត ផែនការសកម្មភាពរួម ដំណាក់កាលទី២ បច្ចុប្បន្នកម្ម ឬ ថ្មី ត្រូវបានរៀបចំ ដោយផ្អែកលើការកែសម្រួលផែនការសកម្មភាពរួម ដំណាក់កាលទី២ និងយុទ្ធសាស្ត្រ ៣ + ២ ព្រមទាំងសម្រេចដាក់ឱ្យអនុវត្តពីឆ្នាំ២០១៤ ដល់ឆ្នាំ២០១៥។ ផែនការសកម្មភាពរួម ដំណាក់កាលទី២ បច្ចុប្បន្នកម្ម ឬ ថ្មី ចែកចេញជា ៤ ផ្នែក, ១៦ គោលបំណង និង ៦២ចង្កោមសកម្មភាព។ ដំណាក់កាលទី២ នឹងត្រូវបញ្ចប់នៅដំណាច់ឆ្នាំ២០១៥ ទន្ទឹមនឹងការបោះជំហានជាបណ្តើរៗ ទៅកាន់ដំណាក់កាលទី៣ នាដើមឆ្នាំ២០១៦ ជាមួយនឹងសមិទ្ធផល និងបញ្ហាប្រឈម ដូចខាងក្រោម÷

### ក. សមិទ្ធផល

ចំពោះជំហានទី១ "ភាពជឿទុកចិត្តនៃថវិកា" ត្រូវបានបន្តពង្រឹងនិងកែលម្អជាច្រើនបន្ថែមទៀត។ ជាក់ស្តែង លទ្ធផលចំណូលក្នុងស្រុកសរុប កាន់តែខិតទៅរកគោលដៅ ដែលបានអនុម័តនៅក្នុងច្បាប់ហិរញ្ញវត្ថុ គឺ គោលដៅ កម្រិតលម្អៀង ៥ % ដោយទទួលបានលទ្ធផល ១១០,៧% សម្រាប់ការអនុវត្តនៅក្នុងឆ្នាំ២០១៤ (ជាពិសេសតាមរយៈការកែទម្រង់រដ្ឋបាលគយ និងពន្ធដារ)។ បំណុលកកស្ទះ ត្រូវបានកម្រិតមិនឱ្យមានលើសពី ២% នៃចំណាយសរុប ទន្ទឹមនឹងរយៈពេលនៃការទូទាត់អាណត្តិបើកប្រាក់ ត្រូវបានកំណត់ដោយ **គ.ហ.ស.** មិនឱ្យលើសពី ៦០ថ្ងៃ នៃថ្ងៃធ្វើការគិតចាប់ពីថ្ងៃដែលអាណត្តិបើកប្រាក់បានទៅដល់រតនាគារជាតិ។ លទ្ធភាពបញ្ចូលចំណាយទៅតាមកម្មវិធីចំណាយនិងផែនការសាច់ប្រាក់កាន់តែមានភាពរលូនតាមគោលដៅកំណត់ ទន្ទឹមនឹងចំណាយតាមប្រភេទកាន់តែខិតទៅរកថវិកាដែលបានអនុម័ត។ រីឯទិន្នផលចំណូលលើមូលដ្ឋានពន្ធ ត្រូវបានកំណត់ឱ្យមានកំណើន ០.៥% នៃ ផសស ក្នុងមួយឆ្នាំ (ដោយសម្រេចបាន ១៥,១៦ % នៃ ផសស នៅឆ្នាំ២០១៣ និងសម្រេចបាន១៦,៦១% នៃ ផសស នៅឆ្នាំ២០១៤)។

ចំពោះជំហានទី២ "ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ" មានការកែលម្អជាច្រើនលើនីតិវិធីអនុវត្តថវិកា មាតិកាថវិកាថ្មីនិងប្លង់គណនេយ្យថ្មី ត្រូវបានរៀបចំ និងដាក់ឱ្យអនុវត្ត។ ចំណាត់ថ្នាក់ថវិកា តាមមុខងារ, ប្រភពធនធាន និងគម្រោង ត្រូវបានសិក្សានិងរៀបចំត្រៀមដាក់ឱ្យអនុវត្ត។

ជាពិសេស ប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដំណាក់កាលទី១ ត្រូវបានដាក់ឱ្យដំណើរការកាលពីថ្ងៃទី២០ ខែកក្កដា ឆ្នាំ២០១៥ សម្រាប់មុខងារវិភាជន៍ថវិកា (Budget Allocation) និងមុខងារសៀវភៅធំ (General Ledger) នៅក្នុងអគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានរតនាគារជាតិ។ ក្រុមការងារគ្រប់គ្រងគម្រោងព័ត៌មានវិទ្យាគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈក៏បានបញ្ចប់ការរៀបចំកសាងប្រព័ន្ធលើមុខងារទាំង៦ ដែលរួមមាន ការវិភាជថវិកា (Budget allocation), សៀវភៅធំ (General Ledger), ការត្រួតពិនិត្យធានាចំណាយ (Commitment Control), គណនីដែលត្រូវសង (Account Payable), គណនីដែលត្រូវទារ (Account Receivable) និងការគ្រប់គ្រងសាច់ប្រាក់ (Cash Management) ដោយបានដាក់ឱ្យប្រើប្រាស់សាកល្បងរួចហើយនៅក្នុងអគ្គនាយកដ្ឋានថវិកា អគ្គនាយកដ្ឋានរតនាគារជាតិ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ អគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងអគ្គាធិការដ្ឋាន។

ចំពោះជំហានទី៣ "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានដាក់ឱ្យអនុវត្តនៅក្នុងគ្រប់ក្រសួង-ស្ថាប័ន; រីឯថវិកាកម្មវិធីនិងអង្គភាពថវិកាត្រូវបានដាក់ឱ្យអនុវត្តពេញលេញជាបណ្តើរៗ នៅឆ្នាំ២០១៥ សម្រាប់ក្រសួងចំនួន ១០, នៅឆ្នាំ២០១៦ សម្រាប់ក្រសួង-ស្ថាប័ន ចំនួន ២៥, នៅឆ្នាំ២០១៧ សម្រាប់ក្រសួង-ស្ថាប័ន ចំនួន ១១ រហូតដល់ឆ្នាំ២០១៨ គ្រប់ក្រសួង-ស្ថាប័ននឹងត្រូវអនុវត្តថវិកាកម្មវិធីនិងអង្គភាពថវិកា ស្របតាមទិសដៅយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកាកម្ពុជា ឆ្នាំ២០១៣-២០២០។ លើសពីនេះ សម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ ការរៀបចំគោលការណ៍ណែនាំស្តីពីការរៀបចំផែនការយុទ្ធសាស្ត្រថវិកា និងការរៀបចំថវិកាកម្មវិធី ក៏កំពុងត្រូវបានរៀបចំនិងត្រៀមដាក់ឱ្យអនុវត្តជាជំហានៗផងដែរ។

## ខ. បញ្ហាប្រឈម

ទន្ទឹមនឹងវឌ្ឍនភាពដែលបានរៀបរាប់ខាងលើ ដំណាក់កាលទី២នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានជួបប្រទះបញ្ហាប្រឈម ជាសារវន្ត ដូចតទៅ÷

- កម្រិតដឹកនាំ ÷ ការកំណត់គោលនយោបាយ គោលការណ៍ ឬ ការផ្តល់ទិសដៅ នៅមិនទាន់ច្បាស់លាស់។
- កម្រិតគ្រប់គ្រង ÷ ការរៀបចំ ការអនុវត្ត និងការត្រួតពិនិត្យតាមដានលើការអនុវត្តសកម្មភាព នៅពុំទាន់មានភាពរលូននៅឡើយ។ ជាពិសេស ការងារកែទម្រង់ និងការងារប្រចាំថ្ងៃ នៅ

មិនទាន់ត្រូវបានយល់ច្បាស់ដោយថ្នាក់ដឹកនាំ និង មន្ត្រីរាជការនៅក្នុងក្រសួង-ស្ថាប័នមួយចំនួននៅឡើយ។ បញ្ហាប្រឈមក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ មិនត្រូវបានកំណត់ច្បាស់លាស់ រីឯដំណោះស្រាយដែលត្រូវបានដាក់ចេញ ក៏នៅមិនទាន់អាចធានានូវការបញ្ចប់បញ្ហាប្រឈមប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៅឡើយ។ លើសពីនេះ ការចាត់តាំងមន្ត្រីពុំទាន់បានសមស្របទាំងស្រុងតាមសមត្ថភាព រីឯមន្ត្រីមួយចំនួនក៏ពុំទាន់មានសមត្ថភាពសមស្របតាមមុខងាររបស់ខ្លួន។

- កម្រិតបច្ចេកទេស ÷ ក្រសួង-ស្ថាប័នមួយចំនួនធំយល់ដឹងអំពីមុខងារ ភារកិច្ច និងសកម្មភាពរបស់ខ្លួនបានច្បាស់លាស់ តែបែរជាមានការខ្វះខាតជំនាញសម្រាប់ប្រតិបត្តិ។ សម្រាប់ក្រសួង ស្ថាប័នមួយចំនួនផ្សេងទៀត ជំនួយបច្ចេកទេសត្រូវបានផ្តល់ជូន តែការប្រើប្រាស់ជំនួយបច្ចេកទេស បែរជាមិនមានប្រសិទ្ធភាពទៅវិញ។
- កម្រិតរដ្ឋបាល និងសម្របសម្រួល ÷ កិច្ចសហការនិងកិច្ចសម្របសម្រួលផ្ទៃក្នុងក្រសួង-ស្ថាប័ននៅមានកម្រិតខ្លាំងនៅឡើយ នៅក្នុងការអនុវត្តដំណាក់កាលទី២នេះ។ បញ្ហានេះមានប្រភពមកពីកង្វះឆន្ទៈរបស់ថ្នាក់ដឹកនាំ, ការមិនផ្តល់អាទិភាពលើការងារកែទម្រង់ និងកង្វះភាពជាម្ចាស់របស់ថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ៤. ផែនការសកម្មភាព ដំណាក់កាលទី៣

សេចក្តីព្រាងផែនការសកម្មភាព ដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានរៀបចំជាដំបូងដោយ **អ.គ.ហ.** នៅដើមឆ្នាំ២០១៥ និងត្រូវបានពិនិត្យ ពិភាក្សា និងផ្តល់មតិយោបល់ដោយក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្នុងកិច្ចប្រជុំកម្រិតមន្ត្រីជំនាញ, កិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងត្រូវបានដាក់ឱ្យពិនិត្យនិងពិគ្រោះយោបល់ទូលំទូលាយលើខ្លឹមសារលម្អិតក្នុងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ២០១៤ លើកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាលពីខែឧសភា ឆ្នាំ២០១៤ និងសិក្ខាសាលាស្តីពីការបង្កើនភាពជាម្ចាស់លើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ កាលពីចុងខែកញ្ញា ឆ្នាំ២០១៥។

លើសពីនេះ **អ.គ.ហ.** បានប្រើប្រាស់នូវធាតុចូលដែលត្រូវបានរកឃើញនៅក្នុងរបាយការណ៍វាយតម្លៃអំពីប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់កម្ពុជា ឆ្នាំ២០១៩ ផ្អែកលើក្របខ័ណ្ឌចំណាយសាធារណៈនិងគណនេយ្យភាពហិរញ្ញវត្ថុ (Public Expenditure and Financial Accountability-PEFA) ដោយពិនិត្យនិងពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធ សម្រាប់ការរៀបចំក្របខ័ណ្ឌផែនការសកម្មភាព ដំណាក់កាលទី៣ នេះ។ អនុសាសន៍គន្លឹះសម្រាប់សូចនាករនីមួយៗ នៃរបាយការណ៍ PEFA នេះ មានភ្ជាប់ជាឧបសម្ព័ន្ធនៃឯកសារនេះ ***(ឧបសម្ព័ន្ធ ១២)***។

ផែនការសកម្មភាព ដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចែកចេញជា ៥ ផ្នែក, ២១ គោលបំណង និង ៦៧ ចង្កោមសកម្មភាព ដែលមានខ្លឹមសារជាសារវន្តតាមផ្នែកនីមួយៗ ដូចខាងក្រោម÷

## ផ្នែកទី ១ ÷ ភាពជឿទុកចិត្តបាននៃថវិកា

ផ្នែកទី១ "ភាពជឿទុកចិត្តបាននៃថវិកា" មាន ៤ គោលបំណង គឺ÷

១. បន្តពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល
២. បន្តពង្រឹងការគ្រប់គ្រងបំណុល
៣. ពង្រឹងការគ្រប់គ្រងសាច់ប្រាក់និងគណនី
៤. កែលម្អការអនុវត្តថវិកានិងពង្រឹងការអនុវត្តផែនការចំណាយ។

## ផ្នែកទី ២ ÷ គណនេយ្យភាពហិរញ្ញវត្ថុ

ផ្នែកទី ២ "គណនេយ្យភាពហិរញ្ញវត្ថុ" មាន ៤ គោលបំណង គឺ÷

១. ពង្រឹងការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនីថ្មី
២. ពង្រឹងការអនុវត្តប្រព័ន្ធថវិកាថ្មីនិងដំណើរការប្រតិបត្តិការថ្មី
៣. ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មីនិងប្រព័ន្ធតម្លាភាព
៤. ពង្រឹងការអនុវត្តឧបករណ៍និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាព (ប្រព័ន្ធត្រួតពិនិត្យ)។

## ផ្នែកទី ៣ ÷ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ

ផ្នែកទី ៣ “ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ” មាន ៦ គោលបំណង គឺ÷

១. ពង្រឹងនិងពង្រីកការអនុវត្តថវិកាកម្មវិធី

២. រៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយនិងធ្វើសមាហរណកម្មថវិកា

៣. រៀបចំនិងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាព (រវាងនីតិប្បញ្ញត្តិនិងនីតិប្រតិបត្តិ, រវាង កសហវ និងក្រសួង-ស្ថាប័ន និង នៅក្នុងក្រសួង-ស្ថាប័ន)

៤. ពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ (ការរៀបចំគោលនយោបាយនិងផែនការចំណូលនិងចំណាយ រយៈពេលមធ្យម)

៥. រៀបចំប្រព័ន្ធត្រួតពិនិត្យ

៦. ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ។

ដើម្បីសម្រេចគោលបំណងខាងលើ ជាពិសេសសម្រាប់ដំណាក់កាលទី៣ តទៅ រាជរដ្ឋាភិបាលបានកំណត់យកការកែទម្រង់ប្រព័ន្ធថវិកា ទុកជាស្នូលនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយបានដាក់ចេញនូវ **ទិសដៅនិងយុទ្ធសាស្ត្រនៃការកែទម្រង់ប្រព័ន្ធថវិកានៅកម្ពុជា ឆ្នាំ២០១៣-២០២០**។

ក្នុងគោលដៅខាងលើនេះ ក្របខ័ណ្ឌថវិការយៈពេលមធ្យម នឹងត្រូវបង្កើតឡើងដោយផ្អែកលើក្របខ័ណ្ឌចំណូលរយៈពេលមធ្យម, ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម ដើម្បីដាក់ជូនគណៈរដ្ឋមន្ត្រីពិនិត្យនិងអនុម័ត។

## ផ្នែកទី ៤ ÷ ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់

ផ្នែកទី ៤ “ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់” មាន ៤ គោលបំណង គឺ÷

១. បង្កើតក្របខ័ណ្ឌថវិកាដោយផ្អែកលើសមិទ្ធកម្ម

២. បង្កើតក្របខ័ណ្ឌគណនេយ្យភាពនៃសមិទ្ធកម្ម

៣. បង្កើតក្របខ័ណ្ឌសវនកម្មលើសមិទ្ធកម្ម

៤. រៀបចំផែនការកសាងសមត្ថភាព (ដោយរួមទាំងស្ថាប័ននីតិប្បញ្ញត្តិ និង អាជ្ញាធរសវនកម្មជាតិ)។

**ផ្នែកទី៥ ÷ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យនិងចីរភាព**

ផ្នែកទី ៥ "ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព" មានគោលបំណងចំនួន ៣ គឺ÷

១. បង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្តុះឆន្ទៈកំណែទម្រង់ ព្រមទាំងបង្កើនភាពជាម្ចាស់និងការទទួលខុសត្រូវ
២. បង្កើនប្រសិទ្ធភាពនៃការកសាងសមត្ថភាពនិងវិធានការលើកទឹកចិត្ត និង
៣. ពង្រឹងការកសាងសមត្ថភាពសម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣។

ផែនការសកម្មភាពរួម ដំណាក់កាលទី៣ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ មានភ្ជាប់ជាឧបសម្ព័ន្ធនៃសៀវភៅនេះ ***(ឧបសម្ព័ន្ធ ៩)*** ។

## ៥. ការត្រួតពិនិត្យនិងវាយតម្លៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កិច្ចដំណើរការនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានដាក់ឱ្យស្ថិតនៅក្រោមការត្រួតពិនិត្យនិងវាយតម្លៃដោយនាយករដ្ឋមន្ត្រី ដែលមានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ធ្វើជាសេនាធិការ។

ហេតុនេះ ក្រសួង-ស្ថាប័ននីមួយៗ ត្រូវអនុវត្តផែនការសកម្មភាព ដែលត្រូវបានដាក់ឱ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួង ឬ ប្រធានស្ថាប័ន ដោយត្រូវសម្រេចឱ្យបាននូវសូចនាករនិងគោលដៅនៃសកម្មភាពនីមួយៗ តាមកាលកំណត់។ ក្នុងករណីជួបបញ្ហាប្រឈមក្នុងការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួង-ស្ថាប័ននីមួយៗ អាចប្រើប្រាស់យន្តការដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចមានកំណត់ក្នុងសារាចរលេខ ០០៦ សហវ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ (***ឧបសម្ព័ន្ធ ៨***)។

ដើម្បីធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, យន្តការត្រួតពិនិត្យតាមដាននិងវាយតម្លៃសមិទ្ធកម្មជាប្រចាំ ត្រូវបានដាក់ឱ្យអនុវត្ត ដោយផ្អែកលើរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាសនិងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ

នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង-ស្ថាប័ននីមួយៗ *(ឧបសម្ព័ន្ធ ១០)*។

ការវាយតម្លៃសមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវអនុលោមតាមវិធីសាស្ត្រនៃការកំណត់ទម្ងន់ជាក់លាក់មួយ ( ***ឧបសម្ព័ន្ធ ១១***)។

ជារួម ការត្រួតពិនិត្យនិងវាយតម្លៃខាងលើនេះត្រូវបានកំណត់ដោយសារាចររបស់រាជរដ្ឋាភិបាល លេខ ០៩ សរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ***(ឧបសម្ព័ន្ធ ៤)*** ។

## ៦. ធនធានហិរញ្ញវត្ថុ

### ៦.១. ការចំណាយសម្រាប់គាំទ្រកិច្ចដំណើរការ នៃកម្មវិធីកែទម្រង់ចាប់ពីឆ្នាំ ២០០៤ ដល់ឆ្នាំ២០១៥

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានទទួលការគាំទ្រផ្នែកហិរញ្ញវត្ថុ ដោយថវិការបស់រាជរដ្ឋាភិបាល និងមូលនិធិរបស់ដៃគូអភិវឌ្ឍន៍។ សម្រាប់ដំណាក់កាលទី១ និងដំណាក់-កាលទី២ (ពីខែធ្នូ ឆ្នាំ២០០៤ ដល់ខែធ្នូ ឆ្នាំ២០១៥) កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានទទួលហិរញ្ញប្បទានសរុបប្រមាណ **៤៥ លានដុល្លារអាមេរិក** ក្នុងនោះ÷

១. ថវិការបស់រាជរដ្ឋាភិបាលប្រមាណ **១ លានដុល្លារអាមេរិក** និង

២. ហិរញ្ញប្បទានជាជំនួយឥតសំណងពីមូលនិធិដៃគូអភិវឌ្ឍន៍សរុបប្រមាណ **៤៤ លានដុល្លារអាមេរិក** ដែលបានមកពីធនាគារពិភពលោក, សហភាពអឺរ៉ុប, ទីភ្នាក់ងារសហប្រតិបត្តិការអភិវឌ្ឍអន្តរជាតិស៊ុយអែត (SIDA), ប្រទេសអង់គ្លេស (DFID) និងប្រទេសអូស្ត្រាលី (AusAIDS)។

ប្រភពហិរញ្ញប្បទានខាងលើត្រូវបានបែងចែកជា ២ គម្រោង ដែលគ្រប់គ្រងនិងសម្របសម្រួលដោយធនាគារពិភពលោក គឺ÷

១. គម្រោងគណនេយ្យភាពនិងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management and Accountability Project) ពីឆ្នាំ២០០៤ ដល់ឆ្នាំ២០១៣ មានហិរញ្ញប្បទានសរុបចំនួន **២៤,៥ លានដុល្លារសហរដ្ឋអាមេរិក** និង

២. គម្រោងទំនើបកម្មការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (Public Financial Management Modernization Project) សម្រាប់ឆ្នាំ ២០១៤-២០១៧ មានហិរញ្ញប្បទានសរុបប្រមាណ **១៩,៥ លានដុល្លារអាមេរិក**។

ដំណាក់កាលទី១ និងដំណាក់កាលទី២ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានចំណាយឥណទានថវិកាសម្រាប់គាំទ្រកិច្ចដំណើរការរបស់ខ្លួន អស់ប្រមាណ **៣១ លានដុល្លារអាមេរិក** និងនៅសល់ហិរញ្ញប្បទានប្រមាណ ១៤ លានដុល្លារអាមេរិក សម្រាប់បន្តអនុវត្តនៅក្នុងដំណាក់កាលទី៣ សម្រាប់ឆ្នាំ២០១៦-២០១៧។

## ៦.២. តម្រូវការធនធានហិរញ្ញវត្ថុ សម្រាប់ដំណាក់កាលទី៣

សម្រាប់ជំហានទី៣ “**ថវិកាផ្សារភ្ជាប់នឹងគោលនយោបាយ**” នៅដំណាក់កាលទី៣ (២០១៦-២០២០), កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នឹងត្រូវការធនធានហិរញ្ញវត្ថុសម្រាប់គាំទ្រដល់កិច្ចដំណើរការសរុបចំនួនប្រមាណ **៧៥,៧ លានដុល្លារអាមេរិក**។

បច្ចុប្បន្ននេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បានទទួលថវិកាសរុបចំនួន **៣៨,៥ លានដុល្លារអាមរិក** ដែលក្នុងនោះ÷

១. ថវិការបស់រាជរដ្ឋាភិបាលចំនួនប្រមាណ **២,៥ លានដុល្លារអាមេរិក** សម្រាប់រយៈពេល ០៥ ឆ្នាំ (២០១៦-២០២០) និង

២. ហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍ជាជំនួយឥតសំណងចំនួន **៣៦ លានដុល្លារអាមេរិក** ដែលក្នុងនោះ **២២ លានដុល្លារអាមេរិក** ជាជំនួយឥតសំណងរបស់សហភាពអឺរ៉ុប សម្រាប់រយៈពេលបីឆ្នាំ (២០១៦-២០១៨) និងប្រមាណ **១៤ លានដុល្លារអាមេរិក** ជាហិរញ្ញប្បទានដែលនៅសល់ពីគម្រោងទំនើបកម្មការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សម្រាប់បន្តអនុវត្តជាង ០១ ឆ្នាំ (២០១៦-២០១៧)។

ក្រៅពីនេះ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅពុំទាន់មានប្រភពហិរញ្ញប្បទាននៅឡើយ ចំពោះថវិកាសម្រាប់គម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (FMIS) ដំណាក់កាលទី២ និង ការគាំទ្រថវិកាសម្រាប់ក្រសួង-ស្ថាប័ន ដោយមានតម្រូវការបន្ថែមប្រមាណ **៣៧,២លានដុល្លារអាមេរិក** ទៀត។

ការគណនាចំណាយ មានភ្ជាប់ជាតារាងលម្អិតដូចខាងក្រោម÷

១. តារាងគណនាចំណាយតាមផែនការសកម្មភាពរួម ដំណាក់កាលទី៣ សម្រាប់រយៈពេល ០៥ ឆ្នាំ (២០១៦-២០២០)

| **តម្រូវការហិរញ្ញប្បទានសម្រាប់ផែនការសកម្មភាព ដំណាក់កាលទី៣** | | | | | | | |
|---|---|---|---|---|---|---|---|
| **ផែនការសកម្មភាព ដំណាក់កាលទី៣** | **ឆ្នាំ ២០១៦ - ២០២០ (គិតជាលានដុល្លារ)** | | | | | **សរុប** | **ផ្សេងៗ** |
| | **២០១៦** | **២០១៧** | **២០១៨** | **២០១៩** | **២០២០** | | |
| ១.បន្តពង្រឹងភាពជឿទុកចិត្តបាននៃថវិកា | ៣.០០ | ១.៧០ | ០.៨០ | ០.៥០ | ០.៥០ | **៦.៥០** | |
| ២.បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ | ៨.៥០ | ៣.០០ | ៦.០០ | ១០.៥០ | ៥.៥០ | **៣៣.៥០** | |
| ៣.ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ | ១.២០ | ៥.០០ | ៥.៥០ | ៦.០០ | ៦.០០ | **២៣.៧០** | |
| ៤.ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់ | ១.០០ | ០.៨០ | ១.៥០ | ១.៥០ | ១.៥០ | **៦.៣០** | |
| ៥.ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ប្រកបដោយជោគជ័យ និងចីរភាព | ១.០០ | ១.០០ | ១.៧០ | ១.៥០ | ០.៥០ | **៥.៧០** | |
| **សរុប** | **១៤.៧០** | **១១.៥០** | **១៥.៥០** | **២០.០០** | **១៤.០០** | **៧៥.៧០** | |

២. តារាងគណនាចំណាយតាមផ្នែក(Category) សម្រាប់រយៈពេល ០៥ ឆ្នាំ (២០១៦-២០២០)

| **តម្រូវការហិរញ្ញប្បទានតាមផ្នែក (Catagories)** | | | | | | | |
|---|---|---|---|---|---|---|---|
| **ផ្នែក (Catagories)** | **ឆ្នាំ ២០១៦ - ២០២០ (គិតជាលានដុល្លារ)** | | | | | **សរុប** | **ផ្សេងៗ** |
| | **២០១៦** | **២០១៧** | **២០១៨** | **២០១៩** | **២០២០** | | |
| ១-ប្រព័ន្ធ FMIS | ៧.០០ | ០.០០ | ៥.០០ | ១០.០០ | ៥.០០ | **២៧.០០** | |
| ទំនិញ | ១.៧០ | ០.៥០ | ១.០០ | ០.៥០ | ១.០០ | **៤.៧០** | ទូទៅ |
| ២-សេវាកម្ម | ១.០០ | ១.៥០ | ១.០០ | ១.៥០ | ០.៥០ | **៥.៥០** | |
| ៣-បណ្ដុះបណ្ដាល/សិក្ខាសាលា | ១.០០ | ២.០០ | ២.០០ | ២.០០ | ១.៥០ | **៨.៥០** | |
| ៤-ចំណាយប្រតិបត្តិការ | ១.០០ | ១.០០ | ១.០០ | ១.០០ | ១.០០ | **៥.០០** | |
| ៥-ក្រសួង- ស្ថាប័ន (ទំនិញ,សេ-វាកម្ម,សិក្ខាសាលា,ប្រតិបត្តិការ) | ៣.០០ | ៦.៥០ | ៥.៥០ | ៥.០០ | ៥.០០ | **២៥.០០** | |
| **សរុប** | **១៤.៧០** | **១១.៥០** | **១៥.៥០** | **២០.០០** | **១៤.០០** | **៧៥.៧០** | |

## ៣. តារាងគណនាចំណាយលម្អិតតាមសមាសភាគ សម្រាប់ឆ្នាំ២០១៦

| **តម្រូវការហិរញ្ញប្បទានតាមសមាសភាគ (Components)** | | | | | | | |
|---|---|---|---|---|---|---|---|
| សមាសភាគ | **ឆ្នាំ ២០១៦ - ២០២០ (គិតជាលានដុល្លារ)** | | | | | **សរុប** | **ផ្សេងៗ** |
| | **២០១៦** | **២០១៧** | **២០១៨** | **២០១៩** | **២០២០** | | |
| ១-ផ្នែកគោលនយោបាយ | ១.៣០ | ១.៨០ | ១.៥០ | ០.៩០ | ០.៤៥ | **៥.៩៥** | |
| ២-ផ្នែកចំណូល | ១.០០ | ២.០០ | ១.៧០ | ១.៦០ | ០.៥៥ | **៦.៨៥** | |
| ៣-ផ្នែករៀបចំថវិកា | ១.៥០ | ១.២០ | ០.៨០ | ១.០០ | ០.៤៥ | **៤.៩៥** | |
| ៤-ផ្នែកអនុវត្តថវិកា | ០.៩០ | ០.៧០ | ១.៣០ | ១.៣០ | ០.៧០ | **៤.៩០** | |
| ៥-ផ្នែកគាំទ្រទូទៅនិង កសាងសមត្ថភាព | ៩.០០ | ៥.០០ | ៩.៥០ | ១៤.៣០ | ១១.៤០ | **៤៩.២០** | |
| ៦-ផ្នែកនវានុវត្តន៍និងផ្សព្វផ្សាយ | ១.០០ | ០.៨០ | ០.៧០ | ០.៩០ | ០.៤៥ | **៣.៨៥** | |
| **សរុប** | **១៤.៧០** | **១១.៥០** | **១៥.៥០** | **២០.០០** | **១៤.០០** | **៧៥.៧០** | |

## ៤. តារាងគណនាចំណាយតាមអនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាពសម្រាប់រយៈពេល ០៥ ឆ្នាំ (២០១៦-២០២០)

| **គ្រោងតម្រូវការឥណទាននិងការព្យាករណ៍តម្រូវការឥណទាន** | | | | | | |
|---|---|---|---|---|---|---|
| **កម្មវិធី/អនុកម្មវិធី (គិតជាលានដុល្លារអាមេរិក)** | | | | | | |
| **ប្រភេទចំណាយ** | **២០១៦** | **២០១៧** | **២០១៨** | **២០១៩** | **២០២០** | **សរុប** |
| **សរុបរួម** | **០.៣៧** | **០.៦០** | **០.៥៨** | **០.៤៨** | **០.៤៨** | **២.៥១** |
| -សរុបចំណាយចរន្ត | ០.៣៧ | ០.៦០ | ០.៥៨ | ០.៤៨ | ០.៤៨ | **២.៥១** |
| +បន្ទុកបុគ្គលិក | ០.៣១ | ០.៤៣ | ០.៤៣ | ០.៤៣ | ០.៤៣ | **២.០៣** |
| +ក្រៅបន្ទុកបុគ្គលិក | ០.០៦ | ០.១៧ | ០.១៥ | ០.០៥ | ០.០៥ | **០.៤៨** |
| -**សរុបចំណាយមូលធន** | - | - | - | - | - | - |

## ៦.៣. ការគ្រប់គ្រងធនធាន

អនុលោមតាមអនុក្រឹត្យលេខ ៧៤ អនក្រ.បក ចុះថ្ងៃទី២២ ខែឧសភា ឆ្នាំ២០១២ ស្តីពីការដាក់ឱ្យប្រើប្រាស់នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការអនុវត្តគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ និងប្រកាសលេខ ៣៣០ សហវ.ប្រក ចុះថ្ងៃទី២៦ ខែមីនា ឆ្នាំ២០១៥ ស្តីពីការដាក់ឱ្យអនុវត្តនីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ នៅក្នុង **អ.គ.ហ.**, រាល់ប្រតិបត្តិការហិរញ្ញវត្ថុនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវអនុវត្តតាមនីតិវិធីរួមបច្ចុប្បន្នកម្ម សម្រាប់គម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍ ដែលរួមមាន នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការគ្រប់គ្រងគម្រោង (Standard Operating Procedure: SOP), នីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុគម្រោង (Financial Management Manual: FMM) និងនីតិវិធីរួមបច្ចុប្បន្នកម្មសម្រាប់ការគ្រប់គ្រងកិច្ចលទ្ធកម្មគម្រោង (Procurement Manual: PM) ដោយមាន **អ.គ.ហ.** ជា “**អង្គភាពប្រតិបត្តិ**” (Executive Agency: EA) មានន័យថា **អ.គ.ហ.** ត្រូវទទួលបន្ទុកគ្រប់គ្រង សម្របសម្រួល និងត្រួតពិនិត្យតាមដានរាល់ការអនុវត្តថវិការបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល ទាំងចំពោះហិរញ្ញប្បទានដៃគូអភិវឌ្ឍន៍ និងទាំងចំពោះថវិកាបដិភាគរបស់រាជរដ្ឋាភិបាល។

ទន្ទឹមនេះ **អ.គ.ហ.** បានរៀបចំ “គោលការណ៍ណែនាំលម្អិតបន្ថែមស្តីពីការគ្រប់គ្រងហិរញ្ញវត្ថុ” (Supplementary Financial Management Manual: SFMM) សម្រាប់កំណត់ឱ្យកាន់តែមានសមានគតិភាពនឹងស្ថានភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងមានភាពច្បាស់លាស់ក្នុងការកំណត់សិទ្ធិអំណាចនិងការទទួលខុសត្រូវក្នុងការអនុវត្តនីតិវិធីហិរញ្ញវត្ថុ ប្រព័ន្ធគណនេយ្យ ការគ្រប់គ្រងទ្រព្យសម្បត្តិគម្រោង ការត្រួតពិនិត្យផ្ទៃក្នុង និងនីតិវិធីសវនកម្ម។ គោលការណ៍ណែនាំនេះសម្រួលដល់ដៃគូអភិវឌ្ឍន៍ ក្នុងការត្រួតពិនិត្យនិងតាមដានការអនុវត្តថវិកានៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

សម្រាប់ការត្រួតពិនិត្យនិងតាមដានការអនុវត្តថវិកា, **អ.គ.ហ.** ត្រូវរៀបចំបូកសរុបរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សមិទ្ធកម្មនៃគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់ក្រសួង-ស្ថាប័ន ជាប្រចាំត្រីមាស និងប្រចាំឆ្នាំ។ លើសពីនេះ **អ.គ.ហ.** បានរៀបចំរបាយការណ៍ហិរញ្ញវត្ថុនិងរបាយការណ៍សមិទ្ធកម្ម តាមអនុកម្មវិធី ចង្កោមសកម្មភាព និងសកម្មភាព ដោយផ្អែកលើគោលការណ៍ណែនាំស្តីពីនីតិវិធីអនុវត្តថវិកាកម្មវិធី ក្នុងគោលដៅបន្ទុំយន្តការត្រួត-

ពិនិត្យនិងវាយតម្លៃសមិទ្ធកម្មទៅនឹងយន្តការរបស់រាជរដ្ឋាភិបាល។ គ្រប់របាយការណ៍ហិរញ្ញវត្ថុត្រូវជាកម្មវត្ថុនៃការចុះត្រួតពិនិត្យពីធនាគារពិភពលោក និងការចុះធ្វើសវនកម្មពីអគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ, ក្រុមហ៊ុនសវនកម្មឯករាជ្យ និងពីអាជ្ញាធរសវនកម្មជាតិ។

## ៧. ការគ្រប់គ្រងហានិភ័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

### ៧.១. និយមន័យនៃហានិភ័យ

**ហានិភ័យ** គឺជាព្រឹត្តិការណ៍ ដែលបង្កការគំរាមកំហែងដល់លទ្ធផល ឬសមិទ្ធកម្មរបស់កម្មវិធីដែលបានគ្រោងទុក។ ហានិភ័យ មានលក្ខណៈ មិនជាក់លាក់ ពុំទៀងទាត់ ពុំអាចលុបបំបាត់ ឬទប់ស្កាត់បានទាំងស្រុង ប៉ុន្តែអាចត្រូវបានកាត់បន្ថយឥទ្ធិពលតាមរយៈវិធានការបង្ការ ទប់ស្កាត់ ឬបញ្ចៀស ដោយប្រើប្រាស់អភិក្រមបុរេសកម្ម សកម្ម និងអន្តរសកម្ម។ ជាទូទៅ ប្រសិនបើហានិភ័យនោះកើតឡើង លទ្ធផល ឬសមិទ្ធកម្មដែលទទួលបាន នឹងអាចខុសពីការរំពឹងទុក។

ហេតុនេះ ហានិភ័យចាំបាច់ត្រូវស្ថិតនៅក្រោមការគ្រប់គ្រងដ៏ជាក់លាក់មួយ។ ក្នុងន័យនេះ ការគ្រប់គ្រងហានិភ័យសំដៅដល់ដំណើរការកំណត់និងវិភាគហានិភ័យ ដើម្បីរៀបចំនិងដាក់ចេញនូវវិធានការបង្ការ ទប់ស្កាត់ កាត់បន្ថយអានុភាព ឬបញ្ចៀសហានិភ័យប្រកបដោយប្រសិទ្ធភាព។

ចំពោះកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ហានិភ័យត្រូវបានកំណត់ចេញពីបញ្ហាប្រឈមចម្បងៗដែលបានជួបប្រទះនៅដំណាក់កាលទី១ និងដំណាក់កាលទី២ និងបន្តជះឥទ្ធិពលអវិជ្ជមានដល់សមិទ្ធកម្មនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងជំហាននិងដំណាក់កាលបន្ទាប់។

### ៧.២. កម្រិតនៃហានិភ័យ

ហានិភ័យ ត្រូវបានធ្វើចំណាត់ថ្នាក់ ជា ៣ កម្រិត ដូចខាងក្រោម÷

ក. **កម្រិតខ្ពស់** ÷ សំដៅដល់ហានិភ័យទាំងឡាយណាដែលជះឥទ្ធិពលអវិជ្ជមានធ្ងន់ធ្ងរដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រហូតអាចបញ្ឈប់ដំណើរការអនុវត្តសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ខ. **កម្រិតមធ្យម** ÷ សំដៅដល់ហានិភ័យទាំងឡាយណាដែលជះឥទ្ធិពលអវិជ្ជមានមធ្យម ដល់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចជាការរាំងស្ទះ ដែលបង្កឱ្យមាន

ភាពយឺតយ៉ាវខ្លាំង ឬ ពន្យារពេលយូរដល់ការអនុវត្តសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**គ. កម្រិតទាប ÷** សំដៅដល់ហានិភ័យទាំងឡាយណាដែលជះឥទ្ធិពលអវិជ្ជមានជាផលវិបាកដល់ការអនុវត្តសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

## ៧.៣. ហានិភ័យ និង សំណើវិធានការដោះស្រាយ

ហានិភ័យ ទាំង ៣ កម្រិត និងវិធានការដោះស្រាយ ត្រូវបានស្នើឡើង ដូចខាងក្រោម÷

| ល.រ | ហានិភ័យ | កម្រិតហានិភ័យ | អង្គភាពទទួលបន្ទុក | សំណើវិធានការដោះស្រាយ |
|---|---|---|---|---|
| ១ | **ភាពជាម្ចាស់/ភាពជាអ្នកដឹកនាំ**<br>- កង្វះឆន្ទៈ; ភាពជាម្ចាស់, ភាពជាអ្នកដឹកនាំ, ការទទួលខុសត្រូវ និងការផ្តល់អាទិភាពលើការអនុវត្តកម្មវិធីកែទម្រង់ហិរញ្ញវត្ថុសាធារៈណៈនិងកម្មវិធីកែទម្រង់ពាក់ព័ន្ធផ្សេងទៀត | **ខ្ពស់** | - ក្រសួង-ស្ថាប័ន<br>- កសហវ<br>- អ.គ.ហ. | - ត្រូវបង្កើនឆន្ទៈ; ភាពជាម្ចាស់, ការទទួលខុសត្រូវព្រមទាំងពង្រឹងភាពជាអ្នកដឹកនាំ និងសមត្ថភាពគ្រប់គ្រងដល់ថ្នាក់ដឹកនាំនិងមន្រ្តីពាក់ព័ន្ធ តាមរយៈការជំរុញនិងលើកទឹកចិត្តឱ្យមានការដាក់ចេញជាសកម្មភាពពាក់ព័ន្ធនៅក្នុងផែនការសកម្មភាពរួមដំណាក់កាលទី៣ និងដំណាក់កាលបន្តបន្ទាប់ទៀត<br>- រៀបចំឱ្យមានកិច្ចប្រជុំជាប្រចាំរបស់ក្រុមការងារកែទម្រង់ ដោយមានការចូលរួមពីថ្នាក់ដឹកនាំនិងមន្រ្តីពាក់ព័ន្ធ ដើម្បីពិនិត្យតាមដានលើវឌ្ឍនភាពកម្មវិធីកែទម្រង់<br>- បង្កើនការផ្សព្វផ្សាយស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដល់កម្រិតថ្នាក់ដឹកនាំនយោបាយ, កម្រិតថ្នាក់ដឹកនាំបច្ចេកទេស និងកម្រិតជំនាញ តាមរយៈសិក្ខាសាលា សន្និសីទ និង |

| ល.រ | ហានិភ័យ | កម្រិតហានិភ័យ | អង្គភាពទទួលបន្ទុក | សំណើវិធានការដោះស្រាយ |
|---|---|---|---|---|
| | | | | បទឧទ្ទេសនាមពាក់ព័ន្ធនានា។ |
| ២ | **ធនធានមនុស្ស**<br>- ការប្រើប្រាស់ធនធានមនុស្សមិនចំគោល-ដៅនិងការផ្លាស់ប្តូរធនធានមនុស្សញឹកញាប់ក្នុងពេលអនុវត្តកម្មវិធីកែទម្រង់តាមដំណាក់កាលនីមួយៗ<br>- កង្វះធនធានមនុស្សសម្រាប់អនុវត្តកម្មវិធីកែទម្រង់នៅដំណាក់កាលនីមួយៗ<br>- មិនមានការកំណត់គោលដៅការងារច្បាស់លាស់សម្រាប់ក្រុមការងារកែទម្រង់ | ខ្ពស់ | - កសហវ<br>- ក្រសួង-ស្ថាប័ន<br>- អ.គ.ហ. | - ពិនិត្យមើលឡើងវិញនូវប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការបណ្តុះបណ្តាល និងកំណត់ពីតម្រូវការធនធានមនុស្សសម្រាប់ការងារកែទម្រង់ឱ្យបានច្បាស់លាស់ និងស្របតាមពេលវេលាជាក់លាក់<br>- រៀបចំផែនការអភិវឌ្ឍន៍ធនធានមនុស្សសម្រាប់ដំណាក់កាលទី៣និងដំណាក់កាលបន្តបន្ទាប់ដែលរួមមានទាំងការបណ្តុះបណ្តាលជំនាញនៅក្នុងកសហវ និងក្នុងក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>- រៀបចំកំណត់អាណត្តិនិងលក្ខខណ្ឌយោង (TOR) របស់ក្រុមការងារកែទម្រង់ឱ្យបានច្បាស់លាស់បន្ថែមទៀត។ |
| ៣ | **ការគ្រប់គ្រងផ្ទៃក្នុង**<br>- កង្វះប្រព័ន្ធត្រួតពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្តថវិកាកម្មវិធី<br>- តួនាទីនៃអង្គភាព/ស្ថាប័នក្នុងការអនុវត្ត | ខ្ពស់ | - កសហវ<br>- ក្រសួង-ស្ថាប័ន | - ត្រួតពិនិត្យឡើងវិញនូវប្រព័ន្ធតាមដានត្រួតពិនិត្យនិងវាយតម្លៃដែលមានស្រាប់ ព្រមទាំងរៀបចំនូវប្រព័ន្ធត្រួតពិនិត្យថ្មីដែលអាចឆ្លើយតបបានទៅនឹងបរិបថថ្មីនៃថវិកាកម្មវិធីប្រកបដោយស័ក្តិសិទ្ធ- |

| ល.រ | ហានិភ័យ | កម្រិតហានិភ័យ | អង្គភាពទទួលបន្ទុក | សំណើវិធានការដោះស្រាយ |
|---|---|---|---|---|
| | ការងារត្រួតពិនិត្យមិនច្បាស់លាស់ ឬជាន់គ្នា | | | ភាព និងប្រសិទ្ធភាពខ្ពស់<br>- ត្រួតពិនិត្យឡើងវិញពីមុខងារនិងតួនាទីនៃអង្គភាពត្រួតពិនិត្យនិងវាយតម្លៃហើយកែសម្រួលដើម្បីបង្កើនភាពច្បាស់លាស់ និងបន្ថយការត្រួត ឬ ជាន់គ្នា។ |
| ៤ | **ប្រតិភូកម្មអំណាច**<br>- គោលការណ៍ណែនាំនៃការរៀបចំនិងអនុវត្តរបស់អង្គភាពថវិកា មិនទាន់បានគ្រប់ជ្រុងជ្រោយ<br>- កង្វះការផ្ទេរសិទ្ធិអំណាចដល់អង្គភាពថវិកាឱ្យបានពេញលេញ<br>- ប្រើប្រាស់សិទ្ធិអំណាចដែលបានធ្វើប្រតិភូកម្មមិនបានត្រឹមត្រូវ | **ខ្ពស់** | - ក្រសួង-ស្ថាប័ន<br>- កសហវ | - បន្តកែលម្អគោលការណ៍ណែនាំស្តីពីការរៀបចំនិងការអនុវត្តរបស់អង្គភាពថវិកាឱ្យបានច្បាស់លាស់ជាងមុន<br>- បន្តជំរុញការធ្វើប្រតិភូកម្មអំណាចទៅអង្គភាពថវិកាឱ្យបានច្រើនជាងមុនរហូតក្លាយជាអង្គភាពថវិកាពេញលេញ<br>- បន្តផ្សព្វផ្សាយអំពីសិទ្ធិអំណាចនិងការទទួលខុសត្រូវរបស់អង្គភាពថវិកា និងអ្នកគ្រប់គ្រងថវិកា<br>- បន្តពង្រឹងនិងបណ្តុះបណ្តាលមន្ត្រីពាក់ព័ន្ធ។ |

| ល.រ | ហានិភ័យ | កម្រិតហានិភ័យ | អង្គភាពទទួលបន្ទុក | សំណើវិធានការដោះស្រាយ |
|---|---|---|---|---|
| ៥ | **សមាហរណកម្មថវិកា**<br>- ការធ្វើសមាហរណកម្មថវិកា នៅមានកម្រិត<br>- កម្មវិធីវិនិយោគសាធារណៈ(PIP) បីឆ្នាំរំកិល មិនទាន់អាចប្រើជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP), ក្របខ័ណ្ឌថវិកាបីឆ្នាំ រំកិល និងថវិកាប្រចាំឆ្នាំបាន<br>- សមាហរណកម្មរវាងថវិកាវិនិយោគក្នុងស្រុក និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍នៅមានកម្រិត | ខ្ពស់ | - កសហវ<br>- ក្រសួង-ស្ថាប័ន | - ពង្រឹងគុណភាពនៃការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងការរៀបចំថវិកាកម្មវិធីដើម្បីធានាសមាហរណកម្មថវិកាពេញលេញ<br>- ពង្រឹងគុណភាពនៃការរៀបចំកម្មវិធីវិនិយោគសាធារណៈ (PIP) បីឆ្នាំរំកិល ដើម្បីជាមូលដ្ឋានក្នុងការរៀបចំផែនការយុទ្ធសាស្ត្រថវិកា (BSP), ក្របខ័ណ្ឌថវិកាបីឆ្នាំរំកិល និងថវិកាប្រចាំឆ្នាំ<br>- រៀបចំក្របខ័ណ្ឌវិនិយោគ (Investment Framework) សំដៅធ្វើសុខដុមនីយកម្មនៃកម្មវិធីវិនិយោគសាធាណៈ<br>- រៀបចំធ្វើសុខដុមនីយកម្មលើយន្តការនិងនីតិវិធីគ្រប់គ្រងគម្រោងវិនិយោគទាំងអស់ពីប្រភពហិរញ្ញប្បទានវិនិយោគក្នុងស្រុក និងហិរញ្ញប្បទានពីដៃគូអភិវឌ្ឍន៍<br>- បន្តវិភាជន៍ថវិកាវិនិយោគក្នុងស្រុកផ្ទាល់ទៅវិស័យអាទិភាពឱ្យកាន់តែច្រើន តាមដែលអាចធ្វើបាន។ |

| ល.រ | ហានិភ័យ | កម្រិតហានិភ័យ | អង្គភាពទទួលបន្ទុក | សំណើវិធានការដោះស្រាយ |
|---|---|---|---|---|
| ៦ | **លទ្ធផលសម្រេចបាននៅដំណាក់កាលទី១ និង ទី២ ដែលត្រូវបន្តអនុវត្តនៅដំណាក់កាលទី៣ និងដំណាក់កាលបន្តបន្ទាប់**<br>- ការអនុវត្តគោលនយោបាយចំណូលដែលនឹងពង្រីកមូលដ្ឋានប្រមូលចំណូល, ពង្រឹងការគ្រប់គ្រងចំណូល, និងបង្កើនសុក្រឹតភាពនៃការព្យាករណ៍ចំណូលមានវឌ្ឍនភាពយឺត<br>- ការអនុវត្តការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធពត៌មានវិទ្យា (FMIS) នៅមានកម្រិត ឬត្រូវការពេលវេលាច្រើន ដែលប៉ះពាល់ដល់ការងារត្រួតពិនិត្យ និងគណនេយ្យភាពនៃការងារកែទម្រង់<br>- ការគាំទ្រហិរញ្ញវត្ថុសម្រាប់អនុវត្តប្រព័ន្ធ FMIS ដំណាក់កាលទី២ នៅមិនទាន់មានភាពច្បាស់លាស់ | ខ្ពស់ | - រដ្ឋបាលប្រមូលចំណូល<br>- គសហវ<br>- ក្រសួង-ស្ថាប័ន | - បន្តជំរុញអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ សំដៅធានាឱ្យបានភាពជឿទុកចិត្តនៃថវិកា<br>- រៀបចំយន្តការតាមដាន ត្រួតពិនិត្យ និងវាយតម្លៃលើវឌ្ឍនភាពនិងយន្តការដោះស្រាយបន្ថែមទៅលើយន្តការដែលមានស្រាប់ ជាពិសេសការអនុវត្តប្រព័ន្ធ FMIS<br>- បន្តពិភាក្សាជាមួយដៃគូអភិវឌ្ឍន៍ អំពីការគាំទ្រហិរញ្ញវត្ថុសម្រាប់ការអនុវត្តប្រព័ន្ធ FMIS ដំណាក់-កាលទី២ ជាពិសេសការពង្រីកការអនុវត្តដល់ក្រសួងស្ថាប័នផ្សេងទៀត<br>- បន្តផ្សព្វផ្សាយអំពីការគ្រប់គ្រងហិរញ្ញវត្ថុតាមប្រព័ន្ធ FMIS ដល់ក្រសួង-ស្ថាប័នដើម្បីមានចំណេះដឹងមូលដ្ឋានក្នុងការត្រៀមខ្លួនអនុវត្តប្រព័ន្ធ FMIS ឱ្យបានទាន់ពេលវេលា។ |

| ល.រ | ហានិភ័យ | កម្រិតហានិភ័យ | អង្គភាពទទួលបន្ទុក | សំណើវិធានការដោះស្រាយ |
|---|---|---|---|---|
| | - ក្រសួង-ស្ថាប័ន មិនទាន់បានត្រៀមលក្ខណៈគ្រប់គ្រាន់ក្នុងការអនុវត្តប្រព័ន្ធ FMIS។ | | | |
| ៧ | **ប្រព័ន្ធលើកទឹកចិត្តដល់ក្រុមការងារកែទម្រង់**<br>- កង្វះការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និង/ឬ មិនមែនហិរញ្ញវត្ថុដល់ក្រុមការងារកែទម្រង់ អាចប៉ះពាល់ដល់ការអនុវត្តកម្មវិធីកែទម្រង់។ | **មធ្យម** | - កសហវ<br>- ក្រសួង-ស្ថាប័ន | - ពិនិត្យមើលឡើងវិញប្រព័ន្ធផ្តល់ការលើកទឹកចិត្តរយៈពេលកន្លងមកនិងរៀបចំឱ្យមានប្រព័ន្ធផ្តល់ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និង/ ឬ មិនមែនហិរញ្ញវត្ថុ ប្រកបដោយសមធម៌ សង្គតិភាព និងតាមឆន្ទៈនៃការបំពេញការងាររបស់មន្ត្រីពាក់ព័ន្ធ។ |
| ៨ | **ការត្រៀមលក្ខណៈសម្បត្តិគ្រប់គ្រាន់ដើម្បីអនុវត្តថវិកាកម្មវិធីពេញលេញ**<br>- កង្វះការត្រៀមលក្ខណៈឱ្យបានគ្រប់គ្រាន់របស់ក្រសួង-ស្ថាប័នក្នុងការអនុវត្តថវិកាកម្មវិធីពេញលេញ អាចជះឥទ្ធិពលអវិជ្ជមានដល់ការអនុវត្តកម្មវិធីកែទម្រង់ដំណាក់កាលទី៣ និងដំណាក់កាលបន្តបន្ទាប់ទៀត។ | **មធ្យម** | - កសហវ<br>- ក្រសួង-ស្ថាប័ន | - រៀបចំប្រជុំត្រួតពិនិត្យតាមដានវឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ជាប្រចាំ<br>- រៀបចំសិក្ខាសាលាចែករំលែកបទពិសោធន៍នៃការងារថវិកាកម្មវិធី ដោយកំណត់បញ្ហាប្រឈមឱ្យបានច្បាស់លាស់ព្រមទាំងរៀបចំយន្តការដោះស្រាយបញ្ហាប្រឈមទាំងនេះ ប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាពខ្ពស់<br>- រៀបចំសិក្ខាសាលាផ្សព្វផ្សាយគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធី, ការអនុវត្តថវិកាកម្មវិធីនិងការរៀបចំនិងការអនុវត្តរបស់អង្គភាពថវិកា |

| ល.រ | ហានិភ័យ | កម្រិតហានិភ័យ | អង្គភាពទទួលបន្ទុក | សំណើវិធានការដោះស្រាយ |
|---|---|---|---|---|
| | | | | - បន្តកែលម្អគោលការណ៍ណែនាំពាក់ព័ន្ធនឹងការរៀបចំ និងការអនុវត្តថវិកាកម្មវិធី។ |
| ៩ | **ការសម្របសម្រួល**<br>- ប្រសិទ្ធភាពសម្របសម្រួលនៃកម្មវិធីកែទម្រង់ទាំងបី (PFM, PAR, NCDD) នៅមានកម្រិត<br>- ខ្វះការសម្របសម្រួល ឬ ទំនាក់ទំនងជាប្រចាំរវាងអគ្គនាយកដ្ឋាននិងអគ្គនាយកដ្ឋានរបស់ កសហវ និង/ ឬ ក្រសួង-ស្ថាប័ន និងក្រសួង-ស្ថាប័ន<br>- ការប្រើប្រាសប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ទំនាក់ទំនងគ្នានៅមានកម្រិត | **មធ្យម** | - ក្រសួង-ស្ថាប័នពាក់ព័ន្ធ<br>- PFM, PAR, NCDD | - បង្កើនទំនាក់ទំនងសម្របសម្រួលជាប្រចាំនិងជំរុញការអនុវត្តសេចក្ដីសម្រេចរួមស្ដីពីការបង្កើតយន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ, កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥។ ក្នុងករណីចាំបាច់ត្រូវកែលម្អសេចក្ដីសម្រេចរួមនេះ។<br>- រៀបចំនិងអនុវត្តផែនការសកម្មភាពរួម ដើម្បីដោះស្រាយបញ្ហាប្រឈមនៃកំណែទម្រង់ទាំងបី<br>- រៀបចំយន្តការកាត់បន្ថយ និង/ ឬដោះស្រាយបញ្ហាត្រួតគ្នានៃកំណែទម្រង់ទាំងបី (Cross Cutting Issues)<br>- ពង្រឹងទំនាក់ទំនងជាប្រចាំរវាងថ្នាក់ដឹកនាំនិងមន្ត្រីបង្គោលក្នុងអង្គភាព និង/ឬ អន្តរក្រសួង-ស្ថាប័ន |

| ល.រ | ហានិភ័យ | កម្រិតហានិភ័យ | អង្គភាពទទួលបន្ទុក | សំណើវិធានការដោះស្រាយ |
|---|---|---|---|---|
| | | | | ក្នុងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ<br>- ជំរុញការប្រើប្រាស់ប្រព័ន្ធព័ត៌មានវិទ្យា ដើម្បីពង្រឹងទំនាក់ទំនងរបស់មន្ត្រីបង្គោលពាក់ព័ន្ធ។ |
| ១០ | **រចនាសម្ព័ន្ធក្រសួង-ស្ថាប័ន និងកម្មវិធី**<br>- រចនាសម្ព័ន្ធរបស់ក្រសួង-ស្ថាប័នមិនឆ្លើយតបតាមរចនាសម្ព័ន្ធរបស់ថវិកាកម្មវិធី<br>- តួនាទីនិងភារកិច្ចមិនច្បាស់លាស់រវាងរដ្ឋបាលថ្នាក់ជាតិ និងរដ្ឋបាលថ្នាក់ក្រោមជាតិដែលអាចប៉ះពាល់ដល់គណនេយ្យភាពនៃថវិកាកម្មវិធី | **មធ្យម** | - កសហវ<br>- ក្រសួង-ស្ថាប័ន | - ត្រួតពិនិត្យនិងកែលម្អរចនាសម្ព័ន្ធក្រសួង-ស្ថាប័នដើម្បីឆ្លើយតបនឹងរចនាសម្ព័ន្ធរបស់ថវិកាកម្មវិធី<br>- កំណត់បន្ទាត់គណនេយ្យភាពរវាងរដ្ឋបាលថ្នាក់ជាតិនិងរដ្ឋបាលថ្នាក់ក្រោមជាតិ, ពង្រឹងការរៀបចំផែនការយុទ្ធសាស្ត្រថវិកានិងការអនុវត្តគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ<br>- ត្រួតពិនិត្យនិងកែលម្អគោលការណ៍ណែនាំស្តីពីការរៀបចំថវិកាកម្មវិធីសម្រាប់រដ្ឋបាលថ្នាក់ក្រោមជាតិ។ |
| ១១ | **ហិរញ្ញប្បទានគាំទ្រ**<br>- កង្វះហិរញ្ញប្បទានគាំទ្រ អាចជះឥទ្ធិពលអវិជ្ជមានដល់ដំណើរការអនុវត្តកម្មវិធី | **ទាប** | - ដៃគូអភិវឌ្ឍន៍<br>- រាជរដ្ឋាភិបាល | - អនុវត្តឱ្យបាននូវក្របខ័ណ្ឌវាយតម្លៃសមិទ្ធកម្ម (Performance Assessment Framework) រវាងដៃគូអភិវឌ្ឍន៍ និង រាជរដ្ឋាភិបាល |

| ល.រ | ហានិភ័យ | កម្រិតហានិភ័យ | អង្គភាពទទួលបន្ទុក | សំណើវិធានការដោះស្រាយ |
| --- | --- | --- | --- | --- |
| | កែទម្រង់ហិរញ្ញវត្ថុសាធារណៈ | | | - ធានាឱ្យបាននូវភាពទុកជឿទុកចិត្តនៃថវិកា តាមរយៈបន្តអនុវត្តយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យម ២០១៤-២០១៨ និងយុទ្ធសាស្ត្រគៀរគរចំណូលរយៈពេលមធ្យមក្រោយៗទៀត ព្រមទាំងបន្តធ្វើ វិចារណកម្មចំណាយឱ្យបានជាប្រចាំ។ |
| ១២ | **ការគាំទ្រផ្នែកនយោបាយ**<br>- កង្វះការគាំទ្រផ្នែកនយោបាយ | **ទាប** | - គ.ហ.ស.<br>- ក្រសួង-ស្ថាប័ន<br>- កសហវ | - បន្តនិរន្តភាពនៃការគាំទ្រផ្នែកនយោបាយពី គ.ហ.ស និងក្រុមការងារបច្ចេកទេសកែទម្រង់ហិរញ្ញវត្ថុសាធារណៈ។ |
| ១៣ | **ក្របខ័ណ្ឌពេលវេលាសម្រេចចក្ខុវិស័យឆ្នាំ២០២០**<br>- ក្របខ័ណ្ឌពេលវេលាខ្លី សម្រាប់ឈានទៅសម្រេចគោលដៅឆ្នាំ២០២០ នៃការកែទម្រង់ប្រព័ន្ធថវិកា<br>- ឧបករណ៍គាំទ្រមិនទាន់ដំណើរការពេញលេញ ឬនៅមានកង្វះចន្លោះ ដូចជាប្រព័ន្ធ FMIS, លិខិតបទដ្ឋានគតិយុត្ត នីតិវិធីនិង | **ទាប** | - កសហវ<br>- ក្រសួង-ស្ថាប័ន | - បង្កើនការតាមដានលើការគ្រប់គ្រងហានិភ័យពាក់ព័ន្ធ<br>- បន្តពង្រឹងការផ្សព្វផ្សាយពីការងារពាក់ព័ន្ធនឹងកម្មវិធីកែទម្រង់ និងអនុវត្តនូវសំណើវិធានការដោះស្រាយនានាលើហានិភ័យពាក់ព័ន្ធដែលអាចបង្កឱ្យមានភាពរាំងស្ទះដល់ការសម្រេចចក្ខុវិស័យវែងឆ្ងាយនៃកម្មវិធីកែទម្រង់តាមកាលកំណត់។ |

| ល.រ | ហានិភ័យ | កម្រិតហានិភ័យ | អង្គភាពទទួលបន្ទុក | សំណើវិធានការដោះស្រាយ |
|---|---|---|---|---|
| | គោលការណ៍ណែនាំពាក់ព័ន្ធផ្សេងទៀត<br>- បទពិសោធន៍និងសមត្ថភាពនៅមានកម្រិត | | | |

## ៨. សេចក្តីសន្និដ្ឋាន

ការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ចាប់តាំងពីឆ្នាំ២០០៤ រហូតមកដល់ពេលនេះ បានរំលេចឱ្យឃើញអំពីបទពិសោធន៍និងកាតាលីករសម្រាប់ធានាជោគជ័យនៃការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

### ៨.១. បទពិសោធន៍

ដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រយៈពេលជាង ១០ ឆ្នាំ កន្លងមកនេះ បានផ្តល់នូវបទពិសោធន៍ក្នុងការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃ ដូចតទៅ÷

- ក្រសួង ស្ថាប័ន និងអង្គភាពដែលមានផែនការសកម្មភាព និងសូចនាករសមស្រប និងច្បាស់លាស់ គឺងាយស្រួលក្នុងការតាមដានត្រួតពិនិត្យ និងមានការអនុវត្តបានល្អព្រមទាំងមានសមិទ្ធកម្មល្អ។
- ក្រសួង ស្ថាប័ន និងអង្គភាពដែលមានការដឹកនាំនិងការគ្រប់គ្រងល្អ ព្រមទាំងមានការតម្រង់ទិសនិងគាំទ្រផ្នែកនយោបាយ (កម្រិតថ្នាក់ដឹកនាំក្រសួង-ស្ថាប័ន) គឺមានសមិទ្ធកម្មល្អ។
- ការចាត់តាំងមន្ត្រីបានសមស្របរវាងសមត្ថភាពនិងមុខងារ (ចាត់តាំងមនុស្សត្រូវ និងរើសឱ្យទៅរៀនត្រូវ) បង្កើនផលិតភាពនិងប្រសិទ្ធភាពការងាររបស់អង្គភាព។
- ការបណ្តុះបណ្តាលតាមវិធីបណ្តុះគ្រូបង្គោលឱ្យបណ្តុះបណ្តាលបន្ត បាននិងកំពុងបង្ហាញថាមានប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព ទាំងក្នុងក្របខ័ណ្ឌផ្ទៃក្នុងអង្គភាព, អន្តរអង្គភាព និងអន្តរក្រសួង-ស្ថាប័ន។
- ការកំណត់មុខងារនិងភារកិច្ចបានច្បាស់លាស់ បានរួមចំណែកបង្កើនផលិតភាពនិងសមិទ្ធកម្មរបស់មន្ត្រី។
- ការរៀបចំនិងដាក់ចេញនូវផែនការប្រតិបត្តិច្បាស់លាស់សម្រាប់អង្គភាព រួមចំណែកបង្កើនផលិតភាពនិងសមិទ្ធកម្មរបស់មន្ត្រីនិងអង្គភាព។
- ការរៀបចំឱ្យមានលក្ខខណ្ឌយោងសម្រាប់បុគ្គលិក រួមចំណែកបង្កើនផលិតភាពនិងសមិទ្ធកម្មរបស់មន្ត្រី។

## ៨.២. កត្តាកំណត់ជោគជ័យ

ជោគជ័យនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ពឹងផ្អែកលើកត្តា ដូចតទៅ ÷

- **ភាពជាម្ចាស់ និង ភាពជាអ្នកដឹកនាំលើការងារកែទម្រង់ គួរតែកំណត់ទុកជាបុរេលក្ខណៈសម្បត្តិសម្រាប់តួនាទីជាថ្នាក់ដឹកនាំនីមួយៗនៃក្រសួង-ស្ថាប័ន÷** ក្រសួង-ស្ថាប័ន ចាំបាច់ត្រូវតែពង្រឹងយន្តការដឹកនាំ គ្រប់គ្រង និងសម្របសម្រួល ព្រមទាំងបង្កើនឆន្ទៈ ការប្តេជ្ញាចិត្ត និងការទទួលខុសត្រូវខ្ពស់ចំពោះការងារកែទម្រង់។
- **អភិក្រមការងារក្នុងបរិការណ៍កែទម្រង់ គួរតែផ្លាស់ មកជាបុរេសកម្ម សកម្ម និងអន្តរសកម្មក្នុងគោលបំណងបង្កើតនិងបង្កើនកាលានុវត្តភាពអភិវឌ្ឍន៍ថ្មីៗ ÷** ពោលគឺត្រៀមចាត់វិធានការបង្ការទប់ស្កាត់បញ្ហា ដោះស្រាយបញ្ហាដែលកើតមាន និងបង្កើនការប្រាស្រ័យទាក់ទងគ្នារួមគ្នាដោះស្រាយបញ្ហាចំពោះមុខ សម្លឹងឆ្ពោះទៅរកជោគជ័យទាំងអស់គ្នា។
- **តួអង្គពាក់ព័ន្ធការសម្រេចសមិទ្ធកម្មកែទម្រង់ គួរត្រូវបានលើកទឹកចិត្តសមស្របផ្នែកហិរញ្ញវត្ថុ និងគុណបំណាច់នានា÷** ដើម្បីឆ្លើយតបនឹងគុណបំណាច់ក្នុងការលះបង់ពេលវេលាផ្ទាល់ខ្លួនលើសពីការងារប្រចាំថ្ងៃសម្រាប់ការងារកែទម្រង់ ក្រសួង-ស្ថាប័នត្រូវផ្តល់នូវការលើកទឹកចិត្តដល់មន្ត្រីគ្រប់លំដាប់ថ្នាក់ ទាំងផ្នែកហិរញ្ញវត្ថុ និងផ្នែកគុណបំណាច់ ដូចជាការបណ្តុះបណ្តាល ប័ណ្ណសរសើរ និងអាទិភាពក្នុងការដំឡើងតួនាទី។

# បញ្ជីឧបសម្ព័ន្ធ

# បញ្ជីឧបសម្ព័ន្ធ


**ឧបសម្ព័ន្ធ ១.** ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ឧបសម្ព័ន្ធ ២.** អនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ឧបសម្ព័ន្ធ ៣.** អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ឧបសម្ព័ន្ធ ៤.** សារាចររាជរដ្ឋាភិបាល លេខ ០៩ សរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥ ស្តីពីវិធាន និងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ឧបសម្ព័ន្ធ ៥.** ប្រកាសលេខ ៦៤៩ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ឧបសម្ព័ន្ធ ៦.** ប្រកាសលេខ ៣៤៧ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ឧបសម្ព័ន្ធ ៧.** សេចក្តីសម្រេចរួមលេខ ០០៦ សហវ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥ ស្តីពីការបង្កើតយន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

**ឧបសម្ព័ន្ធ ៨.** សារាចរលេខ ០០៦ សហវ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥ ស្តីពីយន្តការដោះស្រាយបញ្ហាប្រឈម ក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ឧបសម្ព័ន្ធ ៩.** ផែនការសកម្មភាពរួម ដំណាក់កាលទី៣

**ឧបសម្ព័ន្ធ ១០.** គំរូរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស និង គំរូរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ឧបសម្ព័ន្ធ ១១.** វិធីសាស្ត្រនៃការកំណត់ទម្ងន់ និង ការវាយតម្លៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ឧបសម្ព័ន្ធ ១២.** អនុសាសន៍កែលម្អកង្វះខាតនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PEFA)

# ឧបសម្ព័ន្ធ ១.

## ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

ព្រះរាជក្រឹត្យ

នស/រកត/១២១៣/១៤៤៤

ស្តីពី

ការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

យើង

ព្រះករុណាព្រះបាទសម្តេចព្រះបរមនាថ នរោត្តម សីហមុនី

សមានភូមិជាតិសាសនា រក្ខតខត្តិយា ខេមរារដ្ឋរាស្ត្រ ពុទ្ធិន្ទ្រាធរាមហាក្សត្រ

ខេមរាជនា សមូហោភាស កម្ពុជឯករាជរដ្ឋបូរណសន្តិ សុភមង្គលា សិរីវិបុលា

ខេមរាស្រីពិរាស្ត្រ ព្រះចៅក្រុងកម្ពុជាធិបតី

- បានទ្រង់យល់រដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានទ្រង់យល់ព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានទ្រង់យល់ព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានទ្រង់យល់សេចក្តីក្រាបបង្គំទូលថ្វាយរបស់សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា

ត្រាស់បង្គាប់

ជំពូកទី១

បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

ត្រូវបានបង្កើត គណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សរសេរជាអក្សរកាត់ថា

ROYAUME DU CAMBODGE
LE MINISTRE DU PALAIS ROYAL

**គ.ស.ហ.** មានភារកិច្ចដឹកនាំ រៀបចំ សម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយសេដ្ឋកិច្ច និងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល មានជាអាទិ៍ ការងារពាក់ព័ន្ធនឹងការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងការអភិវឌ្ឍវិស័យឯកជន, ព្រមទាំងសម្របសម្រួលរាល់កិច្ចសហប្រតិបត្តិការសម្រាប់ការអភិវឌ្ឍឬការងារកែទម្រង់ ក្នុងវិស័យសេដ្ឋកិច្ច និងហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាល ជាមួយដៃគូអភិវឌ្ឍន៍។

## ជំពូកទី២
## សមាសភាពនិងរចនាសម្ព័ន្ធ

**មាត្រា២.–**

**គ.ស.ហ.** មានសមាសភាពដូចតទៅ÷

| | |
|---|---|
| ១- ឧបនាយករដ្ឋមន្ត្រី មួយរូប | ប្រធាន |
| ២- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | អនុប្រធានប្រចាំការ |
| ៣- ទេសាភិបាលនៃធនាគារជាតិនៃកម្ពុជា | អនុប្រធាន |
| ៤- ប្រធានឧត្តមក្រុមប្រឹក្សាសេដ្ឋកិច្ចជាតិ ឬតំណាង | អនុប្រធាន |
| ៥- រដ្ឋមន្ត្រីក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ | សមាជិក |
| ៦- រដ្ឋមន្ត្រីក្រសួងពាណិជ្ជកម្ម | សមាជិក |
| ៧- រដ្ឋមន្ត្រីក្រសួងឧស្សាហកម្មនិងសិប្បកម្ម | សមាជិក |
| ៨- រដ្ឋមន្ត្រីក្រសួងរ៉ែនិងថាមពល | សមាជិក |
| ៩- រដ្ឋមន្ត្រីក្រសួងផែនការ | សមាជិក |
| ១០- រដ្ឋមន្ត្រីក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់ | សមាជិក |
| ១១- រដ្ឋមន្ត្រីក្រសួងធនធានទឹកនិងឧតុនិយម | សមាជិក |
| ១២- រដ្ឋមន្ត្រីក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ | សមាជិក |
| ១៣- រដ្ឋមន្ត្រីក្រសួងសាធារណការនិងដឹកជញ្ជូន | សមាជិក |
| ១៤- រដ្ឋមន្ត្រីក្រសួងទេសចរណ៍ | សមាជិក |
| ១៥- រដ្ឋលេខាធិការទីស្តីការគណៈរដ្ឋមន្ត្រី មួយរូប | សមាជិក |
| ១៦- អគ្គលេខាធិការក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | សមាជិក។ |

**គ.ស.ហ.** អាចមានសមាសភាពបន្ថែម ជារដ្ឋមន្ត្រី ប្រធានស្ថាប័ន ឬតំណាងនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត នៃរាជរដ្ឋាភិបាល តាមការចាំបាច់។

សមាសភាពជាក់ស្តែងនៃ **គ.ស.ហ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣.–**

ក្នុងការបំពេញភារកិច្ចដូចមានចែងក្នុងមាត្រា១ **គ.ស.ហ.** មានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ និងគណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន ជាសសរស្តម្ភ សម្រាប់ជួយដឹកនាំ រៀបចំ សម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ ឬកម្មវិធីនិង/ឬផែនការអភិវឌ្ឍសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ របស់រាជរដ្ឋាភិបាល ព្រមទាំងសម្រាប់ជួយសម្របសម្រួលជាមួយដៃគូអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ។

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបង្កើតឡើងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីប្រធាន គ.ស.ហ.។

គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យហិរញ្ញវត្ថុ ត្រូវបង្កើតឡើងដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីប្រធាន គ.ស.ហ.។

គណៈកម្មាធិការដឹកនាំការងារអភិវឌ្ឍវិស័យឯកជន ត្រូវបង្កើតឡើងដោយអនុក្រឹត្យ តាមសំណើរបស់អនុប្រធានទី១ នៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា បន្ទាប់ពីមានការឯកភាពពីប្រធាន គ.ស.ហ.។

គ.ស.ហ. អាចមានគណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងារផ្សេងទៀត ដើម្បីបម្រើឱ្យការងារគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ តាមតម្រូវការចាំបាច់។ គណៈកម្មាធិការ អនុគណៈកម្មាធិការ ឬក្រុមការងាររបស់ គ.ស.ហ. ត្រូវបង្កើតឡើងដោយអនុក្រឹត្យ ឬសេចក្ដីសម្រេចរបស់រាជរដ្ឋាភិបាល តាមសំណើរបស់ប្រធាន គ.ស.ហ.។

## ជំពូកទី៣
## ដំណើរការការងារ

**មាត្រា៤.–**

តាមការអញ្ជើញរបស់ប្រធាន សមាជិក និងអនុប្រធាន គ.ស.ហ. ត្រូវចូលរួមប្រជុំ ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំ ក្នុងករណីអវត្តមាន ឬមានធុរៈ។

ក្នុងករណីប្រធានអវត្តមានឬមានធុរៈ អនុប្រធានប្រចាំការ បំពេញមុខងារជាប្រធានស្ដីទី លើការងារអញ្ជើញនិងដឹកនាំការប្រជុំរបស់ គ.ស.ហ.។

គ.ស.ហ. ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងារ។

**មាត្រា៥.–**

ប្រធាន គ.ស.ហ. មានសិទ្ធិអញ្ជើញប្រធានស្ថាប័ន ឬតំណាងរបស់ប្រធានស្ថាប័ន ឬអាជ្ញាធរ ព្រមទាំងមន្ត្រីបច្ចេកទេសនៃក្រសួង ស្ថាប័នពាក់ព័ន្ធផ្សេងទៀត ចូលរួមប្រជុំនិងបំពេញការងារ ស្របតាមបទប្បញ្ញត្តិដែលមានចែងក្នុងព្រះរាជក្រឹត្យនេះ។

**មាត្រា៦.–**

គ.ស.ហ. ព្រមទាំងគណៈកម្មាធិការដឹកនាំការងារកែទម្រង់ ឬអភិវឌ្ឍតាមវិស័យ អនុគណៈកម្មាធិការ និងក្រុមការងារបច្ចេកទេស មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន តំណាងសង្គមស៊ីវិល ទីប្រឹក្សា ឬអ្នកជំនាញការជាតិ និងអន្តរជាតិ ចូលរួមប្រជុំ ក្នុងឋានៈជាសមាជិក អ្នកសង្កេតការណ៍ ឬអ្នកផ្ដល់យោបល់ តាមការចាំបាច់។

**មាត្រា៧.–**

គ.ស.ហ. មានអគ្គលេខាធិការដ្ឋានមួយ ជាសេនាធិការ សម្រាប់បំពេញមុខងាររបស់ខ្លួន។

[illegible]យកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បំពេញ[illegible]បន្ថែម[illegible]អគ្គលេខាធិការដ្ឋាន គ.ស.ហ.។

**[illegible].–**

[illegible]បំពេញមុខងាររបស់ខ្លួន អគ្គលេខាធិការដ្ឋាន គ.ស.ហ. មានភារកិច្ចសម្របសម្រួលការរៀបចំនិងការ

អនុវត្តការងារគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចតទៅ÷

- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ គ.ស.ហ. ស្របតាមការណែនាំនិងការសម្រេចរបស់ គ.ស.ហ.
- សហការ និងសម្របសម្រួលជាមួយក្រសួង ស្ថាប័ន និងអង្គភាពនានារបស់រាជរដ្ឋាភិបាល ដៃគូអភិវឌ្ឍន៍ និងអ្នកពាក់ព័ន្ធនានា ក្នុងការអនុវត្ត ការតាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល
- រៀបចំ និងចាត់ចែងកិច្ចប្រជុំទាំងអស់របស់ គ.ស.ហ. តាមការណែនាំរបស់ប្រធាន គ.ស.ហ.
- សម្របសម្រួល និងរៀបចំកិច្ចពិគ្រោះយោបល់នានា ទាំងកម្រិតជាតិ និងអន្តរជាតិអំពីគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុរបស់រាជរដ្ឋាភិបាល និង
- បំពេញការងារផ្សេងទៀតតាមការកំណត់របស់ គ.ស.ហ.។

## ជំពូកទី៤
## អវសានប្បញ្ញត្តិ

**មាត្រា៩.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងព្រះរាជក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១០.-**

សម្តេចអគ្គមហាសេនាបតីតេជោ **ហ៊ុន សែន** នាយករដ្ឋមន្ត្រីនៃព្រះរាជាណាចក្រកម្ពុជា ត្រូវទទួលបន្ទុកអនុវត្តព្រះរាជក្រឹត្យនេះ ចាប់ពីថ្ងៃឡាយព្រះហស្តលេខាតទៅ។

ធ្វើនៅព្រះបរមរាជវាំង ថ្ងៃទី៣១ ខែ ធ្នូ ឆ្នាំ២០១៣

៧ទស.១៣១២.១៤៦៣

**នរោត្តម សីហមុនី**

បានយកសេចក្តីក្រាបបង្គំទូលថ្វាយព្រះមហាក្សត្រ

សូមឡាយព្រះហស្តលេខា

**នាយករដ្ឋមន្ត្រី**

[illegible]

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

# ឧបសម្ព័ន្ធ ២.

## អនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤

## ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់

## ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ព្រះរាជាណាចក្រកម្ពុជា**

**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**

**លេខ:** ៧៣ អនក្រ.បក

**អនុក្រឹត្យ**

**ស្តីពី**

**ការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**រាជរដ្ឋាភិបាល**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**សម្រេច**

**ជំពូកទី១**

**បទប្បញ្ញត្តិទូទៅ**

**មាត្រា១.-**

ត្រូវបានបង្កើត "**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" សរសេរជាអក្សរកាត់ថា "**គ.ហ.ស.**"។

**គ.ហ.ស.** មានភារកិច្ចដឹកនាំ រៀបចំ សម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការជាមួយដៃគូអភិវឌ្ឍន៍ដែលមានការពាក់ព័ន្ធ។

## ជំពូកទី២
## សមាសភាពនិងរចនាសម្ព័ន្ធ

**មាត្រា២.-**

**គ.ហ.ស.** មានសមាសភាពដូចតទៅ÷

| | | |
|---|---|---|
| ១- រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | ប្រធាន |
| ២- រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | មួយរូប | អនុប្រធានប្រចាំការ |
| ៣- ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា | មួយរូប | អនុប្រធាន |
| ៤- រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែលមួយរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ | | សមាជិក |
| ៥- អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សមាជិក |
| ៦- ប្រធានអង្គភាពប្រតិបត្តិនៃគណៈកម្មាធិការ ដឹកនាំការងារកែទម្រង់ដែលមានការពាក់ព័ន្ធផ្សេងទៀត | | សមាជិក |
| ៧- អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការ ដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | | សមាជិកអចិន្ត្រៃយ៍។ |

សមាសភាពជាក់ស្តែងនៃ **គ.ហ.ស.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល។

**មាត្រា៣.-**

ដើម្បីធានាប្រសិទ្ធភាពនិងភាពស័ក្តិសិទ្ធិនៃការបំពេញភារកិច្ចរបស់ **គ.ហ.ស.** ដូចមានចែងក្នុងមាត្រា១ នៃអនុក្រឹត្យនេះ គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពដែលមានការពាក់ព័ន្ធ ត្រូវរៀបចំបង្កើត "**ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" មួយនៅក្នុងក្រសួង ស្ថាប័ន និងអង្គភាពរបស់ខ្លួន។ ក្រុមការងារនេះ ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់តំណាងនៃក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ដែលជាសមាជិក **គ.ហ.ស.**។

ប្រធាន **គ.ហ.ស.** ត្រូវរៀបចំសេចក្តីណែនាំស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រុមការងារនេះ ជូនដល់គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ។

ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបង្កើត "**គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**" មួយដែលត្រូវស្ថិតក្រោមការដឹកនាំផ្ទាល់របស់ប្រធាន **គ.ហ.ស.** ដើម្បីសម្របសម្រួលការរៀបចំ ការអនុវត្ត ការតាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងក្របខណ្ឌនៃសមត្ថកិច្ចផ្ទាល់របស់ក្រសួង។

## ជំពូកទី៣
## ដំណើរការការងារ

**មាត្រា៤.-**

តាមការអញ្ជើញរបស់ប្រធាន សមាជិក និងអនុប្រធាន **គ.ហ.ស.** ត្រូវចូលរួមប្រជុំ ឬចាត់តាំងតំណាងដែលមានសិទ្ធិសម្រេចជំនួស ដើម្បីចូលរួមប្រជុំ ក្នុងករណីអវត្តមាន ឬមានធុរៈ។

**មាត្រា៥.-**

**គ.ហ.ស.** មានសិទ្ធិអញ្ជើញមន្ត្រីផ្សេងទៀតនៃក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ចូលរួមប្រជុំ តាមការចាំបាច់។

**គ.ហ.ស.** មានសិទ្ធិអញ្ជើញតំណាងដៃគូអភិវឌ្ឍន៍ តំណាងវិស័យឯកជន និងតំណាងសង្គមស៊ីវិល ចូលរួមប្រជុំក្នុងឋានៈជាសមាជិក ឬអ្នកសង្កេតការណ៍ តាមការចាំបាច់។

**មាត្រា៦.-**

**គ.ហ.ស.** មានអគ្គលេខាធិការដ្ឋានអចិន្ត្រៃយ៍មួយ នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ជាសេនាធិការ សម្រាប់បំពេញមុខងាររបស់ខ្លួន។

ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន **គ.ហ.ស.** ត្រូវកំណត់ដោយអនុក្រឹត្យ តាមសំណើរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.**។

**គ.ហ.ស.** ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងារ។

## ជំពូកទី៤
## អន្តរប្បញ្ញត្តិ

**មាត្រា៧.-**

រចនាសម្ព័ន្ធរបស់ **គ.ហ.ស.**ដែលត្រូវបានបង្កើតឡើងដោយអនុលោមតាមសេចក្តីសម្រេចរបស់រាជរដ្ឋាភិបាល លេខ ៥៦ សសរ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ២០០៧ ត្រូវបន្តនិរន្តរភាពការងាររបស់ខ្លួន រហូតដល់មានការរៀបចំថ្មី ដោយអនុលោមតាមបទប្បញ្ញត្តិនៃអនុក្រឹត្យនេះ។

## ជំពូកទី៥
## អវសានប្បញ្ញត្តិ

**មាត្រា៨.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា៩.–**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១៧ ខែ មករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាប

ជូនសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រីសូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា៩
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៣.

## អនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤
## ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន
## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខៈ** ៧៤ .អនក្រ.បក

# អនុក្រឹត្យ
# ស្ដីពី
# ការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋាន
# គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## រាជរដ្ឋាភិបាល

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្ដីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្ដីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្ដីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ..២៣.... អនក្រ.បក ចុះថ្ងៃទី..១៧.. ខែ..មករា.. ឆ្នាំ២០១៤ ស្ដីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមសំណើរបស់ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

# សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**មាត្រា១.-**

អនុក្រឹត្យនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលសរសេរជាអក្សរកាត់ថា "**អ.គ.ហ.**"។

**អ.គ.ហ.** បំពេញមុខងារជាសេនាធិការរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលសរសេរជាអក្សរកាត់ថា **គ.ហ.ស.**។

**មាត្រា២.-**

**អ.គ.ហ.** មានទីតាំងស្ថិតនៅក្នុងទីស្ដីការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ សម្រាប់ដំណើរការការងារ។

## ជំពូកទី២

## តួនាទី និងភារកិច្ច

**មាត្រា៣.-**

ក្នុងការបំពេញមុខងាររបស់ខ្លួន **អ.គ.ហ.** មានភារកិច្ចសម្របសម្រួលការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដូចតទៅ÷

- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ **គ.ហ.ស.** ស្របតាមការណែនាំ និងការសម្រេចរបស់ **គ.ហ.ស.** ដោយរួមទាំងការរៀបចំដាក់ឱ្យអនុវត្ត និងការតាមដានត្រួតពិនិត្យគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការរៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ
- សម្របសម្រួលប្រចាំថ្ងៃ លើការងាររដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ លទ្ធកម្មសាធារណៈ និងផ្នែកភស្តុភារក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ផ្ដល់យោបល់ និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈម និងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញល្បឿន និងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សហការ និងសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាព និងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំ និងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**
- ផ្ដល់ការគាំទ្រជូន អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពនានារបស់រាជរដ្ឋាភិបាល តាមសេចក្ដីត្រូវការចាំបាច់ ដោយ

រាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត ការតាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស

- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ស្ទួចនាករកម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅតាមក្រសួង ស្ថាប័ន ដោយរាប់បញ្ចូលបច្ចុប្បន្នកម្មជាទៀងទាត់ លើការផ្គត់ផ្គង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- ផ្សព្វផ្សាយ និងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

## ជំពូកទី៣
## រចនាសម្ព័ន្ធ

**មាត្រា៤.-**

**អ.គ.ហ.** ត្រូវដឹកនាំដោយអគ្គលេខាធិការ ១រូប អមដោយអគ្គលេខាធិការរងមួយចំនួនជាជំនួយការ។

អគ្គលេខាធិការ និងអគ្គលេខាធិការរង ត្រូវតែងតាំងពីក្នុងចំណោមមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលមានគុណវុឌ្ឍិនិងបទពិសោធសមស្របតាមលក្ខខណ្ឌការងារតម្រូវ។

អគ្គលេខាធិការ ត្រូវតែងតាំងនិងបញ្ចប់តួនាទីដោយព្រះរាជក្រឹត្យ តាមសំណើរបស់ប្រធាន **គ.ហ.ស.**។

អគ្គលេខាធិការរង ត្រូវតែងតាំងនិងបញ្ចប់តួនាទីដោយអនុក្រឹត្យ តាមសំណើរបស់ប្រធាន **គ.ហ.ស.**។

**មាត្រា៥.-**

ការរៀបចំរចនាម្ព័ន្ធ និងការប្រព្រឹត្តទៅរបស់ **អ.គ.ហ.** ត្រូវកំណត់ដោយប្រកាសរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុដែលជាប្រធាន **គ.ហ.ស.**។

**មាត្រា៦.-**

មន្ត្រីបម្រើការងារក្នុង **អ.គ.ហ.** ត្រូវជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងពីក្រសួង ស្ថាប័នដែលអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។ ក្នុងករណីចាំបាច់ មន្ត្រីបម្រើការងារក្នុង **អ.គ.ហ.** អាចជ្រើសរើសពីក្នុងចំណោមមន្ត្រីរាជការនៃមុខងារសាធារណៈ ដោយផ្អែកលើគោលការណ៍សមត្ថភាព តម្លាភាព និងការប្រកួតប្រជែងបើកទូលាយ។

**មាត្រា៧.-**

លើកលែងអគ្គលេខាធិការនិងអគ្គលេខាធិការរង មន្ត្រីរាជការដែលត្រូវបានជ្រើសរើសឱ្យបម្រើការងារក្នុង **អ.គ.ហ.** ត្រូវបំពេញលក្ខខណ្ឌដូចតទៅ ÷

- ផ្អាកការងារនៅអង្គភាពដើមជាបណ្តោះអាសន្ន
- បំពេញការងារពេញម៉ោងនៅ **អ.គ.ហ.**

- រក្សាបាននូវប្រាក់បៀវត្ស ប្រាក់បំណាច់មុខងារ ប្រាក់ឧបត្ថម្ភផ្សេងៗ ក្នុងមុខងារសាធារណៈ អតីតភាពការងារ និងមុខតំណែងនៅអង្គភាពដើម ក្នុងពេលបំពេញមុខងារនៅ **អ.គ.ហ.**
- ទទួលបានការលើកទឹកចិត្ត ដោយទទួលបានមុខតំណែងសមស្រប នៅពេលវិលត្រឡប់ទៅបំពេញការងារនៅអង្គភាពដើមវិញ។

**មាត្រា៨.-**

ដោយមានការឯកភាពពីប្រធាន **គ.ហ.ស.** អគ្គលេខាធិការនៃ **អ.គ.ហ.** អាចជ្រើសរើសទីប្រឹក្សា អ្នកជំនាញការជាតិឬអន្តរជាតិ និងបុគ្គលិកជាប់កិច្ចសន្យាផ្សេងទៀត ដើម្បីជួយដល់ការងារ **អ.គ.ហ.**។

ការជ្រើសរើស ត្រូវអនុលោមតាមបទប្បញ្ញត្តិជាធរមាន។

## ជំពូកទី៤

## កិច្ចដំណើរការនិងថវិកា

**មាត្រា៩.-**

**អ.គ.ហ.** មានកញ្ចប់ថវិកាផ្ទាល់ដោយឡែក សម្រាប់គាំទ្រកិច្ចដំណើរការរបស់ខ្លួន។

កញ្ចប់ថវិការបស់ **អ.គ.ហ.** មានប្រភពមកពី÷

- ថវិការដ្ឋដែលជាកញ្ចប់មួយនៅក្នុងថវិការបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ថវិកាផ្តល់ដោយដៃគូអភិវឌ្ឍន៍ និងពីប្រភពផ្សេងៗទៀត។

ថវិកាប្រចាំឆ្នាំរបស់ **អ.គ.ហ.** ត្រូវសម្រេចដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ផ្អែកតាមសំណើរបស់អគ្គលេខាធិការនៃ **អ.គ.ហ..**។

## ជំពូកទី៥

## អន្តរប្បញ្ញត្តិ

**មាត្រា១០.-**

លេខាធិការដ្ឋាននៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានបង្កើតឡើងដោយប្រកាសលេខ ១០០១ សហវ.ប្រក ចុះថ្ងៃទី០៨ ខែតុលា ឆ្នាំ២០០៨ ត្រូវបន្តនិរន្តរភាពការងាររបស់ខ្លួន រហូតដល់មានការរៀបចំ **អ.គ.ហ.** ស្របតាមខ្លឹមសារនៃអនុក្រឹត្យនេះ។

## ជំពូកទី៦

## អវសានប្បញ្ញត្តិ

**មាត្រា១១.-**

បទប្បញ្ញត្តិទាំងឡាយណាដែលមានខ្លឹមសារផ្ទុយពីអនុក្រឹត្យនេះ ត្រូវទុកជានិរាករណ៍។

**មាត្រា១២.-**

រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី ប្រធានគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រដ្ឋមន្ត្រីគ្រប់ក្រសួង និងប្រធានគ្រប់ស្ថាប័ន ដែលពាក់ព័ន្ធ ត្រូវទទួលបន្ទុកអនុវត្តអនុក្រឹត្យនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញថ្ងៃទី ១៧ ខែមករា ឆ្នាំ២០១៤

**នាយករដ្ឋមន្ត្រី**

**សម្តេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

បានយកសេចក្តីគោរពជម្រាប

ជូនសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី សូមហត្ថលេខា

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល:**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោនាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវឧបនាយករដ្ឋមន្ត្រី
- ដូចមាត្រា១២
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៤.

## សារាចររាជរដ្ឋាភិបាល លេខ ០៩ សរ ចុះថ្ងៃទី០៨ ខែធ្នូ ឆ្នាំ២០១៥
## ស្តីពីវិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន
## និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

**រាជរដ្ឋាភិបាលកម្ពុជា**
**លេខ :**......០៩......សរ.ជ.

**សារាចរ**

**ស្តីពី**

**វិធាននិងនីតិវិធីនៃការរៀបចំ ការអនុវត្ត ការត្រួតពិនិត្យតាមដាន**
**និងការវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានប្រកាសដាក់ឱ្យអនុវត្តនៅខែធ្នូ ឆ្នាំ២០០៤ សម្រាប់រយៈពេលវែង ក្នុងគោលដៅប្រែក្លាយប្រព័ន្ធហិរញ្ញវត្ថុសាធារណៈកម្ពុជា ទៅជាប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ស្របតាមស្តង់ដារ និងឧត្តមានុវត្តន៍អន្តរជាតិ ដែលមានលក្ខណៈវិមជ្ឈការ ផ្តោតលើធាតុចេញ និងសមិទ្ធកម្ម នៅឆ្នាំ២០២៥ តាមរយៈការអនុវត្តអភិក្រមបោះជំហាន តាមដំណាក់កាល ដូចខាងក្រោម÷

- ដំណាក់កាលទី១ : "ភាពជឿទុកចិត្តបាននៃថវិកា" ពីឆ្នាំ២០០៥ ដល់ឆ្នាំ២០០៨,
- ដំណាក់កាលទី២ : "គណនេយ្យភាពហិរញ្ញវត្ថុ" ពីឆ្នាំ២០០៩ ដល់ឆ្នាំ២០១៥,
- ដំណាក់កាលទី៣ : "ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ" ពីឆ្នាំ២០១៦ ដល់ឆ្នាំ២០២០ និង
- ដំណាក់កាលទី៤ : "គណនេយ្យភាពចំពោះសមិទ្ធកម្ម" ពីឆ្នាំ២០២១ ដល់ឆ្នាំ២០២៥។

ដំណាក់កាលនីមួយៗ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវអនុវត្តផែនការសកម្មភាពរួម ដែលត្រូវបានអនុម័តនិងដាក់ឱ្យអនុវត្តដោយរាជរដ្ឋាភិបាល តាមសំណើរបស់ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលហៅកាត់ថា "**គ.ហ.ស.**" ដើម្បីក្រសួង-ស្ថាប័ននីមួយៗ រៀបចំនិងអនុវត្តផែនការសកម្មភាពលម្អិត ដោយមានសង្គតិភាពនិងបូរណភាព ជាមួយនឹងផែនការសកម្មភាពរួម។

អនុលោមតាមមាត្រា ៣ នៃអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ, គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពដែលមានការពាក់ព័ន្ធ ត្រូវរៀបចំបង្កើត "ក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ" មួយ ដែលហៅកាត់ថា "**ក.ហ.ស.**" នៅក្នុងក្រសួង ស្ថាប័ន និងអង្គភាពរបស់ខ្លួន។

ដើម្បីធានាសង្គតិភាពនិងសមានគតិភាពនៃការរៀបចំ ប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃការអនុវត្ត ព្រមទាំង សុក្រឹតភាពនិងភាពទាន់ពេលនៃការត្រួតពិនិត្យតាមដាននិងវាយតម្លៃលើការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រាជរដ្ឋាភិបាល ធ្វើការណែនាំដល់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគ្រប់ក្រសួង-ស្ថាប័ន ដែលចូលរួមក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នូវយន្តការ វិធាន និងនីតិវិធី ដូចតទៅ÷

**ក. យន្តការស្ថាប័ន**

**គ.ហ.ស.** នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នីមួយៗ ត្រូវមានសមាសភាព ដូចតទៅ÷

**ក.១. សមាសភាព គ.ហ.ស. នៅតាមក្រសួង-ស្ថាប័ន**

**ក.១.១. ប្រធាន គ.ហ.ស.**

**គ.ហ.ស.** ត្រូវស្ថិតនៅក្រោមការដឹកនាំផ្ទាល់របស់តំណាងនៃក្រសួង-ស្ថាប័ន ០១ រូប ដែលជាសមាជិក **គ.ហ.ស.** ដែលត្រូវជារដ្ឋលេខាធិការ ឬ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំមួយរូប ដែលទទួលបន្ទុកជួយរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័ន ផ្ទាល់លើការងារហិរញ្ញវត្ថុ របស់ក្រសួង-ស្ថាប័ន។

**ក.១.២. អនុប្រធាន គ.ហ.ស.**

ក្រសួង-ស្ថាប័ន នីមួយៗ ត្រូវចាត់តាំងឱ្យមានអនុប្រធាន **គ.ហ.ស.** ០១ រូប ដែលជាអនុរដ្ឋលេខាធិការ ឬ អគ្គលេខាធិការ ឬ អគ្គនាយកទទួលបន្ទុកហិរញ្ញវត្ថុ ឬថ្នាក់ដឹកនាំដែលបំពេញការងារផ្ទាល់ជាមួយប្រធាន **គ.ហ.ស.**។

**ក.១.៣. សមាជិក គ.ហ.ស.**

ក្រសួង-ស្ថាប័ន នីមួយៗ ត្រូវចាត់តាំងសមាជិក នៃ **គ.ហ.ស.** ដែលមានសមាសភាព ដូចតទៅ÷

- តំណាង ០១ រូប នៃគ្រប់អគ្គនាយកដ្ឋាន ឬ គ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រោមឱវាទក្រសួង-ស្ថាប័នផ្ទាល់ និង
- តំណាង ០១ រូប នៃគ្រប់គ្រឹះស្ថានសាធារណៈរដ្ឋបាល និងសហគ្រាសសាធារណៈ ដែលស្ថិតនៅក្រោមអាណាព្យាបាលបច្ចេកទេស នៃក្រសួង-ស្ថាប័នសាមី នីមួយៗ។

**ក.១.៤. លេខាធិការ គ.ហ.ស.**

ក្រសួង-ស្ថាប័ន នីមួយៗ ត្រូវចាត់តាំងឱ្យមានលេខាធិការ **គ.ហ.ស.** ០១ រូប ឬមួយចំនួន តាមការចាំបាច់ ដែលជាមន្ត្រីបង្គោលតែងតាំងដោយរដ្ឋមន្ត្រី ឬ ប្រធានស្ថាប័ន ស្របតាមសំណើនិងលក្ខខណ្ឌយោងការងារ ដែលកំណត់ដោយប្រធាន **គ.ហ.ស.**។

សមាសភាពជាក់ស្តែង នៃ **គ.ហ.ស.** ត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមីនីមួយៗ ដោយមានការឯកភាពពីប្រធាន **គ.ហ.ស.**។

កិច្ចដំណើរការនៃ **គ.ហ.ស.** នៅតាមក្រសួង-ស្ថាប័ន នីមួយៗ ត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន។

**ក.២. សមាសភាព គ.ហ.ស. នៅក្នុងក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំបង្កើត **គ.ហ.ស.** នៅតាមសាមីអង្គភាព នីមួយៗ ដែលត្រូវមានសមាសភាពដូចតទៅ÷

| | | |
|---|---|---|
| - អគ្គលេខាធិការ/អគ្គនាយក/អគ្គាធិការ | | ប្រធាន |
| - អគ្គលេខាធិការរង/អគ្គនាយករង/អគ្គាធិការរង | ០១រូប | អនុប្រធានប្រចាំការ |
| - អគ្គលេខាធិការរង/អគ្គនាយករង/អគ្គាធិការរង | ០១ ឬ ច្រើនរូប | អនុប្រធាន |
| - ប្រធាននាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទ | ០១ ឬ ច្រើនរូប | សមាជិក |

- មន្ត្រីជំនាញពាក់ព័ន្ធក្រោមឱវាទ 				០១ ឬ ច្រើនរូប 	សមាជិក
- មន្ត្រីបង្គោល ដែលជាអ្នកទទួលបន្ទុកហិរញ្ញវត្ថុសម្រាប់
  អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអគ្គាធិការដ្ឋាន 	០១ ឬច្រើនរូប 	លេខាធិការ។

អគ្គនាយកដ្ឋាន ដែលមានមន្ត្រីបង្គោលច្រើនរូប អាចរៀបចំបង្កើតជាក្រុមមន្ត្រីបង្គោលបាន តាមសេចក្តីត្រូវការចាំបាច់ជាក់ស្តែង ដើម្បីសម្របសម្រួលការងារផ្ទៃក្នុង និងជាមួយអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលហៅកាត់ថា "**អ.គ.ហ.**"។

សមាសភាពជាក់ស្តែង នៃ **គ.ហ.ស.** នៅតាមអង្គភាពក្រោមឱវាទនីមួយៗ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវតែងតាំងដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

កិច្ចដំណើរការនៃ **គ.ហ.ស.** នៃអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវកំណត់ដោយប្រធាន **គ.ហ.ស.** នីមួយៗ។

**៦. វិធាននិងនីតិវិធី នៃការរៀបចំផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ក្រសួង ស្ថាប័ន និងអង្គភាពនីមួយៗ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំផែនការសកម្មភាពលម្អិតអនុលោមតាមក្របខ័ណ្ឌផែនការសកម្មភាពរួម សម្រាប់ដំណាក់កាលនីមួយៗ នៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**៦.១. ការរៀបចំផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង-ស្ថាប័ន**

**គ.ហ.ស.** នៅតាមក្រសួង-ស្ថាប័ននីមួយៗ មានភារកិច្ចសម្របសម្រួលនិងប្រមូលសរុបផែនការសកម្មភាព ពីគ្រប់អគ្គនាយកដ្ឋាន នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ រួចផ្ញើមក **អ.គ.ហ.** ដើម្បីពិនិត្យ ផ្តល់យោបល់ និងកែលម្អ។

ផែនការសកម្មភាព របស់ក្រសួង-ស្ថាប័ននីមួយៗ ត្រូវចុះហត្ថលេខាដាក់ឱ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមីនីមួយៗ បន្ទាប់ពីមានការឯកភាពពីប្រធាន **គ.ហ.ស.** និងត្រូវផ្ញើជូនប្រធាន **គ.ហ.ស.** តាមកាលកំណត់។

**៦.២. ការរៀបចំ ផែនការសកម្មភាព របស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**

**គ.ហ.ស.** នៃអង្គភាពនីមួយៗ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ មានភារកិច្ចសម្របសម្រួលលើការរៀបចំនិងប្រមូលសរុបផែនការសកម្មភាព ពីគ្រប់នាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ដែលការងារនេះត្រូវដឹកនាំផ្ទាល់ដោយប្រធាន **គ.ហ.ស.** ដោយមានមន្ត្រីបង្គោល ឬ ក្រុមមន្ត្រីបង្គោលរបស់ខ្លួន ជាសេនាធិការ និងត្រូវផ្ញើមក **អ.គ.ហ.** ដើម្បីពិនិត្យ ផ្តល់យោបល់ និងកែលម្អ។

ផែនការសកម្មភាព របស់អគ្គលេខាធិការដ្ឋាន គ្រប់អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវចុះហត្ថលេខាទទួលស្គាល់ដោយប្រធានអង្គភាពនីមួយៗ និងត្រូវផ្ញើមក **អ.គ.ហ.** ប្រមូលសរុបជាផែនការសកម្មភាពរួម របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដើម្បីដាក់ជូនរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ពិនិត្យនិងពិភាក្សាក្នុងគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឬសម្រេចចុះហត្ថលេខា ដាក់ឱ្យអនុវត្តជាផ្លូវការ។

ការរៀបចំផែនការថវិកានិងការអនុវត្តថវិកា សម្រាប់ការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវអនុវត្តតាមវិធាននិងនីតិវិធីជាធរមាន ដែលត្រូវកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**គ. វិធាននិងនីតិវិធី នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ក្រសួង-ស្ថាប័ននីមួយៗ ត្រូវអនុវត្តផែនការសកម្មភាព ដែលត្រូវបានដាក់ឱ្យអនុវត្តដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័ន ដោយត្រូវសម្រេចឱ្យបាននូវសូចនាករនិងគោលដៅនៃសកម្មភាពនីមួយៗ តាមកាលកំណត់។

ដើម្បីធានាប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ យន្តការតាមដានវឌ្ឍនភាពជាប្រចាំ ត្រូវបានដាក់ឱ្យអនុវត្ត ដូចតទៅ÷

**គ.១. កិច្ចប្រជុំប្រចាំខែ**

- សម្រាប់ក្រសួង-ស្ថាប័ន÷ **ក.ហ.ស.** នៃក្រសួង-ស្ថាប័ននីមួយៗ រៀបចំកិច្ចប្រជុំប្រចាំខែរបស់ខ្លួន និងផ្ញើរបាយការណ៍ស្តីពីវឌ្ឍនភាពប្រចាំខែ តាមទម្រង់ដែលត្រូវកំណត់ដោយ **អ.គ.ហ.** មក **អ.គ.ហ.** នៅក្នុងសប្តាហ៍ទី១ នៃខែបន្ទាប់។ ក្នុងករណីចាំបាច់ មន្ត្រីជំនាញទទួលបន្ទុកពាក់ព័ន្ធនៃ **អ.គ.ហ.** អាចត្រូវបានអញ្ជើញចូលរួមក្នុងកិច្ចប្រជុំនេះ។
- សម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ÷ **ក.ហ.ស.** នៃអង្គភាពនីមួយៗ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ រៀបចំកិច្ចប្រជុំប្រចាំខែរបស់ខ្លួន ដោយមានការចូលរួមពីមន្ត្រីជំនាញទទួលបន្ទុកពាក់ព័ន្ធនៃ **អ.គ.ហ.** និងផ្ញើរបាយការណ៍ស្តីពីវឌ្ឍនភាពប្រចាំខែ តាមទម្រង់ដែលត្រូវកំណត់ដោយ **អ.គ.ហ.** មក **អ.គ.ហ.** នៅក្នុងសប្តាហ៍ទី១ នៃខែបន្ទាប់។
- កិច្ចប្រជុំប្រចាំខែរវាង **អ.គ.ហ.** ជាមួយ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំនៅក្នុងសប្តាហ៍ទី២ នៃខែបន្ទាប់ ឬ តាមការចាំបាច់ ដើម្បីពិនិត្យនិងពិភាក្សាលើវឌ្ឍនភាពប្រចាំខែ បញ្ហាប្រឈម និងសំណូមពរ ព្រមទាំងសំណើដំណោះស្រាយ ជូនប្រធាន **គ.ហ.ស.** ពិនិត្យនិងសម្រេច សម្រាប់ការអនុវត្តការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**គ.២. កិច្ចប្រជុំប្រចាំត្រីមាស**

វឌ្ឍនភាពនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានត្រួតពិនិត្យតាមដានជាប្រចាំត្រីមាស តាមរយៈកិច្ចប្រជុំ ដែលត្រូវរៀបចំក្នុងខែទីមួយ នៃត្រីមាសបន្ទាប់ ឬ តាមការចាំបាច់ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.**។ កិច្ចប្រជុំប្រចាំត្រីមាស រួមមានដូចតទៅ÷

- កិច្ចប្រជុំ នៃគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- កិច្ចប្រជុំ នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង
- កិច្ចប្រជុំ នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាមួយតំណាងដៃគូអភិវឌ្ឍន៍។

**គ.៣. ការកែសម្រួលផែនការសកម្មភាព នៅក្នុងត្រីមាសទី៣**

**ក.ហ.ស.** នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនីមួយៗក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវពិនិត្យឡើងវិញនិងអាចស្នើកែសម្រួល តាមការចាំបាច់ នូវផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន និងអង្គភាពសាមី សម្រាប់ការអនុវត្តនៅឆ្នាំបន្ទាប់ ដោយសហការនិងសម្របសម្រួលជាមួយ **អ.គ.ហ.** ដើម្បីពិនិត្យនិងផ្តល់យោបល់ ក្នុងអំឡុងត្រីមាសទី៣ នៃឆ្នាំនីមួយៗ។

ផែនការសកម្មភាពកែសម្រួល សម្រាប់ការអនុវត្តនៅឆ្នាំបន្ទាប់នេះ ត្រូវចុះហត្ថលេខាដោយរដ្ឋមន្ត្រីក្រសួង ឬប្រធានស្ថាប័នសាមី និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ បន្ទាប់ពីមានការឯកភាពពីប្រធាន **គ.ហ.ស.** និងបញ្ជូនមកប្រធាន **គ.ហ.ស.** ឱ្យបានយ៉ាងយូរត្រឹមដំណាច់ត្រីមាសទី៣។

ការកែសម្រួលផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវអនុលោមតាមវិធាននិងនីតិវិធីនៃការរៀបចំផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្នុងចំណុច “**ខ.**” ខាងលើ។

**គ.៤. កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ**

ការអនុវត្តផែនការសកម្មភាព របស់គ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នឹងត្រូវត្រួតពិនិត្យក្នុងកិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ដែលជាកិច្ចប្រជុំត្រួតពិនិត្យតាមដានកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ទូទាំងក្រសួង-ស្ថាប័ន។

កិច្ចប្រជុំត្រួតពិនិត្យប្រចាំឆ្នាំ ត្រូវរៀបចំនៅក្នុងត្រីមាសទី ១ នៃឆ្នាំបន្ទាប់ ឬ តាមពេលវេលាជាក់ស្តែង ដែលកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.**។

ខ្លឹមសារសំខាន់ៗនៃកិច្ចប្រជុំប្រចាំខែ ប្រចាំត្រីមាស និងប្រចាំឆ្នាំ ត្រូវមានកត់ត្រាក្នុងរបាយការណ៍ និងសេចក្តីសម្រេចសង្ខេបនៃកិច្ចប្រជុំ ដែលត្រូវផ្សព្វផ្សាយជូនគ្រប់ក្រសួង ស្ថាប័ន និងគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**គ.៥. យន្តការដោះស្រាយកិច្ចប្រឈមក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

ក្នុងករណីជួបប្រទះកិច្ចប្រឈមដែលតម្រូវឱ្យមានការដោះស្រាយជាចាំបាច់និងជាការប្រញាប់ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវអនុវត្តយន្តការដោះស្រាយកិច្ចប្រឈមក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលត្រូវបានកំណត់ដោយរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងជាប្រធាន **គ.ហ.ស.**។

**ឃ. វិធាននិងនីតិវិធី នៃការត្រួតពិនិត្យតាមដាននិងវាយតម្លៃ លើការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**ឃ.១. ការរៀបចំនិងបូកសរុបរបាយការណ៍សមិទ្ធកម្ម**

ចំពោះសមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំនិងបូកសរុបរបាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ព្រមទាំងត្រូវផ្ញើមក **អ.គ.ហ.** តាមកាលបរិច្ឆេទកំណត់ ដូចតទៅ÷

- របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស ÷ យ៉ាងយូរត្រឹមដំណាច់សប្តាហ៍ទីមួយ នៃត្រីមាសបន្ទាប់។
- របាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ÷ យ៉ាងយូរត្រឹមដំណាច់ខែទីមួយ នៃឆ្នាំបន្ទាប់។

របាយការណ៍សមិទ្ធកម្មប្រចាំត្រីមាស និងរបាយការណ៍សមិទ្ធកម្មប្រចាំឆ្នាំ ត្រូវរៀបចំតាមទម្រង់ ដែលកំណត់ដោយប្រធាន **គ.ហ.ស.** តាមសំណើរបស់ **អ.គ.ហ.**។

របាយការណ៍សមិទ្ធកម្ម ដែលត្រូវបានផ្ញើមក **អ.គ.ហ.** ក្រោយកាលបរិច្ឆេទកំណត់ខាងលើ អាចជាកម្មវត្ថុនៃការបដិសេធក្នុងការពិនិត្យនិងបូកសរុប ដោយ **អ.គ.ហ.**។

**ឃ.២. ការរៀបចំនិងបូកសរុបរបាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្ម**

របាយការណ៍សមិទ្ធកម្ម របស់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវរៀបចំនិងបូកសរុបជារបាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្ម ដោយ **អ.គ.ហ.** ដើម្បីដាក់ជូនកិច្ចប្រជុំនៃ **គ.ហ.ស.** ពិនិត្យនិងសម្រេច។

**ឃ.៣. ការវាយតម្លៃសមិទ្ធកម្ម**

ការវាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ មានគោលដៅវាស់វែងប្រចាំឆ្នាំ អំពីកម្រិតសមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយផ្អែកលើមូលដ្ឋាននិងវិធីសាស្ត្រ នៃការវាយតម្លៃ ដូចតទៅ÷

- **មូលដ្ឋាននៃការវាយតម្លៃ មាន ២ គឺ÷**
  ១. សកម្មភាពការងារសម្រេចបានធៀបនឹងសកម្មភាពដែលបានគ្រោងអនុវត្ត
  ២. លទ្ធផលសម្រេចបាន ធៀបនឹងគោលដៅសូចនាករសមិទ្ធកម្ម។
- **វិធីសាស្ត្រនៃការវាយតម្លៃសមិទ្ធកម្ម ផ្អែកលើការកំណត់ទម្ងន់ ជាភាគរយ (%) ដែលមាន ២ កម្រិត ដូចតទៅ÷**
  ១. កម្រិតផ្នែក គោលបំណង ចង្កោមសកម្មភាព នៃក្របខ័ណ្ឌផែនការសកម្មភាពរួម ត្រូវកំណត់ដោយ **គ.ហ.ស.**។
  ២. កម្រិតសកម្មភាពលម្អិត (កម្រិត ៣ ខ្ទង់) នីមួយៗ ត្រូវកំណត់ដោយក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ជាមួយ **អ.គ.ហ.**។

មូលដ្ឋាន រូបមន្ត និងវិធីសាស្ត្រនៃការកំណត់ទម្ងន់ និងការវាយតម្លៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវសម្រេច និងដាក់ឱ្យអនុវត្តដោយប្រធាន **គ.ហ.ស.**។

របាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្មប្រចាំត្រីមាស នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវបានផ្សព្វផ្សាយ បន្ទាប់ពីមានការសម្រេចក្នុងកិច្ចប្រជុំគណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកិច្ចប្រជុំគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

របាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្មប្រចាំឆ្នាំ នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង ស្ថាប័ន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវបានផ្សព្វផ្សាយ តាមការសម្រេចរបស់ប្រធាន **គ.ហ.ស.**។

របាយការណ៍ត្រួតពិនិត្យតាមដានសមិទ្ធកម្មប្រចាំឆ្នាំ និងរបាយការណ៍វាយតម្លៃសមិទ្ធកម្មប្រចាំឆ្នាំ នៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវផ្ញើជូននាយករដ្ឋមន្ត្រី ពិនិត្យនិងសម្រេចផ្តល់ចំណាត់ការបន្ត។

**ង. វិធានការលើកទឹកចិត្ត និងវិធានការរឹតត្បិត**

សមិទ្ធកម្មនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនីមួយៗ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវយកធ្វើជាមូលដ្ឋាននៃការពិចារណាអំពីការផ្តល់ការលើកទឹកចិត្ត និង ការរឹតត្បិត ដោយគិតគូរបន្ថែមអំពីធនធានមនុស្ស សម្ភារៈ បច្ចេកទេស និងហិរញ្ញវត្ថុ ដែលត្រូវបានផ្តល់ជូនជាមធ្យោបាយ សម្រាប់អនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

វិធានការលើកទឹកចិត្ត និង វិធានការរឹតត្បិត ចែកចេញ ជា ២ កម្រិត ដូចតទៅ÷

- កម្រិតស្ថាប័ន÷ វិធានការលើកទឹកចិត្ត និង វិធានការរឹតត្បិត អាចអនុវត្តចំពោះឥណទានថវិកាចរន្តក្នុងឆ្នាំ ដែលកំពុងដំណើរការ ឬ ចំពោះដំណើរការពិភាក្សា ឬ ចរចាឥណទានថវិកានៃឆ្នាំបន្ទាប់ សម្រាប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នីមួយៗ។
- កម្រិត **គ.ហ.ស.** ÷ វិធានការលើកទឹកចិត្ត និង វិធានការរឹតត្បិត អាចអនុវត្តចំពោះសមាសភាពនៃ **គ.ហ.ស.** នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនីមួយៗ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលអាចជាការផ្ដល់ការលើកទឹកចិត្តផ្នែកហិរញ្ញវត្ថុ និង គុណបំណាច់ ឬវិធានការរឹតត្បិតនានា តាមវិធាននិងនីតិវិធីហិរញ្ញវត្ថុជាធរមាន។

វិធានការលើកទឹកចិត្ត និង វិធានការរឹតត្បិត ជាក់ស្ដែង ត្រូវដាក់ឱ្យអនុវត្តដោយប្រធាន **គ.ហ.ស.** អនុលោមតាមការសម្រេចរបស់នាយករដ្ឋមន្ត្រី។

ទទួលបានសារាចរនេះ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងគ្រប់ក្រសួង-ស្ថាប័ន ពាក់ព័ន្ធការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ត្រូវអនុវត្តឱ្យមានប្រសិទ្ធភាព និងដោយស្មារតីទទួលខុសត្រូវខ្ពស់។

រាជធានីភ្នំពេញ ថ្ងៃទី ០៨ ខែ [illegible] ឆ្នាំ២០១៥

**នាយករដ្ឋមន្ត្រី**

**សម្ដេចអគ្គមហាសេនាបតីតេជោ ហ៊ុន សែន**

**កន្លែងទទួល ÷**

- ក្រសួងព្រះបរមរាជវាំង
- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
- អគ្គលេខាធិការដ្ឋានរដ្ឋសភា
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យសម្ដេច/ឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង-ស្ថាប័ន
- គ្រប់សាលារាជធានី ខេត្ត
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៥.

# ប្រកាសលេខ ៦៤៩ សហវ.ប្រក ចុះថ្ងៃទី១៩ ខែមិថុនា ឆ្នាំ២០១៤

# ស្តីពីការបង្កើតគណៈកម្មការកែទម្រង់ការគ្រប់គ្រង

# ហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

**ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ**

លេខ ៦២៩ សហវ.ប្រក

# ប្រកាស
# ស្តីពី
# ការបង្កើតគណៈកម្មការកែទម្រង់
# ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ ០៦/នស/៩៤ ចុះថ្ងៃទី៣០ ខែតុលា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីសហលក្ខន្តិកៈមន្ត្រីរាជការស៊ីវិលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, Khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

# សម្រេច

**ប្រការ១.–**

ត្រូវបានបង្កើត គណៈកម្មការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ “កសហវ” ដែលសរសេរជាអក្សរកាត់ថា “**គ.ក.ហ.**” ដើម្បីសម្របសម្រួលការរៀបចំ ការអនុវត្ត ការតាមដាន និងត្រួតពិនិត្យការអនុវត្ត កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៅក្នុងក្របខណ្ឌនៃសមត្ថកិច្ចផ្ទាល់របស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ២.–**

**គ.ក.ហ.** មានសមាសភាពដូចតទៅ ÷

| | | | |
|---|---|---|---|
| ១. រដ្ឋមន្ត្រី | កសហវ | | ប្រធាន |
| ២. រដ្ឋលេខាធិការ | កសហវ | ១ រូប | អនុប្រធានអចិន្ត្រៃយ៍ |
| ៣. រដ្ឋលេខាធិការ | កសហវ | ផ្សេងទៀត | អនុប្រធាន |
| ៤. អគ្គលេខាធិការ | អ.គ.ហ | | អនុប្រធានប្រចាំការ |
| ៥. អនុរដ្ឋលេខាធិការ កសហវ | | | សមាជិក |
| ៦. អគ្គលេខាធិការ | កសហវ | | សមាជិក |
| ៧. អគ្គនាយក នៃគ្រប់អគ្គនាយកដ្ឋាន កសហវ | | | សមាជិក |
| ៨. អគ្គាធិការនៃអគ្គាធិការដ្ឋាន កសហវ | | | សមាជិក។ |

សមាសភាពជាក់ស្តែងនៃ **គ.ក.ហ.** ត្រូវកំណត់ដោយសេចក្តីសម្រេចរបស់រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

**ប្រការ៣.–**

**គ.ក.ហ.** មានមុខងារនិងភារកិច្ចដូចតទៅ÷

- ធ្វើជាចំណុចប្រមូលផ្តុំរបស់ កសហវ ក្នុងការរៀបចំនិងតាមដានការអនុវត្តផែនការសកម្មភាពរបស់ កសហវ នៅក្នុងក្របខ័ណ្ឌនៃកម្មវិធីនយោបាយរបស់រាជរដ្ឋាភិបាលសម្រាប់នីតិកាលទី៥ នៃរដ្ឋសភា ព្រមទាំងសម្របសម្រួលការងារកែទម្រង់នេះ ជាមួយក្រសួង ស្ថាប័ន ពាក់ព័ន្ធ រួមទាំងរាជធានី ខេត្ត
- ពិនិត្យនិងសម្រេចលើចក្ខុវិស័យ គោលបំណង កម្មវិធី និងផែនការសកម្មភាព របស់ កសហវ ក្នុងក្របខណ្ឌការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ កសហវ
- ដឹកនាំនិងតាមដានការអនុវត្តចក្ខុវិស័យ គោលបំណង កម្មវិធី និងផែនការសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដោយធានាឱ្យបាននូវសង្គតិភាព លំដាប់លំដោយត្រឹមត្រូវ និងប្រសិទ្ធភាពខ្ពស់ នៅក្នុងកិច្ចដំណើរការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ កសហវ
- សម្របសម្រួលការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ កសហវ ជាមួយការងារកែទម្រង់ផ្សេងទៀតរបស់ រាជរដ្ឋាភិបាល
- ធ្វើជាចំនុចប្រមូលផ្តុំរបស់ កសហវ ក្នុងការកៀរគរជំនួយនិងការសម្របសម្រួលការអនុវត្តកម្មវិធីកែទម្រង់ប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ កសហវ ជាមួយដៃគូអភិវឌ្ឍន៍នានា។

**ប្រការ៤.–**

តាមការអញ្ជើញរបស់ប្រធាន អនុប្រធាននិងសមាជិក **គ.ក.ហ** ត្រូវចូលរួមប្រជុំសាមញ្ញរបស់ខ្លួនក្នុងមួយខែមួយដង ឬញឹកញាប់ជាងនេះ ទៅតាមតម្រូវការចាំបាច់នៃការងារ។

ប្រធាន **គ.ក.ហ** អាចអញ្ជើញថ្នាក់ដឹកនាំនិងមន្ត្រីជំនាញនានានៃ កសហវ ដែលមិនមែនជាសមាជិកនៃ **គ.ក.ហ.** ឱ្យចូលរួមប្រជុំ ទៅតាមតម្រូវការចាំបាច់នៃការងារ។

**ប្រការ៥.–**

ក្នុងករណីអវត្តមាន សមាជិកនៃ **គ.ក.ហ** ដែលជាអគ្គលេខាធិការ អគ្គនាយក ឬអគ្គាធិការ អាចស្នើសុំការអនុញ្ញាតពីប្រធាន **គ.ក.ហ** ដើម្បីចាត់តាំងអគ្គលេខាធិការរង អគ្គនាយករង ឬអគ្គាធិការរងមួយរូបឱ្យចូលរួមប្រជុំជំនួស។

សមាជិក **គ.ក.ហ** អាចស្នើសុំការអនុញ្ញាតពីប្រធាន **គ.ក.ហ** ឱ្យមន្ត្រីជំនាញដែលមានការពាក់ព័ន្ធផ្ទាល់ទៅនឹងការងារកែទម្រង់ នៅក្នុងអង្គភាពរបស់ខ្លួន ចូលរួមប្រជុំក្នុងឋានៈជាមន្ត្រីជំនួយការ។

**ប្រការ៦.–**

**គ.ក.ហ** មានអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជាសេនាធិការបច្ចេកទេសរបស់ខ្លួន ក្នុងការបំពេញការងារ។

**ប្រការ៧.–**

**គ.ក.ហ** ប្រើប្រាស់ត្រារបស់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅក្នុងការបំពេញការងាររបស់ខ្លួន។

**ប្រការ៨.–**

ត្រូវបាននិរាករ ដូចតទៅ÷

- ប្រកាសលេខ ៤៥១ សហវ.ប្រក ចុះថ្ងៃទី១១ ខែមេសា ឆ្នាំ២០១៣ ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងគម្រោងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងវិស័យហិរញ្ញវត្ថុសាធារណៈ
- ប្រកាសលេខ ០៣៦ សហវ.ប្រក ចុះថ្ងៃទី១១ ខែកុម្ភៈ ឆ្នាំ២០១១ ស្តីពីការបង្កើតអនុគណៈកម្មាធិការកសាងសមត្ថភាពមន្ត្រីរាជការនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សេចក្តីសម្រេចលេខ ០៣៥ សហវ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមសម្របសម្រួល នៃក្រសួង ស្ថាប័ន
- សេចក្តីសម្រេចលេខ ០៣៤ សហវ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមសម្របសម្រួល នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- សេចក្តីសម្រេចលេខ ០៣៣ សហវ ចុះថ្ងៃទី២២ ខែកញ្ញា ឆ្នាំ២០១០ ស្តីពីការបង្កើតក្រុមការងារគ្រប់គ្រងជំនួយបច្ចេកទេស
- ប្រកាសលេខ ១២០ សហវ.ប្រក ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ២០០៨ ស្តីពីការកែសម្រួលប្រកាសលេខ ២១៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ប្រកាសលេខ ២១៨ សហវ.ប្រក ចុះថ្ងៃទី២៨ ខែកក្កដា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- ប្រកាសលេខ ១៥០ សហវ.ប្រក ចុះថ្ងៃទី២០ ខែមីនា ឆ្នាំ២០០៦ ស្តីពីការបង្កើតអនុគណៈកម្មាធិការសម្រាប់ជំរុញការអនុវត្តការងារក្នុងក្របខណ្ឌគម្រោងការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមប្រព័ន្ធព័ត៌មានវិទ្យា
- ប្រកាសលេខ ២២៣ សហវ.ប្រក ចុះថ្ងៃទី១៣ ខែមេសា ឆ្នាំ២០០៥ ស្តីពីការបង្កើតក្រុមការងាររៀបចំមាតិកាគណនេយ្យនិងថវិកាថ្មី
- ប្រកាសលេខ ២៩០ សហវ.ប្រក ចុះថ្ងៃទី០៩ ខែកញ្ញា ឆ្នាំ២០០៤ ស្តីពីការបង្កើតអនុគណៈកម្មាធិការជ្រើសរើសនិងផ្តល់ការលើកទឹកចិត្ត នៃកម្មវិធីកំណែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនិងកម្មវិធីកន្សោមអាទិភាពនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- ប្រកាសលេខ៥៨៨ សហវ.ប្រក ចុះថ្ងៃទី១៧ ខែមិថុនា ឆ្នាំ២០១៣ ស្តីពីការផ្ទេរមុខងារបន្ថែមឱ្យទៅអង្គភាពគ្រប់គ្រងសាច់ប្រាក់ នៃអគ្គនាយកដ្ឋានរតនាគារជាតិ
- ប្រកាសលេខ ៥៩២សហវ.ប្រក ចុះថ្ងៃទី២៤ ខែកក្កដា ឆ្នាំ២០០៦ ស្តីពីការកែសំរួលសមាសភាពគណៈកម្មការតាមដានការអនុវត្តន៍ថវិកានិងគ្រប់គ្រងសាច់ប្រាក់
- ប្រកាសលេខ ២២៥សហវ.ប្រក ចុះថ្ងៃទី០៣ ខែសីហា ឆ្នាំ២០០៤ ស្តីពីការបង្កើតគណៈកម្មការតាមដានការអនុវត្តន៍ថវិកានិងគ្រប់គ្រងសាច់ប្រាក់

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ៩.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការ អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី១៩ ខែ[illegible] ឆ្នាំ២០១៤

បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ៩
- រាជកិច្ច
- ឯកសារ- កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៦.

## ប្រកាសលេខ ៣៤៧ សហវ.ប្រក ចុះថ្ងៃទី០១ ខែមេសា ឆ្នាំ២០១៥

## ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន

## គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ......សហវ.

# ប្រកាស
## ស្តីពី
## ការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋាន គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការបង្កើតក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០៥០៨/០១៦ ចុះថ្ងៃទី១៣ ខែឧសភា ឆ្នាំ២០០៨ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៤៤៤ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការបង្កើតគណៈកម្មាធិការគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ៤៨៨ អនក្រ.បក ចុះថ្ងៃទី១៦ ខែតុលា ឆ្នាំ២០១៣ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ២៤ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom , khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

## សម្រេច

## ជំពូកទី១

## បទប្បញ្ញត្តិទូទៅ

**ប្រការ១.-**

ប្រកាសនេះ មានគោលដៅកំណត់អំពីការរៀបចំនិងការប្រព្រឹត្តទៅនៃអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលសរសេរជាអក្សរកាត់ថា "**អ.គ.ហ.**"។

**ប្រការ២.-**

ប្រកាសនេះ មានគោលបំណង ដូចខាងក្រោម÷

- រៀបចំបេសកកម្មនិងរចនាសម្ព័ន្ធរបស់ **អ.គ.ហ.**
- រៀបចំមុខងារនិងភារកិច្ចរបស់អង្គភាពក្រោមឱវាទ **អ.គ.ហ.**
- ធានាគុណភាពនិងប្រសិទ្ធភាពនៃលទ្ធផលបំពេញការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**ប្រការ៣.-**

ប្រកាសនេះ មានវិសាលភាពអនុវត្ត ចំពោះគ្រប់អង្គភាពក្រោមឱវាទ **អ.គ.ហ.**។

## ជំពូកទី២

## បេសកកម្មនិងរចនាសម្ព័ន្ធ

**ប្រការ៤.-**

ក្នុងការបំពេញមុខងាររបស់ខ្លួន ជាសេនាធិការរបស់គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដែលសរសេរជាអក្សរកាត់ថា "**គ.ហ.ស.**", **អ.គ.ហ.** មានភារកិច្ចសម្របសម្រួលការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ដូចតទៅ÷

- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ **គ.ហ.ស.** ស្របតាមការណែនាំ និងការសម្រេចរបស់ **គ.ហ.ស.** ដោយរួមទាំងការរៀបចំដាក់ឱ្យអនុវត្ត និងការតាមដានត្រួតពិនិត្យគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងការរៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ
- សម្របសម្រួលប្រចាំថ្ងៃ លើការងាររដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ លទ្ធកម្ម និងផ្នែកភស្តុភារក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សហការនិងសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាពនិងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**
- ផ្តល់ការគាំទ្រដល់ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនានាក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពនានារបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ដោយ

រាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស

- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សូចនាករកម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពនានា ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅតាមក្រសួង ស្ថាប័ន ដោយរាប់បញ្ចូលបច្ចុប្បន្នកម្មជាទៀងទាត់ លើការផ្តត់ផ្តង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធានាសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់ទាំងបី
- សម្របសម្រួល ប្រមូលផ្តុំ លើកសំណើ និងដាក់ឱ្យអនុវត្តវិធានការណ៍កែទម្រង់ តាមរយៈការបណ្តុះគំនិតផ្តួចផ្តើម និងការបង្កើននវានុវត្តន៍ ក្នុងការដោះស្រាយបញ្ហាប្រឈមនានាដែលកើតមានឡើងនៅក្នុងដំណើរការរៀបចំនិងអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ផ្សព្វផ្សាយនិងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និង
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

**ប្រការ៥.-**

**អ.គ.ហ.** មានរចនាសម្ព័ន្ធដូចខាងក្រោម÷

១. ផ្នែកគោលនយោបាយ

២. ផ្នែកចំណូល

៣. ផ្នែករៀបចំថវិកា

៤. ផ្នែកអនុវត្តថវិកា

៥. ផ្នែកនវានុវត្តន៍និងផ្សព្វផ្សាយ

៦. ផ្នែកគាំទ្រទូទៅនិងកសាងសមត្ថភាព

៧. ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ។

**ប្រការ៦.-**

ផ្នែកនីមួយៗដឹកនាំដោយប្រធានមួយរូប ដែលអមដោយអនុប្រធានមួយចំនួន ជាជំនួយការ។

អង្គការលេខរបស់ **អ.គ.ហ.** ត្រូវបានកំណត់នៅក្នុងឧបសម្ព័ន្ធនៃប្រកាសនេះ។

## ជំពូកទី៣
## ផ្នែកគោលនយោបាយ

**ប្រការ៧.-**

ផ្នែកគោលនយោបាយ មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំដាក់ឱ្យអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- រៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ របស់ **គ.ហ.ស.**
- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ជួបប្រជុំ សហការ និងសម្របសម្រួលជាមួយអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាពនិងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**
- ពិនិត្យ កំណត់ និងលើកសំណើដោះស្រាយលើបញ្ហាប្រឈម រួមទាំងបញ្ហាជំនាញបច្ចេកទេស ដើម្បីបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- ផ្តល់ការគាំទ្រដល់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ ដោយរាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យលើដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស
- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សូចនាកររកម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងបច្ចុប្បន្នកម្មជាទៀងទាត់ លើការផ្គត់ផ្គង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ផ្នែក ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធានាសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់ទាំងបី
- ផ្សព្វផ្សាយនិងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

**ប្រការ៨.-**

ផ្នែកគោលនយោបាយ ទទួលបន្ទុកសម្របសម្រួលជាមួយអគ្គនាយកដ្ឋាន និងក្រសួង ស្ថាប័ន ដូចខាងក្រោម៖

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមាន ៖ អគ្គនាយកដ្ឋានគោលនយោបាយសេដ្ឋកិច្ចនិងហិរញ្ញវត្ថុសាធារណៈ
- ស្ថាប័នសេវាសេដ្ឋកិច្ច ដែលរួមមាន ៖ រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល ក្រសួងឧស្សាហកម្មនិងសិប្បកម្ម ក្រសួងរ៉ែនិងថាមពល ក្រសួងពាណិជ្ជកម្ម ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ ក្រសួងអភិវឌ្ឍន៍ជនបទ ក្រសួងប្រៃសណីយ៍និងទូរគមនាគមន៍ ក្រសួងសាធារណការនិងដឹកជញ្ជូន ក្រសួងទេសចរណ៍ ក្រសួងធនធានទឹកនិងឧតុនិយម និងក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ។

## ជំពូកទី៤
## ផ្នែកចំណូល

**ប្រការ៩.-**

ផ្នែកចំណូល មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំដាក់ឱ្យអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ របស់ **គ.ហ.ស.**
- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ជួបប្រជុំ សហការ និងសម្របសម្រួលជាមួយអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាពនិងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**
- ពិនិត្យ កំណត់ និងលើកសំណើដោះស្រាយលើបញ្ហាប្រឈម រួមទាំងបញ្ហាជំនាញបច្ចេកទេស ដើម្បីបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- ផ្តល់ការគាំទ្រដល់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ ដោយរាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យលើដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស
- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សូចនាករកម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងបច្ចុប្បន្នកម្មជាទៀងទាត់ លើការផ្គត់ផ្គង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ផ្នែក ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធានាសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់ទាំងបី
- ផ្សព្វផ្សាយនិងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

**ប្រការ១០.-**

ផ្នែកចំណូល ទទួលបន្ទុកសម្របសម្រួលជាមួយអគ្គនាយកដ្ឋាន និងក្រសួង ស្ថាប័ន ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមាន ÷ អគ្គនាយកដ្ឋានគយនិងរដ្ឋាករកម្ពុជា អគ្គនាយកដ្ឋានពន្ធដារ អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធ និងអគ្គនាយកដ្ឋានឧស្សាហកម្មហិរញ្ញវត្ថុ
- ស្ថាប័នសេវាហិរញ្ញវត្ថុ ការបរទេស និងសេវាសាធារណៈទូទៅ ដែលរួមមាន÷ ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងមុខងារសាធារណៈ ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច ក្រសួងការបរទេសនិងសហប្រតិបត្តិការអន្តរជាតិ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងព័ត៌មាន និងក្រសួងផែនការ។

## ជំពូកទី៥
## ផ្នែករៀបចំថវិកា

**ប្រការ១១.-**

ផ្នែករៀបចំថវិកា មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំដាក់ឱ្យអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ របស់ **គ.ហ.ស.**
- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ជួបប្រជុំ សហការ និងសម្របសម្រួលជាមួយអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាពនិងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**
- ពិនិត្យ កំណត់ និងលើកសំណើដោះស្រាយលើបញ្ហាប្រឈម រួមទាំងបញ្ហាជំនាញបច្ចេកទេស ដើម្បីបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- ផ្តល់ការគាំទ្រដល់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ ដោយរាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យលើដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស
- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សូចនាករកម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងបច្ចុប្បន្នកម្មជាទៀងទាត់ លើការផ្គត់ផ្គង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ផ្នែក ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធានាសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់ទាំងបី
- ផ្សព្វផ្សាយនិងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

**ប្រការ១២.-**

ផ្នែករៀបចំថវិកា ទទួលបន្ទុកសម្របសម្រួលជាមួយអគ្គនាយកដ្ឋាន និងក្រសួង ស្ថាប័ន ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមាន ÷ អគ្គនាយកដ្ឋានថវិកា និងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ

  ស្ថាប័នសេវាការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ ដែលរួមមាន÷ ក្រសួងការពារជាតិ ក្រសួងមហាផ្ទៃ "សន្តិសុខសាធារណៈ" និង "រដ្ឋបាលទូទៅ" ក្រសួងបរិស្ថាន ក្រសួងយុត្តិធម៌ សាលាឧទ្ធរណ៍ និងក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់។

## ជំពូកទី៦

## ផ្នែកអនុវត្តថវិកា

**ប្រការ១៣.-**

ផ្នែកអនុវត្តថវិកា មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំដាក់ឱ្យអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ របស់ **គ.ហ.ស.**
- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ជួបប្រជុំ សហការ និងសម្របសម្រួលជាមួយអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាពនិងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**
- ពិនិត្យ កំណត់ និងលើកសំណើដោះស្រាយលើបញ្ហាប្រឈម រួមទាំងបញ្ហាជំនាញបច្ចេកទេស ដើម្បីបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- ផ្តល់ការគាំទ្រដល់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ ដោយរាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត

ការតាមដាន និងការត្រួតពិនិត្យលើដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស

- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សូចនាករកម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងបច្ចុប្បន្នកម្មជាទៀងទាត់ លើការផ្គត់ផ្គង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ផ្នែក ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធានាសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់ទាំងបី
- ផ្សព្វផ្សាយនិងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

**ប្រការ១៤.-**

ផ្នែកអនុវត្តថវិកា ទទួលបន្ទុកសម្របសម្រួលជាមួយអគ្គនាយកដ្ឋាន និងក្រសួង ស្ថាប័ន ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមាន÷ អគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ
- ស្ថាប័នសេវាសង្គមកិច្ច ដែលរួមមាន÷ ក្រសួងសុខាភិបាល ក្រសួងអប់រំ យុវជន និងកីឡា ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា ក្រសួងធម្មការនិងសាសនា និងក្រសួងកិច្ចការនារី។

## ជំពូកទី៧

## ផ្នែកនវានុវត្តន៍និងផ្សព្វផ្សាយ

**ប្រការ១៥.-**

សម្រាប់ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជារួម ផ្នែកនវានុវត្តន៍និងផ្សព្វផ្សាយ មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំដាក់ឱ្យអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ និងសិក្ខាសាលាផ្សេងៗ របស់ **គ.ហ.ស.**
- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ជួបប្រជុំ សហការ និងសម្របសម្រួលជាមួយអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាពនិងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**

- ពិនិត្យ កំណត់ និងលើកសំណើដោះស្រាយលើបញ្ហាប្រឈម រួមទាំងបញ្ហាជំនាញបច្ចេកទេស ដើម្បីបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល
- ផ្តល់ការគាំទ្រដល់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ ដោយរាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យលើដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស
- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សូចនាករកម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធ ក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងនៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងបច្ចុប្បន្នកម្មជាទៀងទាត់ លើការផ្គត់ផ្គង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ផ្នែក ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធានាសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់ទាំងបី
- ផ្សព្វផ្សាយនិងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គនាយកដ្ឋាននិងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

**ប្រការ១៦.-**

សម្រាប់ការងារនវានុវត្តន៍ ផ្នែកនវានុវត្តន៍និងផ្សព្វផ្សាយ មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំយន្តការនិងក្របខ័ណ្ឌនៃការបណ្តុះគំនិតផ្តួចផ្តើមនិងបង្កើននវានុវត្តន៍ ក្នុងការដោះស្រាយបញ្ហាប្រឈមនៃការសម្របសម្រួលការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់ផ្នែកផ្សេងទៀតនៃ **អ.គ.ហ.**
- ប្រមូលផ្តុំនិងសម្របសម្រួលការផ្តួចផ្តើមគំនិតនិងនវានុវត្តន៍ ដែលត្រូវបានស្នើឡើងដោយផ្នែកជំនាញ នៃ **អ.គ.ហ.** ដើម្បីដាក់ជូនថ្នាក់ដឹកនាំ **អ.គ.ហ.** ពិនិត្យនិងអនុម័តសំណើគំនិតផ្តួចផ្តើមនិងនវានុវត្តន៍
- សម្របសម្រួលជាមួយអង្គភាពរបស់ កសហវ និង ក្រសួង ស្ថាប័នពាក់ព័ន្ធ ក្នុងការពិនិត្យ កែលម្អ និងសម្រេចលើសំណើគំនិតផ្តួចផ្តើមនិងនវានុវត្តន៍
- រៀបចំសំណើគំនិតផ្តួចផ្តើមនិងនវានុវត្តន៍ ជូន **អ.គ.ហ.** ដើម្បីដាក់ជូន **គ.ហ.ស.** ពិនិត្យនិងសម្រេច លើវិធានការណ៍គំនិតផ្តួចផ្តើមនិងនវានុវត្តន៍
- សម្របសម្រួលការរៀបចំនិងការអនុវត្តវិធានការណ៍គំនិតផ្តួចផ្តើមនិងនវានុវត្តន៍ នៅក្នុងកិច្ចដំណើរការនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

- រៀបចំនិងប្រមូលសរុបរបាយការណ៍វឌ្ឍនភាពនៃការអនុវត្តគំនិតផ្តួចផ្តើមនិងនវានុវត្តន៍ ដែលត្រូវបានដាក់ចេញនៅក្នុងកិច្ចដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

**ប្រការ១៧.-**

សម្រាប់ការងារផ្សព្វផ្សាយ ផ្នែកនវានុវត្តន៍និងផ្សព្វផ្សាយ មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំសិក្ខាសាលា សន្និសីទ សន្និសីទកាសែត វេទិកាសាធារណៈ បទឧទ្ទេសនាម តាមក្រសួង ស្ថាប័ន គ្រឹះស្ថានសិក្សា និងគ្រឹះស្ថានសាធារណៈ ស្តីពីកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំនិងគ្រប់គ្រងការបោះពុម្ពនិងការផ្សព្វផ្សាយព្រឹត្តិប័ត្រ ខិតប័ណ្ណ និងឯកសារផ្សេងទៀតពាក់ព័ន្ធកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំនិងសម្របសម្រួលផលិតកម្មខ្សែភាពយន្តខ្នាតខ្លីពាក់ព័ន្ធកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំកម្មវិធីផ្សព្វផ្សាយផ្សេងទៀត ដើម្បីបង្កើនការយល់ដឹង ការទទួលស្គាល់អំពីភាពចាំបាច់ និងការចេះដឹងអំពីទស្សនវិស័យ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនសាធារណជន គ្រប់ស្រទាប់ជាន់ថ្នាក់ និងមន្ត្រីរាជការគ្រប់លំដាប់ថ្នាក់ តាមការសម្រេចរបស់ **អ.គ.ហ.**។

**ប្រការ១៨.-**

សម្រាប់ការងារនវានុវត្តន៍និងផ្សព្វផ្សាយ ផ្នែកនវានុវត្តន៍និងផ្សព្វផ្សាយទទួលបន្ទុកសម្របសម្រួលជាមួយគ្រប់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និង គ្រប់ក្រសួង ស្ថាប័ន។

## ជំពូកទី៨
## ផ្នែកគាំទ្រទូទៅនិងកសាងសមត្ថភាព

**ប្រការ១៩.-**

ផ្នែកគាំទ្រទូទៅនិងកសាងសមត្ថភាព មានមុខងារនិងភារកិច្ចដូចតទៅ÷

- រៀបចំដាក់ឱ្យអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តគោលនយោបាយ យុទ្ធសាស្ត្រ និងផែនការសកម្មភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំឯកសារ របាយការណ៍ កិច្ចប្រជុំ សិក្ខាសាលា និងវគ្គបណ្តុះបណ្តាលផ្សេងៗ របស់ **គ.ហ.ស.**
- ផ្តល់យោបល់និងលើកសំណើដោះស្រាយជូន **គ.ហ.ស.** លើបញ្ហាប្រឈមនិងបញ្ហាជំនាញបច្ចេកទេស ដើម្បីជំរុញល្បឿននិងបង្កើនប្រសិទ្ធភាពនៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ជួបប្រជុំ សហការ និងសម្របសម្រួលជាមួយ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ដៃគូអភិវឌ្ឍន៍ ទីប្រឹក្សាបច្ចេកទេស គ្រប់អង្គភាព និងអ្នកពាក់ព័ន្ធនានា ដើម្បីជាជំនួយដល់ការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ តាមការចង្អុលបង្ហាញរបស់ **គ.ហ.ស.**
- ពិនិត្យ កំណត់ និងលើកសំណើដោះស្រាយលើបញ្ហាប្រឈម រួមទាំងបញ្ហាជំនាញបច្ចេកទេស ដើម្បីបង្កើនប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល

- ផ្តល់ការគាំទ្រ ដល់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធរបស់រាជរដ្ឋាភិបាល តាមសេចក្តីត្រូវការចាំបាច់ ដោយរាប់បញ្ចូលទាំងការរៀបចំ ការអនុវត្ត ការតាមដាន និងការត្រួតពិនិត្យលើដំណើរការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងការផ្តល់ជំនួយបច្ចេកទេស
- ត្រួតពិនិត្យ វាយតម្លៃ និងបូកសរុបរបាយការណ៍វឌ្ឍនភាពនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ សូចនាករកម្រិតម៉ាក្រូ និងការសម្របសម្រួលលើការត្រួតពិនិត្យវឌ្ឍនភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល ដោយរាប់បញ្ចូលទាំងបច្ចុប្បន្នកម្មជាទៀងទាត់លើការផ្គត់ផ្គង់ជំនួយបច្ចេកទេស ចំពោះសកម្មភាពអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំនិងបូកសរុបរបាយការណ៍វឌ្ឍនភាព នៃការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់ផ្នែក ប្រចាំខែ ប្រចាំត្រីមាស ប្រចាំឆមាស និងប្រចាំឆ្នាំ
- សម្របសម្រួលការងារជាមួយអង្គភាពពាក់ព័ន្ធនៃកម្មវិធីកែទម្រង់របស់រាជរដ្ឋាភិបាល ជាពិសេស កម្មវិធីកែទម្រង់រដ្ឋបាលសាធារណៈ និងកម្មវិធីសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ដើម្បីធានាសង្គតិភាពនិងភាពប្រទាក់ក្រឡាគ្នា រវាងកម្មវិធីកែទម្រង់ទាំងបី
- ផ្សព្វផ្សាយនិងណែនាំអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជូនអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ នៅតាមក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល
- ពិនិត្យ បូកសរុប និងផ្តល់យោបល់លើផែនការបណ្តុះបណ្តាលដែលស្នើឡើងដោយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ព្រមទាំងតាមដានដំណើរការនៃការបណ្តុះបណ្តាល
- រៀបចំនិងសម្របសម្រួលលើការងារគាំទ្រទូទៅ កសាងសមត្ថភាព និងការលើកទឹកចិត្ត ជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ ក្នុងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- ចូលរួមពិនិត្យនិងផ្តល់យោបល់ដល់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធនានា លើការជ្រើសរើសបុគ្គលិក/មន្ត្រី និងជំនាញការបច្ចេកទេសសម្រាប់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

**ប្រការ២០.-**

ផ្នែកគាំទ្រទូទៅនិងកសាងសមត្ថភាព ទទួលបន្ទុកសម្របសម្រួលជាមួយអគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងក្រសួង ស្ថាប័ន ដូចខាងក្រោម÷

- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដែលរួមមាន ÷ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុង និងអគ្គាធិការដ្ឋាន
- ស្ថាប័នកំពូលនិងឯករាជ្យ ដែលរួមមាន÷ ក្រសួងព្រះបរមរាជវាំង អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា អគ្គលេខាធិការដ្ឋានរដ្ឋសភា តុលាការកំពូល អង្គភាពប្រតិបត្តិនៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត អាជ្ញាធរសវនកម្មជាតិ និងអង្គភាពប្រឆាំងអំពើពុករលួយ។

## ជំពូកទី៩

## ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ

**ប្រការ២១.-**

ផ្នែករដ្ឋបាលនិងហិរញ្ញវត្ថុ មានមុខងារនិងភារកិច្ចដូចតទៅ÷

- សម្របសម្រួលការងារប្រចាំថ្ងៃរបស់ **អ.គ.ហ.** ស្របតាមការណែនាំរបស់អគ្គលេខាធិការនៃ **អ.គ.ហ.**
- សម្របសម្រួលប្រចាំថ្ងៃ លើការងាររដ្ឋបាល គណនេយ្យ ហិរញ្ញវត្ថុ លទ្ធកម្ម និងផ្នែកភស្តុភារក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងពិនិត្យ ផ្តល់យោបល់បច្ចេកទេសលើការគ្រប់គ្រងគម្រោងហិរញ្ញប្បទានសហប្រតិបត្តិការពីដៃគូអភិវឌ្ឍន៍
- គ្រប់គ្រង ចរាចរ តម្កល់ និងថែរក្សាឯកសាររដ្ឋបាល
- សម្របសម្រួលការងាររដ្ឋបាល របស់ **អ.គ.ហ.** ជាមួយ អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួង ស្ថាប័ន ព្រមទាំងអង្គភាពពាក់ព័ន្ធនៃរាជរដ្ឋាភិបាល
- សម្របសម្រួលការងាររវាងអ្នកជំនាញ ឬ ទីប្រឹក្សាបច្ចេកទេស និងដៃគូអភិវឌ្ឍន៍ពាក់ព័ន្ធជាមួយអគ្គលេខាធិការ-ដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន ព្រមទាំងអង្គភាពពាក់ព័ន្ធនានា
- រៀបចំនិងប្រមូលសរុបផែនការថវិកា និងផែនការលទ្ធកម្ម ដែលបានបញ្ជូនមកដោយភ្នាក់ងារពាក់ព័ន្ធ រួចលើកគម្រោងសរុបផែនការទាំងនេះដាក់ជូនថ្នាក់ដឹកនាំ និងដៃគូអភិវឌ្ឍន៍ ដើម្បីពិនិត្យនិងសម្រេច
- រៀបចំ អនុវត្ត និងគ្រប់គ្រងការងារគណនេយ្យនិងហិរញ្ញវត្ថុ ការងារលទ្ធកម្ម និងការងាររដ្ឋបាលរបស់ **អ.គ.ហ.**
- ផ្តល់ជំនួយបច្ចេកទេស ដល់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន ព្រមទាំងអង្គភាពពាក់ព័ន្ធនានា សម្រាប់ការងារពាក់ព័ន្ធការរៀបចំ ផែនការថវិកា កិច្ចលទ្ធកម្មផ្សេងៗទៀត ក្រោមកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- រៀបចំបញ្ចូលរបាយការណ៍វឌ្ឍនភាពរបស់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង ស្ថាប័ន ព្រមទាំងអង្គភាពពាក់ព័ន្ធនានា និងការងារពាក់ព័ន្ធផ្សេងៗ សម្រាប់បញ្ចូលក្នុងគេហទំព័ររបស់កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- គ្រប់គ្រងបុគ្គលិករបស់ **អ.គ.ហ.**
- គ្រប់គ្រងនិងបែងចែកសម្ភារៈប្រើប្រាស់ ឧបករណ៍ និងមធ្យោបាយផ្សេងៗ និង
- បំពេញការងារផ្សេងទៀត តាមការកំណត់របស់ **គ.ហ.ស.**។

## ជំពូកទី១០

## អវសានប្បញ្ញត្តិ

**ប្រការ២២.-**

ក្នុងការបំពេញការងារ ភារកិច្ចទាំងឡាយណា ដែលមានការពាក់ព័ន្ធទៅនឹងសមត្ថកិច្ចរបស់អគ្គនាយកដ្ឋានជំនាញដទៃ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ អគ្គលេខាធិការនៃ **អ.គ.ហ.** ត្រូវសហការជាមួយអគ្គនាយកនៃអគ្គនាយកដ្ឋានពាក់ព័ន្ធទាំងនោះ ដើម្បីរួមគ្នាដោះស្រាយ ឬ ស្នើសុំការសម្រេចពីរដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ លើការកំណត់ ឬបែងចែកភារកិច្ចទាំងនោះ។

**ប្រការ២៣.-**

ប្រកាសនេះ មានអានុភាពអនុវត្តជំនួសប្រកាសលេខ ២២៣ សហវ.ប្រក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅ នៃអង្គភាពក្រោមឱវាទអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

លិខិតបទដ្ឋានគតិយុត្តទាំងឡាយ ដែលត្រូវបានសម្រេចដាក់ឱ្យអនុវត្ត ដោយផ្អែកលើមូលដ្ឋាននៃប្រកាសលេខ ២២៣ សហវ.ប្រក ចុះថ្ងៃទី០៥ ខែកុម្ភៈ ឆ្នាំ២០១៤ ខាងលើ ត្រូវមានអានុភាពអនុវត្ត រហូតដល់មានលិខិតបទដ្ឋានគតិយុត្តថ្មីមកជំនួស។

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ២៤.-**

នាយកខុទ្ទកាល័យ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋាន អគ្គនាយកនៃគ្រប់អគ្គនាយកដ្ឋាន អគ្គាធិការនៃអគ្គាធិការដ្ឋាន និងប្រធានអង្គភាពពាក់ព័ន្ធក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ត្រូវទទួលបន្ទុកអនុវត្តប្រកាសនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

រាជធានីភ្នំពេញ ថ្ងៃទី០១ ខែមករា ឆ្នាំ២០១៥

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/ លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ក្រសួងមុខងារសាធារណៈ
- សាលារាជធានី ខេត្ត
- ដូចប្រការ២៤
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ

ឧបសម្ព័ន្ធ នៃប្រកាសលេខ ៣៩៧ សហវ.ប្រក

ចុះថ្ងៃទី ០៧ ខែ មេសា ឆ្នាំ២០១៥

# អង្គការលេខ

## អគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ



## ស្ថាប័ន សេវាសេដ្ឋកិច្ច

១- រដ្ឋលេខាធិការដ្ឋានអាកាសចរស៊ីវិល
២- ក្រសួងឧស្សាហកម្មនិងសិប្បកម្ម
៣- ក្រសួងរ៉ែនិងថាមពល
៤- ក្រសួងពាណិជ្ជកម្ម
៥- ក្រសួងកសិកម្ម រុក្ខាប្រមាញ់ និងនេសាទ
៦- ក្រសួងអភិវឌ្ឍន៍ជនបទ
៧- ក្រសួងប្រៃសណីយ៍ និងទូរគមនាគមន៍
៨- ក្រសួងសាធារណការ និងដឹកជញ្ជូន
៩- ក្រសួងទេសចរណ៍
១០- ក្រសួងធនធានទឹក និងឧតុនិយម
១១- ក្រសួងការងារនិងបណ្តុះបណ្តាលវិជ្ជាជីវៈ

## ស្ថាប័ន សេវាហិរញ្ញវត្ថុ ការបរទេស និង សេវាសាធារណៈទូទៅ

១- ទីស្តីការគណៈរដ្ឋមន្ត្រី
២- ក្រសួងមុខងារសាធារណៈ
៣- ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា
៤- ក្រសួងទំនាក់ទំនងជាមួយរដ្ឋសភា ព្រឹទ្ធសភា និងអធិការកិច្ច
៥- ក្រសួងការបរទេស និងសហប្រតិបត្តិការអន្តរជាតិ
៦- ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
៧- ក្រសួងព័ត៌មាន
៨- ក្រសួងផែនការ

## ស្ថាប័ន សេវាការពារជាតិ សន្តិសុខ និងសណ្តាប់ធ្នាប់សាធារណៈ

១- ក្រសួងការពារជាតិ
២- ក្រសួងមហាផ្ទៃ "សន្តិសុខសាធារណៈ"
៣- ក្រសួងមហាផ្ទៃ "រដ្ឋបាលទូទៅ"
៤- ក្រសួងបរិស្ថាន
៥- ក្រសួងយុត្តិធម៌
៦- សាលាឧទ្ធរណ៍
៧- ក្រសួងរៀបចំដែនដី នគរូបនីយកម្ម និងសំណង់

## ស្ថាប័ន សេវាសង្គមកិច្ច

១- ក្រសួងសុខាភិបាល
២- ក្រសួងអប់រំ យុវជន និងកីឡា
៣- ក្រសួងវប្បធម៌និងវិចិត្រសិល្បៈ
៤- ក្រសួងសង្គមកិច្ច អតីតយុទ្ធជន និងយុវនីតិសម្បទា
៥- ក្រសួងធម្មការនិងសាសនា
៦- ក្រសួងកិច្ចការនារី

## ស្ថាប័ន កំពូល និងឯករាជ្យ

១- ក្រសួងព្រះបរមរាជវាំង
២- អគ្គលេខាធិការដ្ឋានក្រុមប្រឹក្សាធម្មនុញ្ញ
៣- អគ្គលេខាធិការដ្ឋានព្រឹទ្ធសភា
៤- អគ្គលេខាធិការដ្ឋានរដ្ឋសភា
៥- អង្គភាពប្រតិបត្តិក្រុមប្រឹក្សានៃឧត្តមក្រុមប្រឹក្សានៃអង្គចៅក្រម
៦- តុលាការកំពូល
៧- គណៈកម្មាធិការជាតិរៀបចំការបោះឆ្នោត
៨- អាជ្ញាធរសវនកម្មជាតិ
៩- អង្គភាពប្រឆាំងអំពើពុករលួយ

# ឧបសម្ព័ន្ធ ៧.

## សេចក្តីសម្រេចរួមលេខ ០០៦ សហវ ចុះថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥

## ស្តីពីការបង្កើតយន្តការសម្របសម្រួលរវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍ តាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រង ហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០១........សហវ.....

# សេចក្តីសម្រេចរួម
# ស្តីពី
# ការបង្កើតយន្តការសម្របសម្រួលរវាង កម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ

**ប្រធានគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**
**ប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**
**ប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្តីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២១៣/១៣៩៣ ចុះថ្ងៃទី២១ ខែធ្នូ ឆ្នាំ២០១៣ ស្តីពីការកែសម្រួលនិងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ស្តីពីការរៀបចំនិងការប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/១២០៨/១៤២៩ ចុះថ្ងៃទី៣១ ខែធ្នូ ឆ្នាំ២០០៨ ស្តីពីការបង្កើតគណៈ-កម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ
- បានឃើញអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ
- បានឃើញអនុក្រឹត្យលេខ ៦៣ អនក្រ.បក ចុះថ្ងៃទី១៣ ខែកុម្ភៈ ឆ្នាំ២០១៤ ស្តីពីការបង្កើតគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ
- យោងតាមតម្រូវការចាំបាច់របស់គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ

## សម្រេច

**ប្រការ១.-**

បង្កើតយន្តការសម្របសម្រួល រវាងកម្មវិធីកែទម្រង់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងកម្មវិធីជាតិកំណែទម្រង់រដ្ឋបាលសាធារណៈ ដើម្បីធានាសង្គតិភាព ភាពប្រទាក់ក្រឡា និងសុខដុមនីយកម្ម នៃទំនាក់ទំនងការងារកែទម្រង់ទាំងបីនេះ របស់រាជរដ្ឋាភិបាល។

**ប្រការ២.-**

យន្តការសម្របសម្រួល ត្រូវបានកំណត់ ដូចតទៅ÷

- អគ្គលេខាធិការដ្ឋាន នៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ លេខាធិការដ្ឋាន នៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ មានរបបប្រជុំប្រចាំត្រីមាស និងតាមការចាំបាច់ ដែលដឹកនាំតាមលក្ខណៈប្ដូរវេន
- កិច្ចប្រជុំត្រូវដឹកនាំដោយអគ្គលេខាធិការ ឬប្រធានលេខាធិការដ្ឋាន ដែលជាប្រធានតាមវេន
- របៀបវារៈនៃកិច្ចប្រជុំ ត្រូវបានកំណត់ទៅតាមប្រធានបទដែលស្នើឡើងដោយអគ្គលេខាធិការដ្ឋាន ឬ លេខាធិការដ្ឋាន នៃគណៈកម្មាធិការទាំងបី
- ប្រធានប្ដូរវេនត្រូវប្រមូលព័ត៌មានពាក់ព័ន្ធនឹងរបៀបវារៈនៃកិច្ចប្រជុំ ដើម្បីដំណើរការកិច្ចប្រជុំប្រកបដោយផលិតភាពនិងប្រសិទ្ធភាព
- ប្រធានប្ដូរវេន មានសិទ្ធិអញ្ជើញតំណាងក្រសួង ស្ថាប័ន ដែលមានការពាក់ព័ន្ធ ចូលរួមប្រជុំ តាមការចាំបាច់។

**ប្រការ៣.-**

ប្រធានគណៈកម្មាធិការនីមួយៗ អាចកោះប្រជុំអគ្គលេខាធិការដ្ឋាន ឬលេខាធិការដ្ឋាន នៃគណៈកម្មាធិការទាំងបី តាមការចាំបាច់ក្រោមការដឹកនាំផ្ទាល់ ឬតំណាងប្រធានគណៈកម្មាធិការ។

**ប្រការ៤.-**

រាល់កិច្ចប្រជុំដូចមានចែងក្នុងប្រការ២ និងប្រការ៣ ត្រូវមានរបាយការណ៍ជម្រាបជូនប្រធានគណៈកម្មាធិការទាំងបី។

**ប្រការ៥.-**

អគ្គលេខាធិការ នៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ ប្រធានលេខាធិការដ្ឋាននៃគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ និងប្រធានអង្គភាពចំណុះអគ្គលេខាធិការដ្ឋាន និងលេខាធិការដ្ឋាន នៃគណៈកម្មាធិការទាំងបី ត្រូវទទួលបន្ទុកអនុវត្តសេចក្ដីសម្រេចរួមនេះ តាមភារកិច្ចរៀងៗខ្លួន ចាប់ពីថ្ងៃចុះហត្ថលេខាតទៅ។

ធ្វើនៅរាជធានីភ្នំពេញ ថ្ងៃទី១៩ ខែឧសភា ឆ្នាំ២០១៥

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី**
**ក្រសួងមហាផ្ទៃនិងជាប្រធាន**
**គណៈកម្មាធិការជាតិសម្រាប់ការអភិវឌ្ឍតាមបែបប្រជាធិបតេយ្យនៅថ្នាក់ក្រោមជាតិ**

**ស ខេង**

**រដ្ឋមន្ត្រី**
**ក្រសួងមុខងារសាធារណៈ**
**និងជាប្រធានគណៈកម្មាធិការកែទម្រង់រដ្ឋបាលសាធារណៈ**

**ពេជ្រ ប៊ុនធិន**

**រដ្ឋមន្ត្រី**
**ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុនិងជាប្រធាន**
**គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្ដីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្ដេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- ដូចប្រការ៥
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៨.

# សារាចរលេខ ០០៦ សហវ ចុះថ្ងៃទី២៩ ខែមេសា ឆ្នាំ២០១៥

# ស្តីពីយន្តការដោះស្រាយបញ្ហាប្រឈម ក្នុងការអនុវត្ត

# សកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

ព្រះរាជាណាចក្រកម្ពុជា
ជាតិ សាសនា ព្រះមហាក្សត្រ

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ
លេខ..០០៦......សហវ.....

# សារាចរ
# ស្តីពី
# យន្តការដោះស្រាយបញ្ហាប្រឈម
# ក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បាននិងកំពុងឈានមកដល់ដំណាក់កាលនៃការផ្លាស់ប្តូរដ៏សំខាន់ ទាំងរចនាសម្ព័ន្ធដឹកនាំនិងគ្រប់គ្រង ទាំងយន្តការនិងនីតិវិធីនៃកិច្ចដំណើរការ ជាពិសេសតាមរយៈការដាក់ឱ្យអនុវត្តថវិកាកម្មវិធីពេញលេញ ចាប់ពីឆ្នាំ២០១៥ តទៅ។ ការផ្លាស់ប្តូរនានានៅក្នុងដំណាក់កាលនេះ បានបង្កើតឱ្យមានបញ្ហាប្រឈមមួយចំនួន ដែលទាមទារឱ្យមានការពិនិត្យ តាមដាន និងយកចិត្តទុកដាក់ខ្ពស់ ក្នុងការកំណត់បញ្ហាប្រឈមឱ្យបានជាក់លាក់ និងចាត់វិធានការណ៍ដោះស្រាយជាបន្ទាន់ សំដៅធានាជំរុញការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ឱ្យមានវឌ្ឍនាការ ប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព។

នៅក្នុងបរិការណ៍នេះ គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) សម្រេចដាក់ចេញនូវយន្តការដោះស្រាយបញ្ហាប្រឈមក្នុងការអនុវត្តសកម្មភាពការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដូចតទៅ ÷

## ក. យន្តការសម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ

បញ្ហាប្រឈមនានា រួមទាំងភាពមិនច្បាស់លាស់ ឬអសង្គតិភាពនៃការបកស្រាយ និងការអនុវត្តលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេស ការអនុវត្តថវិកាកម្មវិធី នៅក្នុងក្របខណ្ឌនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក៏ដូចជានៅក្រសួង ស្ថាប័ន ទាំងឡាយដែលអនុវត្តថវិកាកម្មវិធីពេញលេញ ត្រូវកំណត់ឱ្យបានជាក់លាក់ និងពិនិត្យដោះស្រាយ ជាជំហានបឋម ដោយអគ្គនាយកដ្ឋានឬអង្គភាពជំនាញពាក់ព័ន្ធនៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមានការពិគ្រោះយោបល់ឬមានការណែនាំបញ្ជាក់បន្ថែម តាមការចាំបាច់ ដោយរដ្ឋលេខាធិការ ឬអនុរដ្ឋលេខាធិការ ដែលទទួលបន្ទុកអគ្គនាយកដ្ឋាន ឬអង្គភាពជំនាញពាក់ព័ន្ធនោះ។

ក្នុងករណីដែលបញ្ហាទាំងនោះ នៅតែពុំអាចដោះស្រាយបាន ក្នុងជំហានបឋម អគ្គនាយកដ្ឋាន ឬអង្គភាពជំនាញពាក់ព័ន្ធ ត្រូវរៀបចំលិខិតស្នើសុំការពិនិត្យនិងដោះស្រាយ មកអគ្គលេខាធិការដ្ឋាន នៃ **គ.ហ.ស.** (**អ.គ.ហ.**) ដោយកំណត់និងគូសបញ្ជាក់អំពីកម្មវត្ថុនៃចំណោទបញ្ហា និងមូលហេតុ/ប្រភពនៃបញ្ហាប្រឈម ឱ្យបានច្បាស់លាស់ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

ក្នុងករណីដែលបញ្ហាប្រឈម ដែលបានលើកឡើង មានលក្ខណៈមិនទាន់ជាក់លាក់ **អ.គ.ហ.** អាចចាត់បញ្ជូនមន្ត្រីជំនាញរបស់ខ្លួន ទៅពិនិត្យ និងសិក្សាបន្ថែម តាមការចាំបាច់ នៅសាមីអគ្គនាយកដ្ឋានឬអង្គភាពជំនាញ ឬអញ្ជើញថ្នាក់ដឹកនាំ ឬមន្ត្រីជំនាញ នៃអគ្គនាយកដ្ឋានឬអង្គភាពជំនាញពាក់ព័ន្ធ ចូលរួមប្រជុំ ដើម្បីពិនិត្យនិងដោះស្រាយ។

**អ.គ.ហ.** ត្រូវពិនិត្យនិងដោះស្រាយ តាមរយៈលិខិតឆ្លើយតប ទៅកាន់អគ្គនាយកដ្ឋាន ឬអង្គភាពជំនាញពាក់ព័ន្ធ ក្នុងរយៈពេលដ៏ឆាប់បំផុត ដោយចម្លងជូន ប្រធាន **គ.ហ.ស.** ជ្រាបជារបាយការណ៍។


ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខ័ណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

ប្រសិនបើបញ្ហាប្រឈមមានការពាក់ព័ន្ធនឹងប្រព័ន្ធ យន្តការ ឬក្របខណ្ឌគតិយុត្ត នៃការងារកែទម្រង់ ដែលពុំអាចដោះស្រាយបានក្នុងកម្រិតជំនាញ **អ.គ.ហ.** ត្រូវស្នើសុំការពិនិត្យនិងសម្រេចជាវិធានការណ៍ដំណោះស្រាយ ពីប្រធាន **គ.ហ.ស.** ដោយលើកឡើងនូវសំណើជម្រើសជាក់លាក់នៃវិធានការណ៍ដំណោះស្រាយនីមួយៗ ដោយបញ្ជាក់អំពីមូលហេតុ និងផលវិបាកពាក់ព័ន្ធ។

ការសម្រេចរបស់ប្រធាន **គ.ហ.ស.** នឹងត្រូវរៀបចំនិងដាក់ឱ្យអនុវត្ត ក្នុងក្របខណ្ឌនៃសមត្ថកិច្ចរបស់ប្រធាន **គ.ហ.ស.** និងជារដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដោយមាន **អ.គ.ហ.** ជាលេខាធិការ។

ការសម្រេចជាវិធានការណ៍ដំណោះស្រាយ ក្រោមទម្រង់ជាលិខិតបទដ្ឋានគតិយុត្តនានា ដោយ **គ.ហ.ស.** ត្រូវផ្សព្វផ្សាយ និងណែនាំអនុវត្ត ដោយទូលំទូលាយ និងប្រកបដោយប្រសិទ្ធភាព ដោយ **អ.គ.ហ.** ដែលត្រូវរាយការណ៍ជូនប្រធាន **គ.ហ.ស.** តាមកាលកំណត់ជាធរមាន។

**ខ. យន្តការសម្រាប់ក្រសួង ស្ថាប័ន**

ក្រសួង ស្ថាប័ន ទាំងឡាយណាដែលជួបប្រទះបញ្ហាប្រឈមនានាដែលកើតចេញពីការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ជាពិសេសការអនុវត្តចរិកាកម្មវិធីពេញលេញ ត្រូវរៀបចំលិខិតស្នើសុំការពិនិត្យនិងដោះស្រាយ មក **អ.គ.ហ.** តាមរយៈក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**ក.ហ.ស.**) របស់សាមីក្រសួង ស្ថាប័ន ដោយកំណត់និងគូសបញ្ជាក់អំពីកម្មវត្ថុនៃចំណោទបញ្ហា និងមូលហេតុ/ប្រភពនៃបញ្ហាប្រឈមឱ្យបានច្បាស់លាស់ ព្រមទាំងភ្ជាប់មកជាមួយនូវឯកសារនិងលិខិតបទដ្ឋានគតិយុត្តពាក់ព័ន្ធ។

**អ.គ.ហ.** ត្រូវពិនិត្យនិងបូកសរុបសំណើសុំដោះស្រាយបញ្ហាប្រឈមទាំងនោះ និងបញ្ចូលទៅក្នុងរបៀបវារៈនៃកិច្ចប្រជុំប្រចាំខែរបស់ **អ.គ.ហ.** ជាមួយ **ក.ហ.ស.** នៃក្រសួង ស្ថាប័ន ដើម្បីពិភាក្សានិងដោះស្រាយ ដោយមានការចូលរួមពីអគ្គនាយកដ្ឋានឬអង្គភាពជំនាញពាក់ព័ន្ធ នៃក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ។

បញ្ហាប្រឈមទាំងឡាយ ដែលត្រូវបានសម្របសម្រួលនិងដោះស្រាយដោយ **អ.គ.ហ.** ត្រូវរាយការណ៍ជូនប្រធាន **គ.ហ.ស.**។

បញ្ហាប្រឈមទាំងឡាយដែលត្រូវបានលើកឡើងដោយ **ក.ហ.ស.** នៃក្រសួង ស្ថាប័ន និងពុំអាចដោះស្រាយបានក្នុងកម្រិត **អ.គ.ហ.** ត្រូវលើកយកមកដោះស្រាយ នៅក្នុងយន្តការសម្រាប់ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ដូចមានចែងក្នុងចំណុច **ក.** ខាងលើ។

ទទួលបានសារាចរនេះ គ្រប់ក្រសួង ស្ថាប័ន គ្រប់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន និងអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ព្រមទាំងអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ និងក្រុមការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ នៃក្រសួង ស្ថាប័ន ត្រូវអនុវត្តប្រកបដោយស័ក្តិសិទ្ធភាព ប្រសិទ្ធភាព ភាពជាម្ចាស់ និងស្មារតីទទួលខុសត្រូវខ្ពស់។

*រាជធានីភ្នំពេញ ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៥*

**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ**
**និងជាប្រធានគណៈកម្មាធិការដឹកនាំការងារ**
**កែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**កន្លែងទទួល ÷**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យឯកឧត្តម/លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- គ្រប់ក្រសួង ស្ថាប័ន
- គ្រប់អគ្គលេខាធិការដ្ឋាន អគ្គនាយកដ្ឋាន អគ្គាធិការដ្ឋាន និងអង្គភាពក្រោមឱវាទ ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ
- រាជកិច្ច
- ឯកសារ កាលប្បវត្តិ

# ឧបសម្ព័ន្ធ ៩.

# ផែនការសកម្មភាពរួម ដំណាក់កាលទី៣

# ផែនការសកម្មភាពរួម ដំណាក់កាលទី៣ (២០១៦-២០២០)

| គោលបំណង/<br>ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/<br>អង្គភាព | សូចនាករ<br>សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/<br>TA |
| | | | | | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | | |
| **ផ្នែកទី១ ÷ បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា**<br>- ការអនុវត្តចំណូល និងចំណាយប្រចាំត្រីមាស មានភាពរលូននិងអាចប៉ាន់ស្មានបាន (កម្រិតលម្អៀងនៃការអនុវត្តមិនលើសពី +/- ៥% ធៀបទៅនឹងកម្មវិធីចំណូល- ចំណាយ)<br>- ការគ្រប់គ្រងបំណុលត្រូវសង និងបំណុលត្រូវទារក្នុងឆ្នាំប្រកបដោយប្រសិទ្ធភាព | | | | | | | | | | | | | | | | | | | | | | | | | | |
| **១១. បន្តពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល** | **២០១៦** | **២០១៨** | | **ការអនុវត្តចំណូលប្រចាំត្រីមាសមានភាពរលូននិងអាចប៉ាន់ស្មានបាន (កម្រិតលម្អៀង +/-ពី៥ % )** | | | | | | | | | | | | | | | | | | | | | | |
| **១១.១.** អនុវត្តគោលនយោបាយចំណូលរយៈពេលមធ្យម និងយុទ្ធសាស្ត្រកៀរគរចំណូល | ២០១៦ | ២០១៨ | -អគ្គ.គោលនយោបាយ,<br>-អគ្គ.គយ,<br>-អគ្គ.ពន្ធដារ,<br>-អគ្គ.ឧស្សា.ហិរញ្ញ,<br>-អគ្គ.ទ្រព្យ.រដ្ឋ<br>-គ្រប់ក្រសួង-ស្ថាប័ន | **១.** ប្រសិទ្ធភាពនៃការគ្រប់គ្រងការប្រមូលចំណូល (កើនប្រចាំឆ្នាំ =កំណើនពិតផសស + អតិផរណា +៥%)<br>**២.** ការអនុវត្តយុទ្ធសាស្ត្រកៀរគរ | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/ TA |
| | | | | | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | | |
| | | | | ចំណូលប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព<br>៣. ការប្រមូលចំណូលត្រូវបានបង្កើនយ៉ាងហោចណាស់ ០.៥ % នៃ ផសស ប្រចាំឆ្នាំ<br>៤.ប្រកាសអន្តរក្រសួងចំនួន១២ ស្តីពីសេវាកម្មសាធារណៈ និងរង្វាន់លើកទឹកចិត្តត្រូវបានរៀបចំនៅឆ្នាំ២០១៦ ដើម្បីបង្កើនចំណូលមិនមែនពន្ធ<br>៥.ផែនការសកម្មភាពអនុវត្តយុទ្ធសាស្ត្រកៀរគរចំណូលត្រូវបាន | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/ TA |
| | | | | | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | | |
| | | | | រៀបចំ ដាក់ឱ្យអនុវត្ត តាមដានត្រួតពិនិត្យ និងវាយតម្លៃ | | | | | | | | | | | | | | | | | | | | | | |
| ១១.២. បន្តកែលម្អគោលនយោបាយ និងរដ្ឋបាលគយ, ពន្ធដារ, ចំណូលមិនមែនសារពើ-ពន្ធ និងទ្រព្យសម្បត្តិរដ្ឋ | ២០១៦ | ២០១៨ | -អគ្គ.គយ,<br>-អគ្គ.ពន្ធដារ,<br>-អគ្គ.ឧស្សា.ហិរញ្ញ,<br>-អគ្គ.ទ្រព្យ.រដ្ឋ<br>-គ្រប់ក្រសួង-ស្ថាប័ន | **១.**សេវាសម្រាប់អ្នកបង់ពន្ធ/បង់ចំណូល មានលក្ខណៈល្អប្រសើរជាងមុន<br>**២.**គណៈកម្មាធិការដោះស្រាយវិវាទសារពើពន្ធត្រូវបានបង្កើត<br>**៣.** គោលនយោបាយពន្ធគយពន្ធដារ និងចំណូលមិនមែនពន្ធនិងទ្រព្យសម្បត្តិរដ្ឋ ត្រូវបានរៀបចំនិងដាក់ឱ្យអនុវត្តប្រកបដោយ | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ ចង្កោមសកម្មភាព | ពេលវេលា ត្រូវការ | | ក្រសួង-ស្ថាប័ន/ អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភព ហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/ TA |
| | | | | | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | | |
| | | | | ស័ក្តិសិទ្ធភាព និង ប្រសិទ្ធភាព ៤. សវនករគយ ទាំង៩ក្រុម ត្រូវ បានដាក់ឱ្យ ដំណើរការក្រុម និងអង្គភាពស៊ើប អង្កេតបទល្មើស ពន្ធត្រូវបានបង្កើត | | | | | | | | | | | | | | | | | | | | | | |
| ១១.៣. ពង្រឹងការ ព្យាករណ៍ចំណូល | ២០១៦ | ២០១៨ | -អគ្គ.គោលនយោបាយ, -អគ្គ.គយ, -អគ្គ.ពន្ធដារ, -អគ្គ.ឧស្សា.ហិរញ្ញ, -អគ្គ.ទ្រព្យ.រដ្ឋ -គ្រប់ក្រសួង-ស្ថាប័ន | ផែនការព្យាករណ៍ ចំណូលត្រូវបាន រៀបចំជាត្រីមាស និងប្រចាំឆ្នាំ និង មានភាពសុក្រឹត្យ ក្នុងរង្វង់ +/-៥% | | | | | | | | | | | | | | | | | | | | | | |
| **១២. បន្តពង្រឹង ការគ្រប់គ្រងបំណុល** | **២០១៦** | **២០១៨** | | **ការគ្រប់គ្រង បំណុលត្រូវសង និងបំណុលត្រូវទារ ក្នុងឆ្នាំប្រកបដោយ ប្រសិទ្ធភាព** | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ ចង្កោមសកម្មភាព | ពេលវេលា ត្រូវការ | | ក្រសួង-ស្ថាប័ន/ អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភព ហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/ TA |
| | | | | | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | | |
| ១២.១. អនុវត្តយុទ្ធសាស្ត្រគ្រប់គ្រងបំណុល ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព | ២០១៦ | ២០១៨ | អគ្គ. ថវិកា | យុទ្ធសាស្ត្រគ្រប់គ្រងបំណុលត្រូវបានអនុវត្តប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព | | | | | | | | | | | | | | | | | | | | | | |
| ១២.២. រៀបចំក្របខ័ណ្ឌគតិយុត្តនិងយន្តការសម្រាប់អនុវត្តការធានារបស់រដ្ឋ | ២០១៦ | ២០១៨ | អគ្គ. ថវិកា | ក្របខ័ណ្ឌគតិយុត្តនិងក្របខ័ណ្ឌស្ថាប័ន ព្រមទាំងតួនាទី និងការទទួលខុសត្រូវក្នុងការគ្រប់គ្រងការធានារបស់រដ្ឋត្រូវបានរៀបចំនិងអនុវត្តប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព | | | | | | | | | | | | | | | | | | | | | | |
| ១២.៣. ពង្រឹងប្រសិទ្ធភាពនៃការគ្រប់គ្រងបំណុលត្រូវទារក្នុងឆ្នាំ | ២០១៦ | ២០១៨ | -អគ្គ.គយ,<br>-អគ្គ.ពន្ធដារ,<br>-អគ្គ.ទ្រព្យ.រដ្ឋ | ការគ្រប់គ្រងបំណុលត្រូវទារក្នុងឆ្នាំត្រូវបាន | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/ អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/ TA |
| | | | | | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | | |
| | | | -គ្រប់ក្រសួង-ស្ថាប័ន | អនុវត្តប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព | | | | | | | | | | | | | | | | | | | | | | |
| **១៣. ពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និង គណនី** | **២០១៦** | **២០១៨** | | **ផែនការសាច់ប្រាក់ត្រូវបានអនុវត្តប្រកបដោយសិក្តិសិទ្ធភាពនិងប្រសិទ្ធភាព** | | | | | | | | | | | | | | | | | | | | | | |
| ១៣.១. បន្តកែលម្អ និង ពង្រឹងការរៀបចំផែនការសាច់ប្រាក់ (ចាប់ផ្តើមពីប្រចាំត្រីមាស/ប្រចាំខែ និង ឈានទៅរកការរៀបចំផែនការសាច់ប្រាក់ប្រចាំសប្តាហ៍ និង ប្រចាំថ្ងៃ) | ២០១៦ | ២០១៨ | អគ្គ. រតនាគារជាតិ | ផែនការសាច់ប្រាក់ត្រូវបានអនុវត្តប្រកបដោយស័ក្តិសិទ្ធភាព (ចាប់ផ្តើមពីប្រចាំត្រីមាស/ ប្រចាំខែ និងឈានទៅរកការរៀបចំផែនការសាច់ប្រាក់ប្រចាំសប្តាហ៍និងប្រចាំថ្ងៃ) | | | | | | | | | | | | | | | | | | | | | | |
| ១៣.២. បន្តពង្រឹងការប្រើប្រាស់ | ២០១៦ | ២០១៨ | អគ្គ. រតនាគារជាតិ | **១.** ប្រតិបត្តិការចំណូល ចំណាយ | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/ អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/ TA |
| | | | | | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | | |
| ប្រព័ន្ធធនាគារ ព្រមទាំងសិក្សានិងពិនិត្យលទ្ធភាពឈានទៅអនុវត្តការទូទាត់តាម E-Transfer | | | | សាធារណៈ ត្រូវបានទូទាត់តាមរយៈប្រព័ន្ធធនាគារពេញលេញ **២.** ការសិក្សានិងពិនិត្យលទ្ធភាពលើការទូទាត់តាម E-Transfer ត្រូវបានបញ្ចប់ និងមានរបាយការណ៍សិក្សា | | | | | | | | | | | | | | | | | | | | | | |
| ១៣.៣. រៀបចំយន្តការប្រមូលផ្តុំនិងបូកសរុបរបាយការណ៍អនុវត្តថវិកាគម្រោងរបស់ដៃគូអភិវឌ្ឍន៍ ដែលនៅក្រៅប្រព័ន្ធរតនាគារ ជាជំហានៗ និងបន្តពង្រឹងគណនីទោលរតនាគារ | ២០១៦ | ២០១៨ | -អគ្គ.ថវិកា<br>-អគ្គ.រតនាគារជាតិ | **១.** យន្តការប្រមូលផ្តុំនិងបូកសរុបរបាយការណ៍អនុវត្តថវិកាគម្រោងរបស់ដៃគូអភិវឌ្ឍន៍ដែលនៅក្រៅប្រព័ន្ធរតនាគារជាជំហានៗត្រូវបានរៀបចំ **២.** គណនីទោល | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/ TA |
| | | | | | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | | |
| | | | | រតនាគារត្រូវបានបន្តពង្រឹងនិងប្រើប្រាស់ពេញលេញ | | | | | | | | | | | | | | | | | | | | | | |
| ១៣.៤. បន្តតាមដានបំណុលកកស្ទះ និងអាយុកាលរបស់វា | ២០១៦ | ២០១៨ | អគ្គ. រតនាគារជាតិ | ប្រព័ន្ធកត់ត្រាបំណុលកកស្ទះនិងអាយុកាលបំណុលកកស្ទះមានភាពច្បាស់លាស់ព្រមទាំងមានយន្តការត្រួតពិនិត្យត្រឹមត្រូវ | | | | | | | | | | | | | | | | | | | | | | |
| ១៣.៥. ទូទាត់បុរេប្រទានឱ្យបានទាន់ពេលវេលា | ២០១៦ | ២០១៨ | -អគ្គ. ថវិកា<br>-អគ្គ.រតនាគារជាតិ | ថវិកាបុរេប្រទានត្រូវបានទូទាត់ទាន់ពេលវេលា | | | | | | | | | | | | | | | | | | | | | | |
| **១៤. កែលម្អការអនុវត្តថវិកា និងពង្រឹងការអនុវត្តផែនការចំណាយ** | **២០១៦** | **២០១៨** | | **ការអនុវត្តចំណាយប្រចាំត្រីមាសមានភាពរលូននិងអាចប៉ាន់ស្មានបាន (កម្រិតលម្អៀងនៃការអនុវត្តមិនលើស ៥%)** | | | | | | | | | | | | | | | | | | | | | | |
| ១៤.១. ការធ្វើសុខដុមនីយ- | ២០១៦ | ២០១៨ | -អគ្គ. លទ្ធកម្ម | សៀវភៅណែនាំ | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/ TA |
| | | | | | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | | |
| កម្មវាងការអនុវត្តវិធាន និងបទប្បញ្ញត្តិស្តីពីលទ្ធកម្មសាធារណៈ (IRRPP) និង ស្តង់ដារនីតិវិធីរួម (SOP/PM) | | | -អគ្គ. ថវិកា | ស្តីពីលទ្ធកម្មសាធារណៈ (PPM) ត្រូវបានរៀបចំនិងអនុម័តដាក់ឱ្យប្រើប្រាស់ | | | | | | | | | | | | | | | | | | | | | | |
| ១៤.២. បង្កើនការប្រកួតប្រជែង និងតម្លាភាពក្នុងដំណើរការលទ្ធកម្ម ដោយមានការចូលរួមជាសាធារណៈ | ២០១៦ | ២០១៨ | -អគ្គ. លទ្ធកម្ម | **១.** កិច្ចលទ្ធកម្មប្រព្រឹត្តទៅដោយតម្លាភាព, គណនេយ្យភាព និងប្រសិទ្ធភាព តាមរយៈការផ្សព្វផ្សាយ÷<br>ក. ការប្រកាសដេញថ្លៃ<br>ខ. ផែនការលទ្ធកម្ម<br>គ. ការប្រគល់កិច្ចសន្យា និង<br>ឃ. លទ្ធផលនៃការដោះស្រាយបណ្តឹងជាសាធារណៈ | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្ដើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/TA |
| | | | | | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | | |
| | | | | (គេហទំព័រ)<br>**២.**គណៈកម្មាធិការដោះស្រាយបណ្ដឹងតវ៉ាស្ដីពីលទ្ធកម្មត្រូវបានបង្កើត | | | | | | | | | | | | | | | | | | | | | | |
| ១៤.៣. រៀបចំផែនការចំណាយប្រចាំត្រីមាសឱ្យមានសុក្រឹតភាព | ២០១៦ | ២០១៨ | -អគ្គ.ថវិកា<br>-ក្រសួង ស្ថាប័ន | **១.**ផែនការចំណាយប្រចាំត្រីមាសត្រូវបានរៀបចំប្រកបដោយសុក្រឹតភាព (កម្រិតលំអៀងមិនលើសពី+/-៥%)<br>**២.** មានរបាយការណ៍ស្ដីពីចំណាយ ដែលបញ្ជាក់ពីកម្រិតលម្អៀងប្រចាំត្រីមាស +/-៥% | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/ TA |
| | | | | | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | | |
| **ផ្នែកទី២ ÷ បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ** | | | | | | | | | | | | | | | | | | | | | | | | | | |
| - ប្រព័ន្ធ យន្តការ គ្របខ័ណ្ឌគតិយុត្ត ត្រូវបានដាក់ឱ្យអនុវត្តប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព ត្រឹមឆ្នាំ២០១៨ (ចំណាត់ថ្នាក់ថវិកា ប្លង់គណនី និងការអនុវត្ត FMIS ដំណាក់កាលទី១ និងដំណាក់កាលទី២ | | | | | | | | | | | | | | | | | | | | | | | | | | |
| - ប្រព័ន្ធគណនេយ្យ ប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុវត្តប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព តម្លាភាព សុក្រឹតភាព និងទាន់ពេលវេលា | | | | | | | | | | | | | | | | | | | | | | | | | | |
| **២១. ពង្រឹងការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនីថ្មី** | **២០១៦** | **២០១៨** | | **ការអនុវត្តប្លង់គណនីថ្មី និងចំណាត់ថ្នាក់ថវិកាថ្មីត្រូវបានអនុវត្តពេញលេញប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព** | | | | | | | | | | | | | | | | | | | | | | |
| ២១.១. បន្តកែលម្អប្លង់គណនីថ្មី និងចំណាត់ថ្នាក់ថវិកាថ្មី (ភូមិសាស្ត្រ, អង្គភាពប្រតិបត្តិនិងរដ្ឋបាល, កម្មវិធី និង សេដ្ឋកិច្ច) និងអនុវត្តចំណាត់ថ្នាក់បី បន្ថែមទៀត | ២០១៦ | ២០១៨ | -អគ្គ.រតនាគារជាតិ<br>-អគ្គ.ថវិកា<br>-អគ្គ.ហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ | **១.** ប្លង់គណនី និងចំណាត់ថ្នាក់ថវិកាថ្មី ត្រូវបានរៀបចំរួចរាល់ សម្រាប់អនុវត្ត<br>**២.** ចំណាត់ថ្នាក់ភូមិសាស្ត្រ, អង្គភាពប្រតិបត្តិ | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/TA |
| | | | | | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | | |
| (មុខងារ, មូលនិធិ និង គម្រោង) | | | | និងរដ្ឋបាល, កម្មវិធី និង សេដ្ឋកិច្ចត្រូវបាន អនុវត្តពេញលេញ នៅឆ្នាំ ២០១៦ | | | | | | | | | | | | | | | | | | | | | | |
| **២២. ពង្រឹងការអនុវត្ត ប្រព័ន្ធអនុវត្តថវិកាថ្មី និង ដំណើរការ ប្រតិបត្តិការថ្មី** | **២០១៦** | **២០១៨** | | **ប្រព័ន្ធអនុវត្តថវិកា ថ្មីនិងដំណើរការ ប្រតិបត្តិការថ្មីត្រូវ បានអនុវត្តប្រកប ដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព** | | | | | | | | | | | | | | | | | | | | | | |
| ២២.១. បន្ទកាត់បន្ថយ ពេលវេលាសម្រាប់ សំណើសុំធានាចំណាយ និងការទូទាត់ នៅតាម ក្រសួង-ស្ថាប័ន | ២០១៦ | ២០១៨ | -អគ្គ.ថវិកា<br>-អគ្គ.រតនាគារជាតិ<br>-ក្រសួង-ស្ថាប័ន | **១.** នីតិវិធីខ្លី, ដំណើរការលឿន និងមានប្រសិទ្ធភាព<br>**២.** ការស្នើសុំធានា ចំណាយ និងការ ទូទាត់ត្រូវបាន អនុវត្តតាមប្រព័ន្ធ FMIS<br>៣. នីតិវិធី ប្រតិបត្តិរួម | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/TA |
| | | | | | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | | |
| | | | | (SOP) ត្រូវបាន រៀបចំ និងអនុវត្ត ៤. ដំណើរការ ទូទាត់នៅរតនាគារ ជាតិត្រូវបានកាត់ បន្ថយ មកត្រឹម ១០-១៥ នៃថ្ងៃ ធ្វើការ ចាប់ពីឆ្នាំ ២០១៦ | | | | | | | | | | | | | | | | | | | | | | | |
| ២២.២. កែលម្អប្រតិបត្តិការនៅក្នុងកសហវ/ក្រសួង-ស្ថាប័ន ដើម្បីឱ្យស្របទៅនឹងការវិវឌ្ឍន៍នៃប្លង់គណនី និងបទដ្ឋានគណនេយ្យ ព្រមទាំងធ្វើការផ្ទៀងផ្ទាត់គណនីធនាគារជាប្រចាំ | ២០១៦ | ២០១៨ | -គ្រប់អគ្គនាយកដ្ឋាន<br>-ក្រសួង-ស្ថាប័ន | កិច្ចប្រតិបត្តិការគណនេយ្យត្រូវបានកែលម្អនិងមានការផ្ទៀងផ្ទាត់គណនីធនាគារជាប្រចាំ | | | | | | | | | | | | | | | | | | | | | | |
| ២២. ៣. បង្កើនកម្រិតយល់ដឹង, ភាពជាម្ចាស់, ការចូលរួម និងសមត្ថភាពផ្នែក FMIS | ២០១៦ | ២០១៨ | -ក្រុមការងារ FMWG<br>-ក្រសួង-ស្ថាប័ន | ការយល់ដឹង, ភាពជាម្ចាស់, ការចូលរួម និងសមត្ថភាពផ្នែក | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/TA |
| | | | | | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | | |
| ដល់ កសហវ ក្រសួង-ស្ថាប័ន និងរដ្ឋបាលថ្នាក់ក្រោមជាតិ | | | | FMIS ត្រូវបានបង្កើនសមស្រប | | | | | | | | | | | | | | | | | | | | | | |
| ២២.៤. កសាងសមត្ថភាពគ្រប់គ្រងគម្រោង FMIS ដោយរួមទាំងនៅ កសហវ ក្រសួង-ស្ថាប័ន និងអង្គភាពថ្នាក់ក្រោមជាតិ | ២០១៦ | ២០១៨ | -ក្រុមការងារ FMWG<br>-ក្រសួង-ស្ថាប័ន | ការគ្រប់គ្រងគម្រោង FMIS ប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព | | | | | | | | | | | | | | | | | | | | | | |
| ២២.៥. អនុវត្តសាកល្បងជំហានដំបូង និងពង្រីកការអនុវត្ត FMIS (ម៉ូឌុលស្នូល និងម៉ូឌុលសម្រាប់ថវិកា និងពង្រីកការអនុវត្ត FMIS ទៅក្រសួង-ស្ថាប័ន) | ២០១៦ | ២០១៨ | -ក្រុមការងារ FMWG<br>-ក្រសួង-ស្ថាប័ន | ១. ការអនុវត្តជំហានដំបូងដោយជោគជ័យ និងផែនការពង្រីកការអនុវត្តត្រូវបានរៀបចំ<br>២. គម្រោង FMIS ជំហានទី១ ត្រូវបានអនុវត្ត នៅក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងរតនាគារខេត្ត | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/TA |
| | | | | | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | | |
| | | | | ក្នុងឆ្នាំ២០១៦<br>៣.គម្រោងអនុវត្ត FMIS ជំហានទី២ ត្រូវបានរៀបចំ និងឯកសារដេញថ្លៃត្រូវបានចេញផ្សាយ នៅក្នុង ២០១៦<br>៤. ពេលវេលាបញ្ចូលទិន្នន័យ និងរបាយការណ៍ត្រូវបានកាត់បន្ថយមកត្រឹមតិចជាង ៣០ នាទី ក្នុងឆ្នាំ ២០១៦<br>៥.អនុវត្តការត្រួតពិនិត្យថវិកា (ការធានាចំណាយ ការទូទាត់ និង ចំណូល) និង របាយការណ៍ | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/TA |
| | | | | | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | | |
| | | | | ហិរញ្ញវត្ថុ នៅ កសហវ តាមរយៈ ប្រព័ន្ធ FMIS<br>**៦.** ម៉ូឌុលសម្រាប់ត្រួតពិនិត្យនិងអនុវត្តថវិកា រួមមាន ការវិភាជថវិកា, គណនីសៀវភៅធំ, គណនីត្រូវទទួល, គណនីត្រូវសង, ការគ្រប់គ្រងសាច់ប្រាក់ និងការបញ្ញើទិញត្រូវបានអនុវត្តនៅឆ្នាំ ២០១៦ | | | | | | | | | | | | | | | | | | | | | | | | | | |
| **២៣. ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និងប្រព័ន្ធតម្លាភាព** | **២០១៦** | **២០១៨** | | **ប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការ ណ៍ថ្មី និងប្រព័ន្ធតម្លាភាព ត្រូវបានអនុវត្តប្រកបដោយ** | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្ដើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/ TA |
| | | | | | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | | |
| | | | | **ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព** | | | | | | | | | | | | | | | | | | | | | | |
| ២៣.១. រៀបចំស្តង់ដារគណនេយ្យសាធារណៈស្របតាមស្តង់ដារ IPSAS និងដាក់ឱ្យអនុវត្តជាបណ្តើរៗ តាមលំដាប់លំដោយ ព្រមទាំងផ្សារភ្ជាប់ទៅនឹងការពង្រីកការប្រើប្រាស់ FMIS និងបង្កើតជម្រើសសម្រាប់ការអនុវត្ត ជាជំហានៗ ទៅរកការអនុវត្តគណនីបង្គរ | ២០១៦ | ២០១៨ | អគ្គ. រតនាគារជាតិ | **១.** ស្តង់ដារគណនេយ្យ ត្រូវបានដាក់ឱ្យអនុវត្ត<br>**២.** រយៈពេលបិទបញ្ជិកាគណនេយ្យត្រូវបានកាត់បន្ថយ មកត្រឹម ៣-៤ ខែ នៅឆ្នាំ២០១៦<br>**៣.** របាយការណ៍ហិរញ្ញវត្ថុដោយមានមូលដ្ឋានលើសាច់ប្រាក់តាមស្តង់ដារ IPSAS មួយផ្នែក ត្រូវបានរៀបចំនៅឆ្នាំ២០១៦ | | | | | | | | | | | | | | | | | | | | | | |
| ២៣.២. កែលម្អទម្រង់របាយការណ៍អនុវត្តថវិកាដែលត្រូវផ្ញើទៅ | ២០១៦ | ២០១៨ | -អគ្គ. ថវិកា<br>-អគ្គ.រតនាគារជាតិ | ទម្រង់របាយការណ៍អនុវត្តថវិកា (របាយការណ៍ | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/ អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/ TA |
| | | | | | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | | |
| គណៈរដ្ឋមន្ត្រី និង ស្ថាប័ននីតិប្បញ្ញត្តិ | | | | សមិទ្ធកម្ម និង ហិរញ្ញវត្ថុ) ត្រូវបានកែលម្អ | | | | | | | | | | | | | | | | | | | | | | |
| ២៣.៣. កែលម្អទម្រង់របាយការណ៍និងការផ្លាស់ប្តូរព័ត៌មានជាមួយសាធារណជន | ២០១៦ | ២០១៨ | ក្រសួង-ស្ថាប័ន | **១.** ទម្រង់របាយការណ៍និងការផ្លាស់ប្តូរព័ត៌មានជាមួយសាធារណៈជនត្រូវបានកែលម្អ **២.** តារាងសង្ខេបទិន្នន័យថវិកា (Budget in Brief) ត្រូវបានរៀបចំបន្ទាប់ពីថវិកាជាតិ ត្រូវបានអនុម័តសម្រាប់ស្ថាប័ននីតិប្បញ្ញត្តិ និងសាធារណៈជន **៣.** តារាងហិរញ្ញវត្ថុនិងចំណាយ | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/ TA |
| | | | | | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | | |
| | | | | សាធារណៈ (TOFE) និង ព្រឹត្តិបត្រស្ថិតិ ត្រូវបានរៀបចំ ប្រចាំខែ និង បង្ហោះទៅក្នុង គេហទំព័រ ក្នុង រយៈពេល ៣ខែ បន្ទាប់ពីការរៀបចំ របាយការណ៍ផុត កំណត់<br>៤.របាយការណ៍ ត្រួតពិនិត្យការ អនុវត្តថវិកាប្រចាំ ឆមាសត្រូវបាន រៀបចំនិង ផ្សព្វផ្សាយក្នុង គេហទំព័រ ក្នុង រយៈពេល ៣ខែ បន្ទាប់ពី របាយការណ៍នេះ | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/TA |
| | | | | | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | តម១ | តម២ | តម៣ | តម៤ | | |
| | | | | ត្រូវបានរៀបចំរួចរាល់ (ឆ្នាំ២០១៧)<br>**៥.** របាយការណ៍នៃការអនុវត្តថវិកាប្រចាំឆ្នាំត្រូវបានរៀបចំ និងបង្ហោះក្នុងគេហទំព័រ ក្នុងរយៈពេល១២ ខែបន្ទាប់ពីបញ្ចប់ឆ្នាំនីមួយៗ | | | | | | | | | | | | | | | | | | | | | | |
| ២៣.៤. ដាក់ឱ្យអនុវត្តយន្តការដើម្បីបញ្ចប់ការចុះបញ្ជីសារពើភ័ណ្ឌទ្រព្យសម្បត្តិរដ្ឋ និងធ្វើបច្ចុប្បន្នភាពជាប្រចាំ | ២០១៦ | ២០១៨ | -អគ្គ.ទ្រព្យរដ្ឋ<br>-ក្រសួង-ស្ថាប័ន | នីតិវិធីនិងយន្តការចុះបញ្ជីសារពើ-ភ័ណ្ឌត្រូវបានអនុវត្ត និងត្រូវធ្វើបច្ចុប្បន្នភាពជាប្រចាំ | | | | | | | | | | | | | | | | | | | | | | |
| **២៤. ពង្រឹងការអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និង** | **២០១៦** | **២០១៨** | | **ឧបករណ៍ និងយន្តការត្រូវបានដាក់ឱ្យអនុវត្តដើម្បីបង្កើនការ** | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/អង្គភាព | សូចនាករសមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/TA |
| | | | | | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | ត ម ១ | ត ម ២ | ត ម ៣ | ត ម ៤ | | |
| **គណនេយ្យភាព (ប្រព័ន្ធត្រួតពិនិត្យ)** | | | | **ទទួលខុសត្រូវនិងគណនេយ្យភាព** | | | | | | | | | | | | | | | | | | | | | | |
| ២៤.១. បង្កើតឱ្យមានទណ្ឌកម្មរដ្ឋបាលសមស្រប ចំពោះកំហុសឆ្គង ឬការគ្រប់គ្រងធនធានសាធារណៈមិនសមស្រប និងគ្មានប្រសិទ្ធភាព។ ទណ្ឌកម្មនេះត្រូវចែងនៅក្នុងលិខិតបទដ្ឋានគតិយុត្ត និង ធ្វើការផ្សព្វផ្សាយ និងណែនាំឱ្យបានទូលំទូលាយ | ២០១៦ | ២០១៨ | -អគ្គលេខាធិការដ្ឋាន<br>-ក្រសួង-ស្ថាប័ន | ទណ្ឌកម្មរដ្ឋបាលសមស្របចំពោះកំហុសឆ្គង ត្រូវបានកំណត់នៅក្នុងលិខិតបទដ្ឋានគតិយុត្ត | | | | | | | | | | | | | | | | | | | | | | |
| ២៤.២. ធ្វើបច្ចុប្បន្នភាពនិងផ្តល់សិទ្ធិអំណាចនិងភាពទន់ភ្លន់ ជាបន្តបន្ទាប់ ជូនអង្គភាពថវិកា | ២០១៦ | ២០១៨ | -អគ្គ.ថវិកា<br>-ក្រសួង-ស្ថាប័ន | សិទ្ធិអំណាចនិងការទទួលខុសត្រូវរបស់អង្គភាពថវិកា ត្រូវបានពង្រឹងនិងកែលម្អ | | | | | | | | | | | | | | | | | | | | | | |
| ២៤.៣.ត្រួតពិនិត្យឡើងវិញ លើការអនុវត្តសិទ្ធិ | ២០១៦ | ២០១៨ | -អគ្គ.ថវិកា<br>-អគ្គាធិការដ្ឋាន | របាយការណ៍និងអនុសាសន៍ | | | | | | | | | | | | | | | | | | | | | | |

| គោលបំណង/ ចង្កោមសកម្មភាព | ពេលវេលាត្រូវការ | | ក្រសួង-ស្ថាប័ន/ អង្គភាព | សូចនាករ សមិទ្ធកម្មគន្លឹះ | គោលដៅសូចនាករសមិទ្ធកម្មគន្លឹះ | | | | | | | | | | | | | | | | | | | | ប្រភពហិរញ្ញប្បទាន | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចាប់ផ្តើម | បញ្ចប់ | | | ២០១៦ | | | | ២០១៧ | | | | ២០១៨ | | | | ២០១៩ | | | | ២០២០ | | | | ប្រភព | $/ TA |
# ការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

## វិធីសាស្ត្រនៃការកំណត់ទម្ងន់និងការវាយតម្លៃ
## ការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ

វិធីសាស្ត្រនៃការកំណត់ទម្ងន់និងការវាយតម្លៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ គឺជាឧបករណ៍វាយតម្លៃលទ្ធផលនៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ បន្ថែមលើយន្តការត្រួតពិនិត្យតាមដាន និងវាយតម្លៃដែលមានស្រាប់។

ផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ រួមមាន ផែនការសកម្មភាពរួម (CAP) ផែនការសកម្មភាពលម្អិតរបស់អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ (GDAP) និងផែនការសកម្មភាពលម្អិតរបស់ក្រសួង-ស្ថាប័ន (MAP)។ ដើម្បីឱ្យផែនការសកម្មភាពរួម អាចសម្រេចបានតាមសូចនាករគន្លឹះដែលបានដាក់ចេញ តម្រូវឱ្យមានផែនការសកម្មភាពលម្អិតដែលអនុវត្តដោយក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន។

វិធីសាស្ត្រដាក់ពិន្ទុនេះ មានលក្ខណៈវិទ្យាសាស្ត្រនិងច្បាស់លាស់សម្រាប់ការវាស់វែងលទ្ធផលនៃការអនុវត្តផែនការសកម្មភាព។ ដើម្បីឱ្យវិធីសាស្ត្រនេះអនុវត្តបានប្រកបដោយសុក្រឹតភាព និងប្រសិទ្ធភាព អង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួង-ស្ថាប័ន ត្រូវរៀបចំផែនការសកម្មភាពរបស់ខ្លួនដើម្បីសម្រេចបាន សូចនាករគន្លឹះនៃចង្កោមសកម្មភាព គោលបំណង និងផ្នែកនីមួយៗរបស់ផែនការសកម្មភាពរួមដំណាក់កាលទី៣ និងត្រូវកំណត់សូចនាករមានលក្ខណៈ SMART ពោលគឺជាក់លាក់ (Specific), អាចវាស់វែងបាន (Measurable), អាចសម្រេចបាន (Achievable), ត្រឹមត្រូវតាមមុខងារ (Relevant) និងមានពេលវេលាកំណត់ជាក់លាក់ (Time-bound)។

ដើម្បីវាយតម្លៃការអនុវត្តផែនការសកម្មភាពកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ការកំណត់ទម្ងន់ ចែកចេញជាបួនកម្រិត គឺកម្រិតចង្កោមសកម្មភាព, កម្រិតគោលបំណង, កម្រិតផ្នែក និងកម្រិតកម្មវិធី ទៅតាមទម្ងន់ដែលបានកំណត់ទុកជាមុន។

**១. កម្រិតចង្កោមសកម្មភាព÷**

ពិន្ទុចង្កោមសកម្មភាពនីមួយៗបានមកពីពិន្ទុសរុបនៃសកម្មភាពលម្អិត (GDAP/MAP) ដែលមានទម្ងន់ខុសៗគ្នា ដើម្បីរួមចំណែកសម្រេចឱ្យបានសូចនាករគន្លឹះនៃចង្កោមសកម្មភាព។

**២. កម្រិតគោលបំណង÷**

ពិន្ទុគោលបំណងនីមួយៗបានមកពីពិន្ទុសរុបនៃចង្កោមសកម្មភាពដែលមានទម្ងន់ខុសៗគ្នា។

**៣. កម្រិតផ្នែក÷**

ពិន្ទុផ្នែកនីមួយៗបានមកពីពិន្ទុសរុបនៃគោលបំណងដែលមានទម្ងន់ខុសៗគ្នា។

**៤. កម្រិតកម្មវិធី÷**

ពិន្ទុនៃការអនុវត្តកម្មវិធី បានមកពីពិន្ទុសរុបនៃផ្នែកទាំង៥ នៃផែនការសកម្មភាពរួមដំណាក់កាលទី៣ ដែលមានទម្ងន់ខុសៗគ្នា។

ទម្ងន់នៃសកម្មភាពលម្អិតដែលចូលរួមចំណែកសម្រេចបាននូវសូនាករសមិទ្ធកម្មគន្លឹះ កម្រិតចង្កោមសកម្មភាព ត្រូវកំណត់ដោយអង្គភាពក្រោមឱវាទក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ និងក្រសួងស្ថាប័ន និងដោយមានការពិភាក្សាជាមួយ **អ.គ.ហ.**។ ដោយឡែក ទម្ងន់នៃចង្កោមសកម្មភាព គោលបំណង និងផ្នែកនីមួយៗ ដើម្បីសម្រេចបាននូវកម្មវិធី ត្រូវកំណត់ដោយប្រធានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។

ទោះបីទម្ងន់នៃការដាក់ពិន្ទុនៅតាមកម្រិតនីមួយៗ មានខុសៗគ្នា ប៉ុន្តែវិធីសាស្ត្រអនុវត្តមានដូចគ្នានៅគ្រប់កម្រិតទាំងអស់ ដោយតារាងដាក់ពិន្ទុនៃកម្រិតនីមួយៗ ចែកចេញជា ៥ កូឡោន ដែលមានអត្ថន័យដូចខាងក្រោម÷

**កូឡោនទី១÷** បង្ហាញពីលទ្ធផលចុងក្រោយ ដែលលទ្ធផលចុងក្រោយនីមួយៗសម្រេចបានមកពីការចូលរួមចំណែក ពីលទ្ធផលក្នុងឆ្នាំនៃកូឡោនទី២ ហើយមានទម្ងន់ខុសៗគ្នាក្នុងការរួមចំណែកសម្រេចបានលទ្ធផលចុងក្រោយមួយទៀត។

**កូឡោនទី២÷** បង្ហាញពីលទ្ធផលក្នុងឆ្នាំនិងទម្ងន់ ដើម្បីចូលរួមចំណែកសម្រេចឱ្យបានលទ្ធផលចុងក្រោយ។ លទ្ធផលក្នុងឆ្នាំ មានទម្ងន់ខុសៗគ្នា ហើយទម្ងន់សរុបនៃសកម្មភាពទាំងអស់

គឺស្មើនឹង ១.០០ ដើម្បីសម្រេចបានលទ្ធផលចុងក្រោយ។ ឧទាហរណ៍ ដើម្បីសម្រេចបានលទ្ធផលចុងក្រោយកម្រិតកម្មវិធីនៃផែនការសកម្មភាពរួមដំណាក់កាលទី៣ ត្រូវមានការចូលរួមចំណែកលទ្ធផលក្នុងឆ្នាំរបស់ផ្នែកទាំង៥ ដែលផ្នែកទី១ មានទម្ងន់ ០.១០, ផ្នែកទី២ មានទម្ងន់ ០.២០, ផ្នែកទី៣ មានទម្ងន់ ០.៤០, ផ្នែកទី៤ មានទម្ងន់ ០.១០ និងផ្នែកទី៥ មានទម្ងន់ ០.២០។

**ក្ងួឡោនទី៣÷** បង្ហាញពីសូចនាករគន្លឹះនៃលទ្ធផលចុងក្រោយ និងលទ្ធផលក្នុងឆ្នាំដែលមាននៅក្នុងផែនការសកម្មភាពរួម ដោយកំណត់ឯកតានិងទម្ងន់ឱ្យបានច្បាស់លាស់។ ការកំណត់ឯកតានៃសូចនាករសមិទ្ធកម្មគន្លឹះ អាចជាចំនួន ឬជាភាគរយតាមភាពសមស្របនៃការវាស់វែងបាននៃសូចនាករនីមួយៗ។ លទ្ធផលក្នុងឆ្នាំអាចមានសូចនាករសមិទ្ធកម្មគន្លឹះចំនួនមួយ ឬច្រើនជាងមួយ។ ចំពោះលទ្ធផលក្នុងឆ្នាំដែលមានច្រើនជាងមួយត្រូវកំណត់ទម្ងន់ ដើម្បីងាយស្រួលវាយតម្លៃលើការរួមចំណែករបស់សូចនាករនីមួយៗ។ លើសពីនេះ ទម្ងន់នៃសូចនាករសមិទ្ធកម្មគន្លឹះត្រូវកំណត់ទុកជាមុន ដូចការកំណត់ទម្ងន់នៃលទ្ធផលក្នុងឆ្នាំ ក្នុងក្ងួឡោនទី២ដែរ។

**ក្ងួឡោនទី៤÷** បង្ហាញពីការវាយតម្លៃលើគោលដៅនៃសូចនាករសម្រេចបាន ដែលគោលដៅទាំងនោះ ត្រូវបានវាយតម្លៃជាភាគរយតាមកម្រិតនៃការសម្រេចបាន ដែលបានកំណត់ទុកជាមុន គឺ ចាប់ពី ៩១% ឡើងទៅស្មើ ល្អណាស់,ពី៨១% ដល់ ៩០% ស្មើ ល្អ, ពី៧១% ដល់ ៨០% ស្មើ ល្អបង្គួរ, ពី៦១% ដល់ ៧០% ស្មើ មធ្យម និង ទាបជាង ឬស្មើ ៦០% ស្មើ ខ្សោយ។ ជាទូទៅ គោលដៅនៃសូចនាករដែលត្រូវសម្រេចឱ្យបាន អាចជាភាគរយ, ចំនួន, ភាគរយនៃកំណើន ឬ ភាគរយនៃការថយចុះ។ បើសិនជាគោលដៅសូចនាករសមិទ្ធកម្មនីមួយៗ ដែលត្រូវសម្រេចបានសូចនាករសមិទ្ធកម្មគន្លឹះរួម មានលក្ខណៈជាដំណាក់កាលនៃកិច្ចប្រតិបត្តិការការងារ ក្នុងករណីនេះ ត្រូវដាក់ទម្ងន់ដំណាក់កាលនីមួយៗដែលជាគោលដៅសូចនាករសមិទ្ធកម្មនោះ ជាភាគរយ។ ឧទាហរណ៍ (១)-ការត្រួតពិនិត្យឡើងវិញលើច្បាប់ស្តីពីប្រព័ន្ធហិរញ្ញវត្ថុសាធារណៈ ឆ្នាំ ២០០៨ ដើម្បីឈានទៅធ្វើវិសោធនកម្ម សម្រេចបាន ៧៥% ដូចនេះការវាយតម្លៃលើគោលដៅសម្រេចបានគឺ ល្អបង្គួរ។ ឧទាហរណ៍ (២)-សូចនាករគោលដៅនៃការបណ្តុះបណ្តាលគ្រូបង្គោលថវិកាកម្មវិធីតាមក្រសួង-ស្ថាប័ន ត្រូវសម្រេចឱ្យបាន ចំនួន១០នាក់ ដែលការវាយតម្លៃលើគោលដៅសម្រេចបាន គឺធ្វើទៅតាមចំនួននៃមន្ត្រីដែលបានបណ្តុះបណ្តាលជាក់ស្តែង។ ក្នុងករណីនេះ ការកំណត់លទ្ធផលសម្រេចបានទុកជាមុនតាមកម្រិតវាយតម្លៃទាំង៥ គឺ ប្រសិនបើសម្រេចបាន ១០នាក់ គឺ ល្អណាស់ (១០០%), សម្រេចបាន ៩នាក់គឺ ល្អ (៩០%), សម្រេចបាន៨នាក់គឺ

ល្អបង្គួរ (៨០%), សម្រេចបាន៧នាក់ គឺ មធ្យម (៧០%) និងសម្រេចបាន ៦នាក់ គឺ ខ្សោយ (៦០%)។ ម្យ៉ាងទៀត ប្រសិនបើគោលដៅនៃសូចនាករ មានលក្ខណៈជាភាគរយនៃកំណើន/ការថយចុះ ឧទាហរណ៍ ការអនុវត្តផែនការប្រមូលចំណូលប្រចាំឆ្នាំ មិនឱ្យលើសពី +/-៥% ធៀបនឹងច្បាប់ថវិកា, ការកំណត់លទ្ធផលសម្រេចបានតាមកម្រិតនៃការវាយតម្លៃទាំង ៥ គឺ សម្រេចបានក្នុងចន្លោះពី ៩៥% ដល់ ១០៥% គឺសម្រេចបាន ល្អណាស់ (១០០%), ចន្លោះពី ៩៤% ដល់ ១០៦% គឺសម្រេចបាន ល្អ (៩០%), ចន្លោះពី ៩៣% ដល់ ១០៧% គឺសម្រេចបានល្អបង្គួរ (៨០%), ចន្លោះពី ៩៣% ដល់ ១០៨% សម្រេចបានមធ្យម (៧០%) និងក្រៅចន្លោះពី ៩៣% ដល់ ១០៨% នោះ គឺខ្សោយ (៦០%)។ ឧទាហរណ៍ (៣)-កំណើនការប្រមូលក្នុងស្រុកប្រចាំឆ្នាំត្រូវសម្រេចឱ្យបាន ០.៥% ពិន្ទុភាគរយ នៃផលិតផលក្នុងស្រុកសរុប។ ក្នុងករណីនេះ ការកំណត់លទ្ធផលសម្រេចបានតាមកម្រិតនៃការវាយតម្លៃទាំង ៥ គឺ ប្រសិនបើកំណើនមាន ០.៥% ទទួលបានពិន្ទុល្អណាស់ (១០០%), កំណើនចន្លោះពី ០.៤% ដល់ ០.៦% ទទួលបានពិន្ទុល្អ (៩០%), កំណើនចន្លោះពី ០.៣% ដល់ ០.៧% ទទួលបានពិន្ទុល្អបង្គួរ (៨០%), កំណើនចន្លោះពី ០.២% ដល់ ០.៨% ទទួលបានពិន្ទុមធ្យម (៧០%) ហើយក្រៅចន្លោះពី ០.២% ដល់ ០.៨% នោះ ទទួលបានពិន្ទុខ្សោយ (៦០%)។

**ក្ឡោនទី៥÷** បង្ហាញពីលទ្ធផលសរុបសម្រេចបានដែលក្នុងនោះមានលទ្ធផលសម្រេចបាន, ពិន្ទុផ្ទាល់ និងពិន្ទុសម្រួល។ ក្ឡោននេះទំនេរ និងសម្រាប់ដាក់ពិន្ទុជាក់ស្ដែង នៅពេលអនុវត្តផែនការសកម្មភាព ដែលខុសពីក្ឡោនទី១, ក្ឡោនទី២, ក្ឡោនទី៣ និងក្ឡោនទី៤ ដែលលទ្ធផល, ទម្ងន់, សូចនាករសមិទ្ធកម្មគន្លឹះ ឬ គោលដៅសម្រេចបានត្រូវបានកំណត់ទុកជាមុន។

- **លទ្ធផលសម្រេចបាន÷** អាចជាចំនួន ឬភាគរយនៃសូចនាករសមិទ្ធកម្មគន្លឹះដែលសម្រេចបានជាក់ស្ដែង។
- **ពិន្ទុផ្ទាល់÷** ជាពិន្ទុផ្ទាល់ក្នុងឆ្នាំរបស់សូចនាករសមិទ្ធកម្មគន្លឹះនីមួយៗដែលសម្រេចបានជាភាគរយតាមកម្រិតវាយតម្លៃទាំង៥។
- **ពិន្ទុសម្រួល÷** ជាពិន្ទុដែលត្រូវចូលរួមចំណែកដើម្បីសម្រេចឱ្យបានលទ្ធផលចុងក្រោយទៅតាមទម្ងន់ ដែលបានកំណត់ទុកជាមុន។ ពិន្ទុសម្រួល គឺជាផលគុណនៃពិន្ទុផ្ទាល់នឹងទម្ងន់ផ្ទាល់របស់សូចនាករនីមួយៗ។

## តារាងទី១ ÷ ការកំណត់ទម្ងន់កម្រិតគោលបំណង
## (២១ គោលបំណង, ៦៧ ចង្កោមសកម្មភាព)

| លទ្ធផលចុងក្រោយ (កម្រិតគោលបំណង) (១) | លទ្ធផលក្នុងឆ្នាំ ឬត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចង្កោមសកម្មភាព | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| ១១. បន្តពង្រឹងការគ្រប់គ្រងចំណូលនិងការអនុវត្តផែនការប្រមូលចំណូល | | | ការអនុវត្តចំណូលប្រចាំត្រីមាស មានភាពរលូន និងអាចប៉ាន់ស្មានបាន (កម្រិតលម្អៀងនៃការអនុវត្តមិនលើសពី ៥%) | | | | | | | | | | |
| | ១១.១ | | | | | | | | | | | | |
| | ១១.២ | | | | | | | | | | | | |
| | ១១.៣ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ១១ | | ១.០០ | ១.០០ | | | | | | | | | | |
| ១២. បន្តពង្រឹងការគ្រប់គ្រងបំណុល | | | ការគ្រប់គ្រងបំណុលត្រូវសង និងបំណុលត្រូវទារក្នុងឆ្នាំ ប្រកបដោយប្រសិទ្ធភាព | | | | | | | | | | |
| | ១២.១ | | | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតគោលបំណង) (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចង្កោមសកម្មភាព | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| | ១២.២ | | | | | | | | | | | | |
| | ១២.៣ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ១២ | | ១.០០ | | | | | | | | | | | |
| ១៣.ពង្រឹងការគ្រប់គ្រងសាច់ប្រាក់ និង គណនី | | | ផែនការសាច់ប្រាក់ត្រូវបានអនុវត្ត ប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព | | | | | | | | | | |
| | ១៣.១ | | | | | | | | | | | | |
| | ១៣.២ | | | | | | | | | | | | |
| | ១៣.៣ | | | | | | | | | | | | |
| | ១៣.៤ | | | | | | | | | | | | |
| | ១៣.៥ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ១៣ | | ១.០០ | | | | | | | | | | | |
| ១៤. កែលម្អការអនុវត្តថវិកា និង ពង្រឹងការអនុវត្តផែនការចំណាយ | | | ការអនុវត្តចំណាយប្រចាំខែ មានភាពរលូននិងអាចប៉ាន់ស្មានបាន | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតគោលបំណង) (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចង្កោមសកម្មភាព | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| | | | (កម្រិតលម្អៀងនៃការអនុវត្តមិនលើសពី៥%) | | | | | | | | | | |
| | ១៤.១ | | | | | | | | | | | | |
| | ១៤.២ | | | | | | | | | | | | |
| | ១៤.៣ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ១៤ | | ១.០០ | | | | | | | | | | | |
| ២១. ពង្រឹងការអនុវត្តមាតិកាថវិកាថ្មី និងប្លង់គណនីថ្មី | | | ការអនុវត្តប្លង់គណនីថ្មី និងចំណាត់ថ្នាក់ថវិកាថ្មី ត្រូវបានអនុវត្តពេញលេញ ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព | | | | | | | | | | |
| | ២១.១ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ២១ | | ១.០០ | | | | | | | | | | | |
| ២២. ពង្រឹងការអនុវត្តប្រព័ន្ធអនុវត្តថវិកាថ្មីនិងដំណើរការប្រតិបត្តិការថ្មី | | | ប្រព័ន្ធអនុវត្តថវិកាថ្មី និងដំណើរការប្រតិបត្តិការថ្មីត្រូវបានអនុវត្តប្រកបដោយ | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតគោលបំណង) (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចង្កោមសកម្មភាព | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| | | | ស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព | | | | | | | | | | |
| | ២២.១ | | | | | | | | | | | | |
| | ២២.២ | | | | | | | | | | | | |
| | ២២.៣ | | | | | | | | | | | | |
| | ២២.៤ | | | | | | | | | | | | |
| | ២២.៥ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ២២ | | ១.០០ | | | | | | | | | | | |
| ២៣. ពង្រឹងការអនុវត្តប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និង ប្រព័ន្ធតម្លាភាព | | | ប្រព័ន្ធគណនេយ្យថ្មី ប្រព័ន្ធកត់ត្រាថ្មី ប្រព័ន្ធរបាយការណ៍ថ្មី និង ប្រព័ន្ធតម្លាភាព ត្រូវបានអនុវត្តប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព | | | | | | | | | | |
| | ២៣.១ | | | | | | | | | | | | |
| | ២៣.២ | | | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតគោលបំណង) (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចង្កោម សកម្មភាព | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផល សម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុ សម្រួល |
| | ២៣.៣ | | | | | | | | | | | | |
| | ២៣.៤ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ២៣ | | ១.០០ | | | | | | | | | | | |
| ២៤. ពង្រឹងការអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវ និងគណនេយ្យភាព (ប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង) | | | ដាក់ឱ្យអនុវត្តឧបករណ៍ និងយន្តការដើម្បីបង្កើនការទទួលខុសត្រូវនិងគណនេយ្យភាព | | | | | | | | | | |
| | ២៤.១ | | | | | | | | | | | | |
| | ២៤.២ | | | | | | | | | | | | |
| | ២៤.៣ | | | | | | | | | | | | |
| | ២៤.៤ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ២៤ | | ១.០០ | | | | | | | | | | | |
| ៣១. ពង្រឹងនិងពង្រីក ការអនុវត្តថវិកាកម្មវិធី | | | ថវិកាកម្មវិធីត្រូវបានអនុវត្ត ប្រកបដោយប្រសិទ្ធភាព | | | | | | | | | | |
| | ៣១.១ | | | | | | | | | | | | |
| | ៣១.២ | | | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតគោលបំណង) (១) | លទ្ធផលក្នុងឆ្នាំ ឬត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចង្កោមសកម្មភាព | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| | ៣១.៣ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ៣១ | | ១.០០ | | | | | | | | | | | |
| ៣២. រៀបចំថវិកាឱ្យមានលក្ខណៈគ្រប់ជ្រុងជ្រោយ និងធ្វើសមាហរណ-កម្មថវិកា | | | ប្រតិបត្តិការទាំងអស់ត្រូវស្ថិតនៅក្នុងប្រព័ន្ធថវិកា។ ថវិកាចរន្តនិងមូលធនត្រូវបានធ្វើសមាហរណ-កម្ម។ | | | | | | | | | | |
| | ៣២.១ | | | | | | | | | | | | |
| | ៣២.២ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ៣២ | | ១.០០ | ១.០០ | | | | | | | | | | |
| ៣៣. រៀបចំនិងដាក់ឱ្យ អនុវត្តប្រព័ន្ធ បន្ទាត់គណនេយ្យភាព (រវាងនីតិប្បញ្ញត្តិ និង នីតិប្រតិបត្តិ, រវាង កសហវ និង ក្រសួង- ស្ថាប័ន និងនៅក្នុងក្រសួង-ស្ថាប័ន) | | | កំណត់និងដាក់ឱ្យអនុវត្តប្រព័ន្ធបន្ទាត់គណនេយ្យភាពស្របតាមថវិកាកម្មវិធី | | | | | | | | | | |
| | ៣៣.១ | | | | | | | | | | | | |
| | ៣៣.២ | | | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតគោលបំណង) (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចង្កោម សកម្មភាព | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផល សម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុ សម្រួល |
| | ៣៣.៣ | | | | | | | | | | | | |
| | ៣៣.៤ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ៣៣ | | ១.០០ | | | | | | | | | | | |
| ៣៤. ពង្រឹងការរៀបចំគោលនយោបាយនិងការធ្វើផែនការហិរញ្ញវត្ថុសាធារណៈ (ការរៀបចំគោលនយោបាយនិងផែនការចំណូលនិងចំណាយរយៈពេលមធ្យម) | | | គោលនយោបាយនិងផែនការហិរញ្ញវត្ថុសាធារណៈ (ចំណូលនិងចំណាយ) ឆ្លើយតបតាមស្ថានភាពសេដ្ឋកិច្ចនិងបម្រើវិស័យសាធារណៈ ប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព | | | | | | | | | | |
| | ៣៤.១ | | | | | | | | | | | | |
| | ៣៤.២ | | | | | | | | | | | | |
| | ៣៤.៣ | | | | | | | | | | | | |
| លទ្ធផលក្នុងឆ្នាំ គោលបំណង ៣៤ | | ១.០០ | | | | | | | | | | | |
| ៣៥. រៀបចំប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុង | | | ស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពនៃប្រព័ន្ធ | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតគោលបំណង) (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចង្កោម សកម្មភាព | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផល សម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុ សម្រួល |
| | | | និងយន្តការត្រួតពិនិត្យផ្ទៃក្នុងត្រូវបានបង្កើត និងអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័ន | | | | | | | | | | |
| | ៣៥.១ | | | | | | | | | | | | |
| | ៣៥.២ | | | | | | | | | | | | |
| | ៣៥.៣ | | | | | | | | | | | | |
| | ៣៥.៤ | | | | | | | | | | | | |
| | ៣៥.៥ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ៣៥ | | ១.០០ | | | | | | | | | | | |
| ៣៦. ពង្រឹងការអនុវត្តគោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុ | | | គោលនយោបាយវិមជ្ឈការហិរញ្ញវត្ថុត្រូវបានអនុវត្តប្រកបដោយប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាព | | | | | | | | | | |
| | ៣៦.១ | | | | | | | | | | | | |
| | ៣៦.២ | | | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតគោលបំណង) (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចង្កោមសកម្មភាព | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| | ៣៦.៣ | | | | | | | | | | | | |
| | ៣៦.៤ | | | | | | | | | | | | |
| | ៣៦.៥ | | | | | | | | | | | | |
| | ៣៦.៦ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ៣៦ | | ១.០០ | | | | | | | | | | | |
| ៤១. បង្កើតក្របខ័ណ្ឌថវិកាដោយផ្អែកលើសមិទ្ធកម្ម | | | ក្របខ័ណ្ឌថវិកាដោយផ្អែកលើសមិទ្ធកម្ម ត្រូវបានរៀបចំនិងផ្សព្វ-ផ្សាយបណ្តុះបណ្តាល | | | | | | | | | | |
| | ៤១.១ | | | | | | | | | | | | |
| | ៤១.២ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ៤១ | | ១.០០ | ១.០០ | | | | | | | | | | |
| ៤២. បង្កើតក្របខ័ណ្ឌគណនេយ្យភាពនៃសមិទ្ធកម្ម | | | ក្របខ័ណ្ឌគណនេយ្យភាពនៃសមិទ្ធកម្ម ត្រូវបានរៀបចំនិងផ្សព្វផ្សាយបណ្តុះបណ្តាល | | | | | | | | | | |
| | ៤២.១ | | | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតគោលបំណង) (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចង្កោម សកម្មភាព | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផល សម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុ សម្រួល |
| | ៤២.២ | | | | | | | | | | | | |
| លទ្ធផលក្នុងឆ្នាំ គោលបំណង ៤២ | | ១.០០ | ១.០០ | | | | | | | | | | |
| ៤៣. បង្កើតក្របខ័ណ្ឌសវនកម្មលើសមិទ្ធកម្ម | | | ក្របខ័ណ្ឌសវនកម្មលើសមិទ្ធកម្ម ត្រូវបានរៀបចំនិងផ្សព្វផ្សាយ បណ្តុះបណ្តាលដល់ក្រសួង-ស្ថាប័ន និង អង្គភាពពាក់ព័ន្ធ | | | | | | | | | | |
| | ៤៣.១ | | | | | | | | | | | | |
| | ៤៣.២ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ៤៣ | | ១.០០ | ១.០០ | | | | | | | | | | |
| ៤៤. រៀបចំផែនការកសាងសមត្ថភាព (ដោយរួមទាំងស្ថាប័ននីតិប្បញ្ញត្តិ និង អាជ្ញាធរសវនកម្មជាតិ) | | | ផែនការកសាងសមត្ថភាពត្រូវបានរៀបចំ អនុម័ត និង អនុវត្ត | | | | | | | | | | |
| | ៤៤.១ | | | | | | | | | | | | |
| | ៤៤.២ | | | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតគោលបំណង) (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចង្កោមសកម្មភាព | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| | ៤៤.៣ | | | | | | | | | | | | |
| លទ្ធផលគោលបំណង ៤៤ | | ១.០០ | | | | | | | | | | | |
| ៥១. បង្កើនភាពជាអ្នកដឹកនាំ សមត្ថភាពគ្រប់គ្រង និងបណ្តុះ ឆន្ទៈកំណែទម្រង់ ព្រមទាំង បង្កើនភាពជាម្ចាស់ និងការ ទទួលខុសត្រូវ | | | • ភាពជាអ្នកដឹកនាំនិង សមត្ថភាពគ្រប់គ្រង សមស្រប<br>• ឆន្ទៈភាពជាម្ចាស់ និងការទទួល ខុសត្រូវសមស្រប | | | | | | | | | | |
| | ៥១.១ | | | | | | | | | | | | |
| | ៥១.២ | | | | | | | | | | | | |
| លទ្ធផលក្នុងឆ្នាំ គោលបំណង ៥១ | | ១.០០ | | | | | | | | | | | |
| ៥២. បង្កើនប្រសិទ្ធភាព នៃការកសាងសមត្ថភាព និងវិធានការលើកទឹកចិត្ត | | | • ការបណ្តុះបណ្តា ល សមស្របនិងប្រក ប ដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព<br>• ការផ្តល់ការលើក ទឹកចិត្តសមស្រប និងប្រកបដោយ ផលិតភាព | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតគោលបំណង) (១) | លទ្ធផលក្នុងឆ្នាំ ឬត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចង្កោមសកម្មភាព | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| | | | ស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព | | | | | | | | | | |
| | ៥២.១ | | | | | | | | | | | | |
| | ៥២.២ | | | | | | | | | | | | |
| លទ្ធផលក្នុងឆ្នាំ គោលបំណង ៥២ | | ១.០០ | | | | | | | | | | | |
| ៥៣. ពង្រឹងការកសាងសមត្ថភាពសម្រាប់អនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ដំណាក់កាលទី៣ | | | គ្រប់ក្រសួង-ស្ថាប័នមានសមត្ថភាពសម ស្របសម្រាប់ចូលរួមការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព | | | | | | | | | | |
| | ៥៣.១ | | | | | | | | | | | | |
| | ៥៣.២ | | | | | | | | | | | | |
| | ៥៣.៣ | | | | | | | | | | | | |
| | ៥៣.៤ | | | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតគោលបំណង) (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ចង្កោមសកម្មភាព | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| លទ្ធផលគោលបំណង ៥៣ | | ១.០០ | | | | | | | | | | | |

# តារាងទី២÷ ការដាក់ពិន្ទុកម្រិតផ្នែក

# (៥ ផ្នែក, ២១ គោលបំណង)

| លទ្ធផលចុងក្រោយ (កម្រិតផ្នែក) (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | គោលបំណង | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| **ផ្នែកទី១. បន្តពង្រឹងភាពជឿទុកចិត្តនៃថវិកា** | | | ១.ការអនុវត្តចំណូលនិងចំណាយប្រចាំត្រីមាសមានភាពរលូននិងអាចប៉ាន់ស្មានបាន (កម្រិតលម្អៀងនៃការអនុវត្តមិនលើសពី៥% ធៀបទៅនឹងកម្មវិធីចំណូល-ចំណាយ)<br>២.ការគ្រប់គ្រងបំណុលត្រូវសង និងបំណុលត្រូវទារក្នុងឆ្នាំប្រកបដោយប្រសិទ្ធភាព | | | | | | | | | | |
| | ១១ | | | | | | | | | | | | |
| | ១២ | | | | | | | | | | | | |
| | ១៣ | | | | | | | | | | | | |
| | ១៤ | | | | | | | | | | | | |
| **លទ្ធផលផ្នែកទី ១** | | ១.០០ | | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតផ្នែក) (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | គោលបំណង | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| **ផ្នែកទី ២÷ បន្តពង្រឹងគណនេយ្យភាពហិរញ្ញវត្ថុ (២០១៨)** | | | ១.ប្រព័ន្ធ, យន្តការ, ក្របខ័ណ្ឌគតិយុត្ត ត្រូវបានដាក់ឱ្យអនុវត្តប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព ត្រឹមឆ្នាំ២០១៨ (ចំណាត់ថ្នាក់ថវិកា, ប្លង់គណនី, ការអនុវត្ត FMIS ដំណាក់កាលទី១ និង ដំណាក់កាលទី២) ២.ប្រព័ន្ធគណនេយ្យ, ប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ហិរញ្ញវត្ថុ ត្រូវបានអនុវត្តប្រកបដោយស័ក្តិសិទ្ធភាព ប្រសិទ្ធភាព តម្លាភាព សុក្រឹតភាព និង ទាន់ពេលវេលា | | | | | | | | | | |
| | ២១ | | | | | | | | | | | | |
| | ២២ | | | | | | | | | | | | |
| | ២៣ | | | | | | | | | | | | |
| | ២៤ | | | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតផ្នែក) (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | គោលបំណង | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| លទ្ធផលផ្នែកទី២ | | ១.០០ | | | | | | | | | | | |
| **ផ្នែកទី៣៖ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** | | | ១. ក្របខ័ណ្ឌថវិការយៈពេលមធ្យម (ដែលរួមមានក្របខ័ណ្ឌចំណូលរយៈពេលមធ្យម, ក្របខ័ណ្ឌចំណាយរយៈពេលមធ្យម និងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម) ត្រូវបានរៀបចំនិងអនុវត្តប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព និងត្រូវអនុម័តដោយគណៈរដ្ឋមន្ត្រី<br>២. ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំ និងអនុវត្តប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព<br>៣. ថវិកាកម្មវិធីនិងអង្គភាពថវិកា ត្រូវបានអនុវត្តនៅគ្រប់ក្រសួង-ស្ថាប័នថ្នាក់ជាតិ និង | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតផ្នែក) (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | គោលបំណង | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| | | | ថ្នាក់ក្រោមជាតិប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព | | | | | | | | | | |
| | ៣១ | | | | | | | | | | | | |
| | ៣២ | | | | | | | | | | | | |
| | ៣៣ | | | | | | | | | | | | |
| | ៣៤ | | | | | | | | | | | | |
| | ៣៥ | | | | | | | | | | | | |
| | ៣៦ | | | | | | | | | | | | |
| លទ្ធផលផ្នែកទី ៣ | | ១.០០ | | | | | | | | | | | |
| **ផ្នែកទី ៤÷ ការត្រៀមខ្លួនសម្រាប់ជំហានបន្ទាប់** | | | ក្របខ័ណ្ឌថវិកា, ក្របខ័ណ្ឌគណនេយ្យភាព និងក្របខ័ណ្ឌសវនកម្ម ដោយផ្អែកលើសមិទ្ធកម្មត្រូវបានរៀបចំ | | | | | | | | | | |
| | ៤១ | | | | | | | | | | | | |
| | ៤២ | | | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតផ្នែក) (១) | លទ្ធផលក្នុងឆ្នាំ ឬ ត្រីមាស/ទម្ងន់ (២) | | សូចនាករគន្លឹះ (៣) | | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | សរុបលទ្ធផលសម្រេចបាន (៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | គោលបំណង | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| | ៤៣ | | | | | | | | | | | | |
| | ៤៤ | | | | | | | | | | | | |
| លទ្ធផល ផ្នែកទី ៤ | | ១.០០ | | | | | | | | | | | |
| ផ្នែកទី៥÷ ការគាំទ្រដល់ការអនុវត្តកម្មវិធីកែទម្រង់ ប្រកបដោយជោគជ័យ និងចីរភាព | | | ភាពជាអ្នកដឹកនាំ, សមត្ថ-ភាពគ្រប់គ្រង, សមត្ថភាពបច្ចេកទេស, ភាពជាម្ចាស់, ការទទួលខុសត្រូវ មានសមានគតិភាពជាមួយនឹងការគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់-គ្រងហិរញ្ញវត្ថុសាធារណៈ | | | | | | | | | | |
| | ៥១ | | | | | | | | | | | | |
| | ៥២ | | | | | | | | | | | | |
| | ៥៣ | | | | | | | | | | | | |
| លទ្ធផល ផ្នែកទី ៥ | | ១.០០ | | | | | | | | | | | |

# តារាងទី៣÷ ការដាក់ពិន្ទុកម្រិតកម្មវិធី

## (ពិន្ទុ ៥ ផ្នែក)

| លទ្ធផលចុងក្រោយ (កម្រិតកម្មវិធី) (១) | លទ្ធផលក្នុងឆ្នាំឬត្រីមាស/ទម្ងន់(២) | សូចនាករគន្លឹះ (៣) | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | | | សរុបលទ្ធផលសម្រេចបាន(៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ផ្នែក | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| | ផ្នែកទី ១ | | ១. ការអនុវត្តចំណូល និងចំណាយប្រចាំត្រីមាសមានភាពរលូន និងអាចប៉ាន់ស្មានបាន (កម្រិតលម្អៀងនៃការអនុវត្ត មិនលើសពី៥% ធៀបទៅនឹងកម្មវិធីចំណូល-ចំណាយ)<br>២. ការគ្រប់គ្រងបំណុលត្រូវសង និងបំណុលត្រូវទារក្នុងឆ្នាំប្រកបដោយប្រសិទ្ធភាព | | | | | | | | | | |
| សរុបផ្នែកទី១ | | | | | | | | | | | | | |
| | ផ្នែកទី ២ | | ១. ប្រព័ន្ធ, យន្តការ, ក្របខ័ណ្ឌគតិយុត្ត ត្រូវបានដាក់ឱ្យអនុវត្ត | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្មវិធី) (១) | លទ្ធផលក្នុងឆ្នាំឬត្រីមាស/ទម្ងន់(២) | សូចនាករគន្លឹះ (៣) | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | | | សរុបលទ្ធផលសម្រេចបាន(៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ផ្នែក | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| | | | ប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាពត្រឹមឆ្នាំ ២០១៨(ចំណាត់ថ្នាក់ថវិកា, ប្លង់គណនី, ការអនុវត្ត FMIS ដំណាក់កាលទី១ និង ដំណាក់កាលទី២)<br>២. ប្រព័ន្ធគណនេយ្យនិងប្រព័ន្ធកត់ត្រា និងប្រព័ន្ធរបាយការណ៍ហិរញ្ញវត្ថុប្រកបដោយស័ក្តសិទ្ធភាព ប្រសិទ្ធភាព តម្លាភាព សុក្រឹតភាព និងទាន់ពេលវេលា | | | | | | | | | | |
| សរុបផ្នែកទី២ | | | | | | | | | | | | | |
| | ផ្នែកទី ៣ | | ១. ក្របខ័ណ្ឌថវិការយៈពេលមធ្យម (ដែលរួមមានក្របខ័ណ្ឌចំណូល រយៈពេលមធ្យម, ក្របខ័ណ្ឌចំណាយរយៈពេល | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតកម្មវិធី) (១) | លទ្ធផលក្នុងឆ្នាំឬត្រីមាស/ទម្ងន់(២) | សូចនាករគន្លឹះ (៣) | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | | | សរុបលទ្ធផលសម្រេចបាន(៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ផ្នែក | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| | | | មធ្យម និងក្របខ័ណ្ឌគោលនយោបាយហិរញ្ញវត្ថុសាធារណៈរយៈពេលមធ្យម) ត្រូវបានរៀបចំនិងអនុវត្តប្រកបដោយស័ក្តិសិទ្ធភាព និងប្រសិទ្ធភាព និងត្រូវអនុម័តដោយគណៈរដ្ឋមន្ត្រី<br>២.ផែនការយុទ្ធសាស្ត្រថវិកាត្រូវបានរៀបចំនិងអនុវត្តប្រកបដោយស័ក្តិសិទ្ធភាពនិងប្រសិទ្ធភាព<br>៣.ថវិកាកម្មវិធីនិងអង្គភាពថវិកាត្រូវបានអនុវត្តគ្រប់ក្រសួងស្ថាប័នថ្នាក់ជាតិ និងថ្នាក់ក្រោមជាតិប្រកបដោយស័ក្តិសិទ្ធភាពនិង | | | | | | | | | | |

| លទ្ធផលចុងក្រោយ (កម្រិតកម្មវិធី) (១) | លទ្ធផលក្នុងឆ្នាំឬត្រីមាស/ទម្ងន់(២) | សូចនាករគន្លឹះ (៣) | | ការវាយតម្លៃលើគោលដៅសម្រេចបាន (៤) | | | | | | | សរុបលទ្ធផលសម្រេចបាន(៥) | | |
|---|---|---|---|---|---|---|---|---|---|---|---|---|---|
| | ផ្នែក | ទម្ងន់ | សូចនាករគន្លឹះ | ឯកតា | ទម្ងន់ | ល្អណាស់ ១០០% | ល្អ ៩០% | ល្អបង្គួរ ៨០% | មធ្យម ៧០% | ខ្សោយ ៦០% | លទ្ធផលសម្រេចបាន | ពិន្ទុផ្ទាល់ | ពិន្ទុសម្រួល |
| | | | ប្រសិទ្ធភាព | | | | | | | | | | |
| | ផ្នែកទី ៤ | | ១.ក្របខ័ណ្ឌថវិកា, ក្របខ័ណ្ឌគណនេយ្យភាព និងក្របខ័ណ្ឌសវនកម្ម ដោយផ្អែកលើសមិទ្ធកម្មត្រូវបានរៀបចំ | | | | | | | | | | |
| | ផ្នែកទី៥ | | ១.ភាពជាអ្នកដឹកនាំ, សមត្ថភាពគ្រប់គ្រង, សមត្ថភាពបច្ចេកទេស, ភាពជាម្ចាស់, ការទទួលខុសត្រូវ មានសមានគតិភាព ជាមួយនឹងការគាំទ្រការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | | | | | | | | | | |
| **លទ្ធផលកម្មវិធីកែទម្រង់** | ១.០០ | | | | | | | | | | | | |

# ឧបសម្ព័ន្ធ ១២.
# អនុសាសន៍កែលម្អកង្វះចន្លោះនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (PEFA)

| សូចនាករសមិទ្ធកម្ម | | អនុសាសន៍ |
|---|---|---|
| **១. លទ្ធផលនៃការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ ៖ ភាពជឿទុកចិត្តនៃថវិកា** | | |
| PI-1 | ចំណាយសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | គួរមានគោលការណ៍ណែនាំជាក់លាក់សម្រាប់ការរៀបចំចំណាយថវិកាមូលធននិងការងារពាក់ព័ន្ធរបស់ក្រសួងផែនការ (MoP), ក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា (CDC) និងក្រសួង-ស្ថាប័នដទៃទៀត។ លើសពីនេះ ការធ្វើសមាហរណកម្មថវិការវាងចំណាយមូលធន និង ចំណាយចរន្ត គឺមានសារៈសំខាន់ណាស់ដែលអាចអនុញ្ញាតឱ្យក្រសួងស្ថាប័នកំណត់នូវសូចនាករកំណត់ជោគជ័យចម្បងៗសម្រាប់គោលបំណងគោលនយោបាយនិងកម្មវិធី។ សមាហរណកម្មថវិកា ត្រូវការយកចិត្តទុកដាក់បន្ថែមទៀតតាមរយៈការរៀបចំនិងអនុវត្តសកម្មភាពគាំទ្រ។ |
| PI-2 | សមាសធាតុចំណាយធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | ការផ្សារភ្ជាប់គ្នាយ៉ាងជិតស្និទ្ធរវាងគោលនយោបាយនិងថវិកាគឺជាចំណុចដ៏សំខាន់ដើម្បីមានលទ្ធផលល្អនៃការអនុវត្តថវិកា។ ការផ្សារភ្ជាប់នេះទាមទារឱ្យមានការបង្កើតក្របខ័ណ្ឌចំណាយរយៈពេលមធ្យម (MTEF) និងកែលម្អនូវការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ។ ការរៀបចំផែនការសកម្មភាពជាក់លាក់ ទាមទារជាដំបូងនូវការវិភាគពីកម្រិតខ្ពស់នៃភាពខុសគ្នារបស់ PI-2 សមាសធាតុ ១, ថាតើវាបណ្ដាលមកពីការរៀបចំផែនការមិនបានល្អ (និងចលនាឥណទានញឹកញាប់) ឬ ការអនុវត្តមិនអនុលោមតាមគោលការណ៍ណែនាំ។ លើសពីនេះ, ដើម្បីកាត់បន្ថយថវិកាមិនបានគ្រោងទុកគឺត្រូវធ្វើការវិភាជថវិកាសម្រាប់កម្មវិធីអាទិភាពនិងជាក់លាក់ដែលធ្វើឱ្យការរៀបចំកាន់តែមានភាពគ្រប់ជ្រុងជ្រោយ។ ចំណាយមិនបានគ្រោងទុកដែលមានកម្រិត ៥,៣% បញ្ជាក់ឱ្យឃើញពីតម្រូវការក្នុងការផ្លាស់ប្ដូរប្រព្រឹត្តកម្មគណនេយ្យ (accounting treatment) និងផ្ដល់ចំណាយជាក់ស្ដែងទៅឱ្យក្រសួង-ស្ថាប័ន។ |

| សូចនាករសមិទ្ធកម្ម | | អនុសាសន៍ |
|---|---|---|
| PI-3 | ចំណូលសរុបធៀបនឹងច្បាប់ថវិកាដែលបានអនុម័ត | រដ្ឋាភិបាល អាចបង្កើតនូវលំហរថវិកា ដោយពង្រឹងការប្រមូលចំណូលក្នុងស្រុកទាំងចំណូលសារពើពន្ធនិងចំណូលមិនមែនសារពើពន្ធ, ដោយធានាឱ្យបាននូវហិរញ្ញប្បទានបន្ថែមខាងក្រៅ, ដោយកាត់បន្ថយចំណាយដែលមិនចាំបាច់ ឬដោយកំចីក្នុងស្រុកឬក្រៅស្រុក។ អាទិភាពដំបូងរបស់រដ្ឋាភិបាលក្នុងការបង្កើតលំហរថវិកា គឺត្រូវកាត់បន្ថយឱនភាពថវិកា និងបង្កើនទុនបំរុងរដ្ឋាភិបាល។ គួរពង្រឹងការព្យាករណ៍ចំណូល ឬបង្កើតវិធីសាស្រ្តក្នុងការព្យាករណ៍ចំណូល ដែលជាទូទៅច្បាប់ថវិកាមិនកម្រិតទាបខ្លាំង ធៀបនឹងការប្រមូលចំណូលថ្នាក់រាជធានី-ខេត្ត។ អនុសាសន៍ដូចគ្នាសម្រាប់ការប្រមូលចំណូលមិនមែនសារពើពន្ធ ដែលមានកម្រិត ២៧% ទាបជាងច្បាប់ថវិកាសរុបក្នុងរយៈពេល ៣ឆ្នាំចុងក្រោយ។ |

| សូចនាករសមិទ្ធកម្ម | | អនុសាសន៍ |
|---|---|---|
| PI-4 | សន្និធិបំណុលកកស្ទះ និងការត្រួតពិនិត្យតាមដានបំណុលកកស្ទះ | ដើម្បីត្រួតពិនិត្យតាមដានបំណុលកកស្ទះ, អគ្គនាយកដ្ឋានរតនាគារជាតិ គួរបង្កើតនូវរបាយការណ៍ដើម្បីគ្រប់គ្រងសន្និធិបំណុលកកស្ទះជាប្រចាំត្រីមាស និងប្រចាំឆ្នាំ។ របាយការណ៍នេះនឹងជួយថ្នាក់ដឹកនាំ ឱ្យអាចដឹងអំពីភាពរលូននៃលំហូរសាច់ប្រាក់ និងហេតុផលផ្សេងៗពីអង្គភាពពាក់ព័ន្ធ តាមរយៈសកម្មភាពចំនួន ២ ខាងក្រោម÷<br>(១) ការតាមដានភ្លាមៗនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈតាមរយៈប្រព័ន្ធព័ត៌មានវិទ្យា (FMIS) និងម៉ូឌុលគណនីត្រូវបង់/គណនីបំណុល (accounts payable module) និង<br>(២) ដំណោះស្រាយបណ្ដោះអាសន្នតាមរយៈការទាញយកនូវព័ត៌មាន KIT ចូលទៅក្នុងប្រព័ន្ធ Excel។ ក្នុងន័យនេះ ការត្រួតពិនិត្យតាមដាន អាចត្រូវបានពង្រឹងតាមរយៈការដាក់ប្រាក់បៀវត្សនិងបំណុលកកស្ទះ ទៅក្នុងការត្រួតពិនិត្យតាមដាន÷<br>-ពង្រីកវិសាលភាពនៃការត្រួតពិនិត្យតាមដាន ដោយគិតគូររាប់រយៈពេលចាប់ពីថ្ងៃប្រគល់វិក្កយបត្រទូទាត់ដោយអ្នកផ្គត់ផ្គង់<br>-សម្របរយៈពេលពន្យារដែលត្រូវបានត្រួតពិនិត្យតាមដានជាមួយរយៈពេលពន្យារនៃការទូទាត់ដែលមានចែងនៅក្នុងឯកសារកិច្ចលទ្ធកម្ម និងកិច្ចសន្យា។ |

| សូចនាករសមិទ្ធកម្ម | | អនុសាសន៍ |
|---|---|---|
| ២. ការទទួលស្គាល់ខ្សឹមបរិច្ឆេទ ៖ ភាពគ្រប់ជ្រុងជ្រោយនិងតម្លាភាពនៃថវិកា | | |
| PI-5 | ចំណាត់ថ្នាក់ថវិកា | គ្រប់អគ្គនាយកដ្ឋានពាក់ព័ន្ធ ជាពិសេសអគ្គនាយកដ្ឋានរតនាគារជាតិ និងអគ្គនាយកដ្ឋានថវិកា គួរពង្រឹងនិងពង្រីកការអនុវត្តចំណាត់ថ្នាក់រដ្ឋបាល សេដ្ឋកិច្ច និងមុខងារ ដែលអនុលោមតាមស្តង់ដារអន្តរជាតិ (រួមបញ្ចូល GFS និង COFOG)។ លើសពីនេះ អគ្គនាយកដ្ឋានពាក់ព័ន្ធខាងលើគួរត្រួតពិនិត្យតាមដាននិងវាយតម្លៃលើការអនុវត្ត និងបន្ថែមនូវសមាសធាតុក្នុងប្លង់គណនី ដើម្បីសម្រួលដល់ការរៀបចំ GFS និង COFOG សំដៅលើកកម្ពស់សមានគតិភាពនិងភាពគ្រប់ជ្រុងជ្រោយនៃថវិកា ដូចជា (១) បង្ហាញភាពច្បាស់លាស់និងភាពគ្រប់ជ្រុងជ្រោយនៃការកត់ត្រានិងការរាយការណ៍នៃប្រតិបត្តិការហិរញ្ញវត្ថុ, (២) ពង្រឹងសុក្រឹតភាពក្នុងការវិភាគ និងការប្រៀបធៀបការព្យាករណ៍, (៣) ពង្រឹងការរៀបចំថវិកា, ការត្រួតពិនិត្យតាមដាន និងការគ្រប់គ្រង និង (៤) លើកកម្ពស់តម្លាភាពនិងគណនេយ្យភាពនៃប្រព័ន្ធគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈជារួម។ ផ្អែកលើភាពខុសគ្នានៃប្រតិបត្តិការការងារនិងប្រព័ន្ធ, យើងជឿថាការអនុវត្តនូវចំណាត់ថ្នាក់ទាំង៣ខាងលើ នឹងបង្កើនពិន្ទុខ្ពស់ជាងមុន។ ការកែទម្រង់គន្លឹះ គឺការណែនាំការអនុវត្តថវិកាកម្មវិធីដែលនឹងអាចឱ្យការអនុវត្តចំណាយតាមចំណាត់ថ្នាក់អនុមុខងារពេញលេញ ដែលរួមមាន (១) ដាក់ឱ្យដំណើរការពេញលេញការអនុវត្តថវិកាកម្មវិធីនៅគ្រប់ក្រសួង-ស្ថាប័ន និង(២) រាប់បញ្ចូលចំណាយបៀវត្ស។ |

| សូចនាករសមិទ្ធកម្ម | | អនុសាសន៍ |
|---|---|---|
| PI-6 | ភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មានដែលត្រូវបានបញ្ចូលនៅក្នុងឯកសារថវិកា | ដើម្បីសម្រេចបានភាពគ្រប់ជ្រុងជ្រោយនៃព័ត៌មាន ដែលត្រូវបញ្ចូលនៅក្នុងឯកសារថវិកាការបំពេញបាននូវលក្ខខណ្ឌនៃឯកសារព័ត៌មានដែលត្រូវការ ទាំង៩ ក្នុងសូចនាករនេះ គឺកត្តាគន្លឹះកំណត់ជោគជ័យ។ គួរផ្តល់អាទិភាពលើការលើកកម្ពស់សមត្ថភាពក្នុងការប្រមូលផ្តុំនូវឯកសារមួយចំនួនដូចតទៅ (១)លទ្ធផលរំពឹងទុកសម្រាប់ឆ្នាំកំពុងអនុវត្ត និងលទ្ធផលក្នុងឆ្នាំចាស់, (២)ឱនភាពហិរញ្ញវត្ថុ (៣) សន្និធិបំណុលកកស្ទះ ដែលរួមបញ្ចូលយ៉ាងហោចណាស់ សមតុល្យដើមគ្រាក្នុងឆ្នាំអនុវត្ត និង (៤) ទ្រព្យសកម្មហិរញ្ញវត្ថុដែលរួមបញ្ចូលយ៉ាងហោចណាស់ សមតុល្យដើមគ្រាក្នុងឆ្នាំអនុវត្ត។ |
| PI-7 | ទំហំនៃប្រតិបត្តិការរបស់រដ្ឋាភិបាលដែលមិនត្រូវបានរាយការណ៍ | អង្គភាពពាក់ព័ន្ធ គួរត្រួតពិនិត្យនិងរៀបចំឡើងវិញនូវប្រព័ន្ធយន្តការ និងនីតិវិធីសម្រាប់ការកត់ត្រានិងការរាយការណ៍ប្រតិបត្តិការថវិកាបន្ថែមរបស់រដ្ឋ ដែលមិនត្រូវបានកត់ត្រា ឬមិនបានបញ្ចូលក្នុងថវិកាប្រចាំឆ្នាំ។ ការមិនបានរាយការណ៍អំពីចំណូល-ចំណាយរបស់ក្រសួង-ស្ថាប័ន ត្រូវតែជាកម្មវត្ថុនៃការត្រួតពិនិត្យជារួមមួយ និងការវិភាគគោលនយោបាយក្នុងកម្រិតថ្នាក់ដឹកនាំ បន្ទាប់មក ត្រូវរៀបចំសកម្មភាពកែទម្រង់លម្អិតសម្រាប់ការគ្រប់គ្រងនិងការប្រមូលចំណូលមិនមែនសារពើពន្ធ។ ក្រសួង-ស្ថាប័នដែលទទួលខុសត្រូវត្រូវបន្តប្រមូលនិងរក្សាកត់ត្រាចំណូល ប៉ុន្តែត្រូវពង្រឹងព័ត៌មាននៃថវិកា ទាំងលើផែនការនិងការប្រមូលជាក់ស្តែង ព្រមទាំងពង្រឹងការធ្វើសវនកម្ម។ |

| សូចនាករសមិទ្ធកម្ម | | អនុសាសន៍ |
|---|---|---|
| PI-8 | តម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់នៃរដ្ឋបាល (ថ្នាក់ជាតិនិងក្រោមជាតិ) | បើទោះជាតម្លាភាពនៃទំនាក់ទំនងហិរញ្ញវត្ថុនៅគ្រប់ថ្នាក់នៃរដ្ឋបាល មានភាពល្អប្រសើរ ក៏ប៉ុន្តែមានការងារមួយចំនួនទាមទារឱ្យមានការកែលម្អនិងពង្រឹងបន្ថែមទៀត ដូចជាវិធីសាស្ត្រផ្ទេរមូលនិធិ ឬការវិភាជន៍ថវិកាទៅរដ្ឋបាលថ្នាក់-ក្រោមជាតិ, សមត្ថភាពក្នុងការរៀបចំរបាយការណ៍ចំណូលចំណាយ។ ទន្ទឹមនេះ គួរធ្វើការត្រួតពិនិត្យឡើងវិញលើប្រព័ន្ធនិងក្របខ័ណ្ឌច្បាប់ជាធរមាន ជាពិសេសដើម្បីពង្រឹងសមត្ថភាពរដ្ឋបាលថ្នាក់ក្រោមជាតិ លើការព្យាករណ៍ថវិកានិងកម្រិតនៃការរៀបចំរបាយការណ៍។ សុខដុមនីយកម្មនៃប្លង់គណនីរបស់រដ្ឋាភិបាល គួរត្រូវបានគិតគូរចាត់ជាការងារអាទិភាពនៃការកែទម្រង់។ ការបង្កើនសមត្ថភាពនៅរដ្ឋបាលថ្នាក់ក្រោមជាតិ គួរត្រូវពិចារណាផងដែរ។ |
| PI-9 | ការត្រួតពិនិត្យហានិភ័យថវិកាពីអង្គភាពសាធារណៈដទៃទៀតក្រៅពីក្រសួង- ស្ថាប័នរដ្ឋ | អគ្គនាយកដ្ឋានទ្រព្យសម្បត្តិរដ្ឋនិងចំណូលមិនមែនសារពើពន្ធនិងអគ្គនាយកដ្ឋានហិរញ្ញវត្ថុរដ្ឋបាលថ្នាក់ក្រោមជាតិ គួរពិនិត្យលើការងាររៀបចំយន្តការ នីតិវិធី ឬ យុទ្ធសាស្ត្រដើម្បីត្រួតពិនិត្យតាមដាននិងគ្រប់គ្រងហានិភ័យថវិកា ជាពិសេសពាក់ព័ន្ធនឹងការព្យាករណ៍និងការរៀបចំចំណូលចំណាយរបស់អង្គភាពសាធារណៈ ដែលស្ថិតក្នុងវិសាលភាពនៃការវាយតម្លៃសូចនាករនេះ ដើម្បីជៀសវាងនូវបញ្ហាប្រឈមជាអវិជ្ជមាននិងដែលអាចប៉ះពាល់ដល់កិច្ចដំណើរការនៅថ្នាក់កណ្តាល។ ក្នុងន័យនេះ មានសេចក្តីត្រូវការចាំបាច់ក្នុងការពង្រឹងសមត្ថភាពគ្រប់គ្រងហានិភ័យថវិកានៅក្នុងអគ្គនាយកដ្ឋានទាំងពីរ។ |

| សូចនាករសមិទ្ធកម្ម | | អនុសាសន៍ |
|---|---|---|
| PI-10 | លទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានថវិកាសំខាន់ៗ | យោងតាមការអង្កេត, អង្គភាពពាក់ព័ន្ធគួរត្រួតពិនិត្យតាមដានឡើងវិញនិងបន្តប្រឹងប្រែងសំដៅបោះផ្សាយឯកសារថវិកាចំនួន ០៣ ដែលរួមមាន (១) របាយការណ៍សវនកម្មពីខាងក្រៅ, (២) ការផ្តល់កិច្ចសន្យា÷ ការផ្តល់កិច្ចសន្យាទាំងអស់ ដែលមានតម្លៃចាប់ពីប្រមាណ ១០០.០០០ដុល្លារ សមមូល ឡើងទៅ និង (៣) ធនធានដែលមានសម្រាប់អង្គភាពផ្តល់សេវាអាទិភាព/ បឋម (PSUs)÷ យ៉ាងហោចណាស់ អង្គភាពផ្តល់សេវាអាទិភាព/ បឋម ដែលមានទូទាំងប្រទេស ចំនួន ២ វិស័យ (ដូចជាសាលាបឋមសិក្សា ឬមណ្ឌលសុខភាពមូលដ្ឋាន)។ គួរពិនិត្យនិងកែសម្រួលបទដ្ឋានគតិយុត្តពាក់ព័ន្ធ ឬអង្គភាពទទួលបន្ទុកពាក់ព័ន្ធ។ |
| **៣. វដ្តថវិកា** | | |
| **៣.១ ការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** | | |
| PI-11 | កាលានុក្រមនិងការចូលរួមក្នុងកិច្ចដំណើរការរៀបចំថវិកាប្រចាំឆ្នាំ | សូចនាករសមិទ្ធកម្មនេះបានទទួលពិន្ទុខ្ពស់ ដោយសារដំណើរការរៀបចំថវិកាមានភាពច្បាស់លាស់។ ទោះយ៉ាងណាអង្គភាពពាក់ព័ន្ធត្រូវបន្តពង្រឹងនិងត្រៀមខ្លួនសម្រាប់ការផ្លាស់ប្តូរប្រព័ន្ធថវិកាថ្មី នាពេលអនាគត (ឆ្នាំ២០២០)។ |

| សូចនាករសមិទ្ធកម្ម | | អនុសាសន៍ |
|---|---|---|
| PI-12 | ទស្សនៈវិស័យច្រើនឆ្នាំក្នុងការធ្វើផែនការថវិកា, គោលនយោបាយចំណាយ និងការរៀបចំថវិកា | ការរៀបចំថវិកានិងការអនុវត្តថវិកា មានសមិទ្ធកម្មល្អតាមរយៈការដាក់ឱ្យអនុវត្តផែនការយុទ្ធសាស្ត្រថវិកា, ថវិកាកម្មវិធី និងក្របខ័ណ្ឌចំណាយរយៈមធ្យម ទោះបីជាសមត្ថភាពរបស់ក្រសួង-ស្ថាប័ននៅមានកម្រិតនៅឡើយជាក់ស្តែង ការរៀបចំក្នុងទម្រង់ដាច់ដោយឡែកពីគ្នា នូវថវិកាចរន្តនិងថវិកាមូលធន។ សមាហរណកម្មថវិកាចរន្ត និងថវិកាមូលធន ឱ្យស្ថិតក្រោមពិដានថវិការួមមួយ គួរត្រូវគិតគូរក្នុងក្របខ័ណ្ឌនៃការរៀបចំផែនការសកម្មភាពរយៈពេលមធ្យម។ សកម្មភាពមួយ នឹងត្រូវរៀបចំដើម្បីដាក់ឱ្យអនុវត្តប្លង់គណនី ដែលសមាហរណកម្មចំណាយមូលធននិងចំណាយចរន្ត។ |
| ៣.២ ភាពអាចប៉ាន់ប្រមាណបាន និងការត្រួតពិនិត្យការអនុវត្តថវិកា | | |
| PI-13 | តម្លាភាពនៃកាតព្វកិច្ចជាប់ពន្ធ និងបំណុលពន្ធរបស់អ្នកជាប់ពន្ធ | ដើម្បីមានយន្តការដែលអាចជឿទុកចិត្តបាន សម្រាប់ការដោះស្រាយបណ្តឹងពាក់ព័ន្ធនឹងពន្ធដារ និងដើម្បីធានាយុត្តិធម៌ជូនអ្នកបង់ពន្ធ, អគ្គនាយកដ្ឋានពន្ធដារ គួរពន្លឿនការបង្កើតគណៈកម្មាធិការសំរុះសំរួលសារពើពន្ធ ដែលកំពុងត្រូវបានរៀបចំ។ យន្តការដោះស្រាយបណ្តឹងនេះ គួរត្រូវអនុវត្តពេញលេញ នៅពេលដែលគណៈកម្មការនេះត្រូវបានបង្កើតឡើង។ |
| PI-14 | ប្រសិទ្ធភាពនៃវិធានការសម្រាប់ចុះបញ្ជីអ្នកជាប់ពន្ធ និងការវាយតម្លៃពន្ធ | ដើម្បីពង្រឹងការចុះបញ្ជីបង់ពន្ធ និងការប្រកាសពន្ធឱ្យបានត្រឹមត្រូវ, អគ្គនាយកដ្ឋានពន្ធដារ គួរមានវិធានការតឹងរ៉ឹងចំពោះសហគ្រាសដែលមិនទាន់បានចុះបញ្ជីបង់ពន្ធ។ ទន្ទឹមនេះ ទណ្ឌកម្មលើសហគ្រាសដែលមិនបានបំពេញកាតព្វកិច្ចចុះបញ្ជី និងបង់ពន្ធ គួរត្រូវពង្រឹង និងអនុវត្តឱ្យខ្ជាប់ខ្ជួន និងប្រកបដោយយុត្តិធម៌ចំពោះគ្រប់អ្នកបង់ពន្ធ។ មានតម្រូវការព័ត៌មានលម្អិតបន្ថែម និងការកំណត់ការទទួលខុសត្រូវ។ |

| សូចនាករសមិទ្ធកម្ម | | អនុសាសន៍ |
|---|---|---|
| PI-15 | ប្រសិទ្ធភាពនៃការប្រមូលពន្ធ | គួរមានវិធានការតឹងរ៉ឹង និងដំណោះស្រាយជាបន្ទាន់ចំពោះអ្នកដែលខកខានមិនបានបង់ពន្ធរ៉ុំរ៉ៃ និងពង្រឹងការទារបំណុលពន្ធដែលហួសឱសានវាទ ដើម្បីធានាភាពជឿទុកចិត្តនៃថវិកា។ មានតម្រូវការព័ត៌មានលម្អិតបន្ថែម និងការកំណត់ការទទួលខុសត្រូវ។ |
| PI-16 | ភាពអាចប៉ាន់ប្រមាណបាននូវអត្ថិភាពថវិកាសម្រាប់ធានាចំណាយ | ១. ទោះបីការព្យាករណ៍ និងការតាមដានលំហូរសាច់ប្រាក់ទទួលបានពិន្ទុ “B” ក៏ដោយ, ការរៀបចំរបាយការណ៍ស្តីពីផែនការសាច់ប្រាក់ នៅមិនទាន់មានភាពគ្រប់ជ្រុងជ្រោយនៅឡើយ។ របាយការណ៍ស្តីពីផែនការសាច់ប្រាក់ គួរបញ្ចូលស្ថានភាពសាច់ប្រាក់ ឧទាហរណ៍ ការប្រើប្រាស់អតិរេកសាច់ប្រាក់ ឬ យន្តការបំពេញបន្ថែមសាច់ប្រាក់នៅពេលមានឱនភាព។ ទន្ទឹមនេះ គួររៀបចំផែនការសាច់ប្រាក់ប្រចាំខែដែលមានបញ្ចូលការវិភាគលំហូរសាច់ប្រាក់ ជាក់ស្តែង ធៀបនឹងការព្យាករណ៍។<br>២. គួរកែសម្រួលជំពូក ០៩ នៃថវិកា ដើម្បីអនុញ្ញាតឱ្យធ្វើចលនាឥណទានបានត្រឹមត្រូវ។ |
| PI-17 | ការកត់ត្រានិងការគ្រប់គ្រងសមតុល្យសាច់ប្រាក់, បំណុល និងការធានា | គួរធ្វើការផ្ទៀងផ្ទាត់សមតុល្យជាមួយម្ចាស់បំណុល។ |

| សូចនាករសមិទ្ធកម្ម | | អនុសាសន៍ |
|---|---|---|
| PI-18 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យបញ្ជីប្រាក់បៀវត្ស | ការភ្ជាប់ប្រព័ន្ធទិន្នន័យបុគ្គលិកនៃក្រសួង-ស្ថាប័ន ទៅនឹងប្រព័ន្ធព័ត៌មានវិទ្យាគ្រប់គ្រងធនធានមនុស្ស នៃក្រសួងមុខងារសាធារណៈ គឺជាការងារអាទិភាព។ ចំពោះការធ្វើបច្ចុប្បន្នភាពព័ត៌មាន និងបៀវត្សមន្ត្រី, នាយកដ្ឋានបុគ្គលិកនៃក្រសួង-ស្ថាប័ន គួរពិនិត្យឡើងវិញ និងកែសម្រួលនីតិវិធីស្មុគស្មាញនានា ដែលទាមទារឱ្យមន្ត្រីរាជការ ត្រូវមកបង្ហាញខ្លួន បំពេញបែបបទនិងរាយការណ៍ពីការផ្លាស់ប្តូរនៃស្ថានភាពផ្ទាល់ខ្លួន សម្រាប់ព័ត៌មានណាដែលមាននៅក្នុងនាយកដ្ឋានបុគ្គលិករួចហើយ។ ក្រៅពីនេះ ក្រសួងមុខងារសាធារណៈ គួររំលឹកក្រសួង-ស្ថាប័ន ឱ្យធ្វើតារាងបម្រែបម្រួលមន្ត្រីរាជការប្រចាំខែទាន់ពេលវេលា និងគួរមានយន្តការអចិន្ត្រៃយ៍សម្រាប់តាមដានការប្រែប្រួលនេះ ដើម្បីជៀសវាងការកែតម្រូវចំណាយបន្ទុកបុគ្គលិក ដែលមានទំហំធំ និងមិនអាចគ្រប់គ្រងបាន។ |
| PI-19 | តម្លាភាព ការប្រកួតប្រជែង និងយន្តការដោះស្រាយបណ្តឹងតវ៉ាក្នុងកិច្ចលទ្ធកម្ម | ការកែទម្រង់លទ្ធកម្មសាធារណៈគឺជាការងារអាទិភាពខ្ពស់ ដោយហេតុថាកិច្ចលទ្ធកម្មសាធារណៈ ជះឥទ្ធិពលយ៉ាងខ្លាំងលើប្រសិទ្ធភាពនិងស័ក្តិសិទ្ធភាពនៃសេវាសាធារណៈ។ អគ្គនាយកដ្ឋានលទ្ធកម្មសាធារណៈ គួរកែលម្អលទ្ធភាពរបស់សាធារណជនក្នុងការទទួលបានព័ត៌មានអំពីកិច្ចលទ្ធកម្មភាពជឿទុកចិត្តបាននិងភាពទាន់ពេលវេលានៃការបោះផ្សាយផែនការលទ្ធកម្ម, ការផ្តល់កិច្ចសន្យា, និងការដោះស្រាយវិវាទក្នុងកិច្ចលទ្ធកម្ម និងគួរបង្កើតប្រព័ន្ធឯករាជ្យមួយ ដើម្បីដោះស្រាយវិវាទក្នុងកិច្ចលទ្ធកម្ម។ |

| សូចនាករសមិទ្ធកម្ម | | អនុសាសន៍ |
|---|---|---|
| PI-20 | ប្រសិទ្ធភាពនៃការត្រួតពិនិត្យផ្ទៃក្នុងទៅលើចំណាយមិនមែនបៀវត្ស | ការដាក់ឱ្យអនុវត្តប្រព័ន្ធ FMIS នឹងផ្តល់នូវទិន្នន័យដែលត្រឹមត្រូវ និងមានបច្ចុប្បន្នភាពលើការធានាចំណាយ។ ប្រព័ន្ធទូទាត់ គួរត្រូវបានកែសម្រួលឱ្យសាមញ្ញ ដោយកាត់បន្ថយដំណាក់កាលដែលត្រូវឆ្លងកាត់ និងពន្លឿនការទូទាត់វិក្កយបត្រ។ |
| PI-21 | ប្រសិទ្ធភាពនៃសវនកម្មផ្ទៃក្នុង | ដើម្បីបង្កើនសមត្ថភាពនៃសវនកម្មផ្ទៃក្នុង ក្នុងបរិបទនៃការអនុវត្តថវិកាកម្មវិធី គួរតែ÷ (១) ផ្តោតដំបូងលើប្រព័ន្ធត្រួតពិនិត្យផ្ទៃក្នុងនៃអង្គភាព, (២) សវនកម្មផ្ទៃក្នុងផ្តោតលើលទ្ធផល ប្រសិទ្ធភាព និងស័ក្តិសិទ្ធភាពនៃការអនុវត្តថវិកា, (៣) អគ្គនាយកដ្ឋានសវនកម្មផ្ទៃក្នុងនិងអគ្គាធិការដ្ឋានមានមុខងារជាន់គ្នា ដែលគួរបញ្ចូលគ្នា, (៤) បង្កើតគណៈកម្មការសវនកម្មផ្ទៃក្នុងនៅក្នុងក្រសួង-ស្ថាប័ននីមួយៗ ដឹកនាំដោយបុគ្គលដែលមានបទពិសោធន៍ និងមកពីក្រៅក្រសួង-ស្ថាប័ន (សូមមើលស្តង់ដារវិទ្យាស្ថាននៃសវនករផ្ទៃក្នុង, IIA Standards)។ |
| ៣.៣ គណនេយ្យ ការកត់ត្រា និងរបាយការណ៍ | | |
| PI-22 | ភាពទាន់ពេលនិងភាពទៀងទាត់នៃការផ្ទៀងផ្ទាត់គណនី | ដើម្បីទទួលបានពិន្ទុ A ក្នុងសូចនាករនេះ, គ្រប់គណនី គួរត្រូវផ្ទៀងផ្ទាត់ជាប្រចាំ និងឱ្យបានគ្រប់ជ្រុងជ្រោយ ហើយការទូទាត់បុរេប្រទានក្នុងឆ្នាំ គួរត្រូវពន្លឿន ដើម្បីជៀសវាងការយឺតយ៉ាវក្នុងការទូទាត់ ឬការយោងទៅឆ្នាំក្រោយ។ |
| PI-23 | អត្ថិភាពនៃព័ត៌មានស្តីពីធនធានដែលទទួលបានពីអង្គភាពផ្តល់សេវា | ដើម្បីទទួលបានពិន្ទុខ្ពស់ជាងនេះ ក្រសួង-ស្ថាប័ន គួរពង្រឹងការប្រមូលទិន្នន័យ ឬប្រព័ន្ធគណនេយ្យ ដើម្បីប្រមូលទិន្នន័យដែលសុក្រឹតពាក់ព័ន្ធនឹងធនធានថវិកានិងសម្ភារៈដែលទទួលបាននៅសាលាបឋមសិក្សានិងមណ្ឌលសុខភាពទូទាំងប្រទេស ហើយព័ត៌មានទាំងនេះ គួរត្រូវបញ្ចូលក្នុងរបាយការណ៍ យ៉ាងហោចណាស់ជាប្រចាំឆ្នាំ។ |

| សូចនាករសមិទ្ធកម្ម | | អនុសាសន៍ |
|---|---|---|
| PI-24 | គុណភាព និងភាពទាន់ពេលនៃរបាយការណ៍ថវិកាក្នុងឆ្នាំ | គុណភាពនៃរបាយការណ៍អនុវត្តថវិកាក្នុងឆ្នាំ គួរត្រូវកែលម្អដោយបញ្ចូលនូវគ្រប់ចំណាយនានា ដែលប្រើប្រាស់ថវិការបស់ដៃគូអភិវឌ្ឍន៍។ |
| PI-25 | គុណភាព និងភាពទាន់ពេលវេលានៃរបាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ | របាយការណ៍ហិរញ្ញវត្ថុប្រចាំឆ្នាំ មានតែចំណូលនិងចំណាយដោយពុំមានរាយការណ៍ពីទ្រព្យនិងបំណុល (Assets and Liabilities) ឡើយ។ ការបញ្ចូលស្ថានភាពនៃទ្រព្យ និងបំណុល ដូចមានក្នុងតារាងតុល្យការសាកល្បង (Trial Balances), នឹងជាជំហានសំខាន់សម្រាប់ការអនុលោមតាមប្រព័ន្ធ IPSAS Cash-basis។ ការណ៍នេះ នឹងតម្រូវឱ្យមានការកែប្រែក្របខ័ណ្ឌគតិយុត្ត, ការអភិវឌ្ឍទម្រង់ថ្មី និងការបណ្តុះបណ្តាលបន្ថែម។ |
| ៣.៤ ការត្រួតពិនិត្យ និងសវនកម្មផ្ទៃក្រៅ | | |
| PI-26 | វិសាលភាព ចរិតលក្ខណៈ និងការតាមដានបន្តនៃសវនកម្មពីខាងក្រៅ | គ្មានអនុសាសន៍ |
| PI-27 | ការត្រួតពិនិត្យលើច្បាប់ថវិកាប្រចាំឆ្នាំដោយអង្គនីតិប្បញ្ញត្តិ | គ្មានអនុសាសន៍ |
| PI-28 | ការត្រួតពិនិត្យលើរបាយការណ៍សវនកម្មពីខាងក្រៅដោយអង្គនីតិប្បញ្ញត្តិ | គ្មានអនុសាសន៍ |
| ៤. ការអនុវត្តរបស់ដៃគូអភិវឌ្ឍន៍ | | |
| D-1 | ការប៉ាន់ប្រមាណ Budget Support | គ្មានអនុសាសន៍ |
| D-2 | ព័ត៌មានហិរញ្ញវត្ថុដែលត្រូវបានផ្តល់ដោយដៃគូអភិវឌ្ឍន៍សម្រាប់ការរៀបចំថវិកា និងការ | គ្មានអនុសាសន៍ |

| សូចនាករសមិទ្ធកម្ម | | អនុសាសន៍ |
|---|---|---|
| | របាយការណ៍ពីហិរញ្ញប្បទានសម្រាប់គម្រោងនិងកម្មវិធី | |
| D-3 | ទំហំនៃហិរញ្ញប្បទានដែលត្រូវបានគ្រប់គ្រងតាមនីតិវិធីជាតិ | គ្មានអនុសាសន៍ |

គណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**គ.ហ.ស.**) ត្រូវបានបង្កើតឡើងដោយអនុក្រឹត្យលេខ ២៣ អនក្រ.បក ចុះថ្ងៃទី១៧ ខែមករា ឆ្នាំ២០១៤ ដើម្បីបំពេញភារកិច្ចដឹកនាំ រៀបចំ សម្របសម្រួលការអនុវត្ត តាមដាន និងត្រួតពិនិត្យការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈរបស់រាជរដ្ឋាភិបាល ព្រមទាំងសម្របសម្រួលកិច្ចសហប្រតិបត្តិការ ជាមួយដៃគូអភិវឌ្ឍន៍ ដែលមានការពាក់ព័ន្ធ។

**គ.ហ.ស.** មានសមាសភាព ដូចតទៅ÷

| | | |
|---|---|---|
| ១. រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | | ប្រធាន |
| ២. រដ្ឋលេខាធិការក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ | មួយរូប | អនុប្រធានប្រចាំការ |
| ៣. ទេសាភិបាលរងនៃធនាគារជាតិនៃកម្ពុជា | មួយរូប | អនុប្រធាន |
| ៤. រដ្ឋលេខាធិការ អនុរដ្ឋលេខាធិការ ឬថ្នាក់ដឹកនាំប្រហាក់ប្រហែលមួយរូប ពីគ្រប់ក្រសួង ស្ថាប័ន និងអង្គភាពពាក់ព័ន្ធ | | សមាជិក |
| ៥. អគ្គលេខាធិការនៃក្រុមប្រឹក្សាអភិវឌ្ឍន៍កម្ពុជា | | សមាជិក |
| ៦. អង្គភាពប្រតិបត្តិនៃគណៈកម្មាធិការដឹកនាំការងារកែទម្រង់ដែលមានការពាក់ព័ន្ធផ្សេងទៀត | | សមាជិក |
| ៧. អគ្គលេខាធិការនៃអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ | | សមាជិកអចិន្ត្រៃយ៍។ |

**គ.ហ.ស.** មានអគ្គលេខាធិការដ្ឋានមួយជាសេនាធិការ គឺអគ្គលេខាធិការដ្ឋានគណៈកម្មាធិការដឹកនាំការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ (**អ.គ.ហ.**) ដែលមានភារកិច្ចសម្របសម្រួលការរៀបចំនិងការអនុវត្តកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ របស់រាជរដ្ឋាភិបាល។ **អ.គ.ហ.** ដឹកនាំដោយអគ្គលេខាធិការ មួយរូប អមដោយអគ្គលេខាធិការរងមួយចំនួន ជាជំនួយការ និងមន្ត្រីជំនាញពាក់ព័ន្ធ ដែលមានសមាសភាពដូចតទៅ÷

| | |
|---|---|
| ១. ឯកឧត្តម **រស់ សីលវ៉ា** | អគ្គលេខាធិការ |
| ២. ឯកឧត្តមបណ្ឌិត **ហ៊ែល ចំរើន** | អគ្គលេខាធិការរង |
| ៣. លោក **ម៉ូ ទេវស្សុខា** | អគ្គលេខាធិការរង |
| ៤. លោក **យ៉េត វិណ្ណៃល** | អគ្គលេខាធិការរង |
| ៥. លោក **មាស សុខសេនសាន** | អគ្គលេខាធិការរង |
| ៦. លោក **ប៉ែន ធីរុទ្ធ** | អគ្គលេខាធិការរង |
| ៧. លោក **អ៊ុំង លុយណា** | អគ្គលេខាធិការរង |
| ៨. លោក **អ៊ុំ យុទ្ធី** | មន្ត្រីជំនាញជាន់ខ្ពស់ |
| ៩. លោក **ឡៀង សុភីរម្យ** | មន្ត្រីជំនាញ |
| ១០. លោក **យន ម៉ាលីមឆេង** | មន្ត្រីជំនាញ |
| ១១. លោក **លី ឌុំង** | មន្ត្រីជំនាញ |
| ១២. លោក **ហៀង សូយ៉ារ៉ូ** | មន្ត្រីជំនាញ |
| ១៣. លោក **អ៊ុច សោភ័ណ** | មន្ត្រីជំនាញ |
| ១៤. លោកស្រី **សុគន្ធ ចរិយា** | មន្ត្រីជំនាញ |
| ១៥. លោក **ឡាំង ឧត្តម** | មន្ត្រីជំនាញ។ |

កម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈនៅកម្ពុជា ត្រូវបានរៀបចំឡើងជា ៤ ជំហាន និងចែកចេញជា ៤ ដំណាក់កាល និងត្រូវបានដាក់ឱ្យអនុវត្តប្រកបដោយលក្ខណៈគ្រប់ជ្រុងជ្រោយ ភាពជាម្ចាស់ស្មារតីទទួលខុសត្រូវខ្ពស់ មហិច្ឆតា និងប្រាកដនិយម សម្រាប់រយៈពេលវែង ដូចតទៅ÷

- **ដំណាក់កាលទី ១ ÷ ការបង្កើនភាពជឿទុកចិត្តនៃថវិកា** មានរយៈពេលជាង ៤ឆ្នាំ (២០០៤ - ២០០៨) ដោយសម្រេចបានជោគជ័យនូវមូលដ្ឋានគ្រឹះនៃការពង្រឹងការគ្រប់គ្រងនិងប្រមូលចំណូល ព្រមទាំងការគ្រប់គ្រងសាច់ប្រាក់និងការកែលម្អយន្តការចំណាយ។
- **ដំណាក់កាលទី ២ ÷ ការបង្កើនគណនេយ្យភាពហិរញ្ញវត្ថុ** មានរយៈពេល ៦ឆ្នាំ (២០០៩ - ២០១៥) ដោយសម្រេចបានមូលដ្ឋានជាសារវន្តនៃគណនេយ្យភាពហិរញ្ញវត្ថុ ដែលមានជាអាទិ៍ ការដាក់ឱ្យអនុវត្តប្លង់គណនេយ្យថ្មី, មាតិកាថវិកាថ្មី, ថវិកាកម្មវិធី, ផែនការយុទ្ធសាស្ត្រថវិកា, អង្គភាពថវិកា និងប្រព័ន្ធព័ត៌មានវិទ្យាសម្រាប់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ។
- **ដំណាក់កាលទី ៣ ÷ ការបង្កើនការផ្សារភ្ជាប់ថវិកាទៅនឹងគោលនយោបាយ** ត្រូវបានរំពឹងថានឹងមានរយៈពេល ៥ឆ្នាំ (២០១៦-២០២០) ដើម្បីសម្រេចគោលដៅគន្លឹះនៃការ កែទម្រង់ប្រព័ន្ធថវិកាទាំងមូល គឺផ្លាស់ប្តូរពីប្រព័ន្ធគ្រប់គ្រងដែលផ្អែកលើធាតុចូលនិងមជ្ឈការ ឆ្ពោះទៅជាប្រព័ន្ធដែលផ្តោតលើលទ្ធផល ឬសមិទ្ធកម្ម និងវិមជ្ឈការ តាមរយៈការពង្រឹងនិងពង្រីកការអនុវត្តផែនការយុទ្ធសាស្ត្រថវិកា, ការអនុវត្តថវិកាកម្មវិធី, និងការអនុវត្តអង្គភាពថវិកា ព្រមទាំងការពង្រឹងការរៀបចំគោលនយោបាយ, ការព្យាករណ៍ និងការរៀបចំផែនការហិរញ្ញវត្ថុសាធារណៈ។
- **ដំណាក់កាលទី ៤ ÷ ការបង្កើនគណនេយ្យភាពសមិទ្ធកម្ម** ត្រូវបានរំពឹងថានឹងមានរយៈពេល ៥ឆ្នាំ (២០២១-២០២៥) ដើម្បីសម្រេចបានជាមូលដ្ឋាន នូវគណនេយ្យភាពសមិទ្ធកម្ម ដែលជាលទ្ធផលចុងក្រោយនៃកម្មវិធីកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈទាំងមូល។

**គណៈកម្មាធិការដឹកនាំ**

**ការងារកែទម្រង់ការគ្រប់គ្រងហិរញ្ញវត្ថុសាធារណៈ**